ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំប្រតិបត្តិ
# ស្ដីពី
# កិច្ចការពារកុមារនៅក្នុងសាលារៀន




នាយកដ្ឋានបឋមសិក្សា

ឆ្នាំ ២០២២

# មាតិកា


គណៈកម្មការដឹកនាំ ត្រួតពិនិត្យ និងរៀបចំ........................................................................................១
អារម្ភកថា.....................................................................................................................................៣
១. សេចក្តីផ្តើម.................................................................................................................................៤
២. គោលបំណង គោលដៅ និងគោលការណ៍.............................................................................................៥
២.១. គោលបំណង.........................................................................................................................៥
២.២. គោលដៅ..............................................................................................................................៥
២.៣. គោលការណ៍..........................................................................................................................៥
៣. វិធីបង្ការអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន ............................ ៧
៣.១. ការបង្កើតនីតិវិធីកិច្ចការពារកុមារ និងការតែងតាំងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន.......................................................................................................................... ៧
៣.២. ការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ...............៨
៣.៣. ការលើកកម្ពស់ការបង្រៀន និងទំនាក់ទំនងវិជ្ជមានរវាងគ្រូបង្រៀន និងសិស្សានុសិស្ស ...... ១៤
៣.៤. ការលើកកម្ពស់ការចូលរួមរបស់កុមារប្រកបដោយសុវត្ថិភាពនៅក្នុងសាលារៀន................ ១៥
៣.៥. ការគ្រប់គ្រងភ្ញៀវ និងអ្នកមកទស្សនកិច្ចសាលារៀន ................................................... ១៨
៤. វិធីឆ្លើយតប និងបញ្ជូនករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ........................២០
៤.១. យន្តការរាយការណ៍.............................................................................................................២០
៤.២. យន្តការឆ្លើយតប និងបញ្ជូនកុមារទៅរកសេវាគាំទ្រត្រឹមត្រូវ ................................................២៤
៥. វិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង .............................៣៤
៥.១. ប្រភេទគ្រោះមហន្តរាយផ្សេងៗដែលអាចកើតឡើងមកលើកុមារ ...........................................34
៥.២. ជំហាននៃវិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង .........៣៤
៥.៣. ការទទួលខុសត្រូវក្នុងការឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង....៣៥
៦. យន្តការគាំទ្រ និងតាមដានត្រួតពិនិត្យការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន................. ៤០
៦.១. ក្រសួងអប់រំ យុវជន និងកីឡា................................................................................................ ៤០
៦.២. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត .............................................................................៤១
៦.៣. ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ...........................................................៤២
៦.៤. រដ្ឋបាលឃុំ សង្កាត់ ...........................................................................................................៤២
៦.៥. គណៈកម្មការគ្រប់គ្រងសាលារៀន..........................................................................................៤៣
ឧបសម្ព័ន្ធទី ១ ៖ គំរូមាតិកានៃនីតិវិធីកិច្ចការពារកុមារនៅក្នុងសាលារៀន ....................................... ៤៥
ឧបសម្ព័ន្ធទី ២.ក ៖ គំរូក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់បុគ្គលិកសាលារៀន ................... ៤៦
ឧបសម្ព័ន្ធទី ២.ខ ៖ គំរូក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់ភ្ញៀវ និងអ្នកមកទស្សនកិច្ចនៅសាលារៀន. ៤៨
ឧបសម្ព័ន្ធទី ៣ ៖ ការណែនាំស្តីពីការរៀបចំជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន..... ៥០

ឧបសម្ព័ន្ធទី ៤ ៖ ឯកសារជំនួយសម្រាប់គាំទ្រសុខភាពផ្លូវចិត្តដល់កុមារ ........................................ ៥២
ឧបសម្ព័ន្ធទី ៥ ៖ ទម្រង់សិក្សា និងកាត់បន្ថយហានិភ័យកិច្ចការពារកុមារ ........................................ ៥៤
ឧបសម្ព័ន្ធទី ៦ ៖ ទម្រង់នៃការយល់ព្រមឯកភាពពីកុមារ ឪពុកម្ដាយ និងអ្នកអាណាព្យាបាល........... ៥៥
ឧបសម្ព័ន្ធទី ៧ ៖ ទម្រង់នៃការយល់ព្រមពីអ្នកមើលថែកុមារ ........................................ ៥៦
ឧបសម្ព័ន្ធទី ៨ ៖ ទម្រង់ចុះបញ្ជី និងបញ្ជូនករណី ........................................ ៥៨
ឧបសម្ព័ន្ធទី ៩ ៖ ទម្រង់បច្ចុប្បន្នភាពពីស្ថានភាពកុមារ........................................ ៦០
ឧបសម្ព័ន្ធទី ១០ ៖ ឧបករណ៍សម្រាប់គ្រូតពិនិត្យការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន ........ ៦១
ឧបសម្ព័ន្ធទី ១១ ៖ សន្ទានុក្រមពាក្យគន្លឹះ........................................ ៦៥
ឧបសម្ព័ន្ធទី ១២ ៖ ឯកសារគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងសាលារៀន.. ៧០
ឯកសារយោង ........................................ ៧២

# គណៈកម្មការដឹកនាំ ត្រួតពិនិត្យ និងរៀបចំ

## ក. គណៈកម្មការដឹកនាំ

| | | |
|---|---|---|
| ១. ឯ.ឧ.បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២. ឯ.ឧ.បណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. លោកជំទាវបណ្ឌិត **ស្មើ សុជាតា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤. ឯ.ឧ. **ពុត សាមិត្ត** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៥. ឯ.ឧ.បណ្ឌិត **ចាន់ សុភា** | ប្រធាននាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៦. ឯ.ឧ.បណ្ឌិត **ស៊ីន សេងហុក** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៧. លោកជំទាវវេជ្ជបណ្ឌិត **ឆាយគីម សុទ្ធាវី** | ប្រធាននាយកដ្ឋានសុខភាពសិក្សា | សមាជិក |
| ៨. លោក **ង៉ោ ម៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ | សមាជិក |
| ៩. លោក **ស៊ុន ប៊ុនណា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា | សមាជិក |
| ១០. លោក **ឈុន រ៉ាមី** | អនុប្រធាននាយកដ្ឋានបឋមសិក្សា | សមាជិក |

## ខ. គណៈកម្មការត្រួតពិនិត្យ

| | | |
|---|---|---|
| ១. ឯ.ឧ.បណ្ឌិត **ចាន់ សុភា** | ប្រធាននាយកដ្ឋានបឋមសិក្សា | ប្រធាន |
| ២. លោក **ឈុន រ៉ាមី** | អនុប្រធាននាយកដ្ឋានបឋមសិក្សា | អនុប្រធាន |
| ៣. លោក **គុយ ច័ន្ទមង្គល** | ប្រធានការិយាល័យនៃនាយកដ្ឋានបឋមសិក្សា | សមាជិក |

## គ. គណៈកម្មការរៀបចំ

| | | |
|---|---|---|
| ១. ឯ.ឧ.បណ្ឌិត **ចាន់ សុភា** | ប្រធាននាយកដ្ឋានបឋមសិក្សា | ប្រធាន |
| ២. លោក **ឈុន រ៉ាមី** | អនុប្រធាននាយកដ្ឋានបឋមសិក្សា | អនុប្រធាន |
| ៣. លោក **គុយ ច័ន្ទមង្គល** | ប្រធានការិយាល័យនៃនាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៤. លោក **សេង សុវ៉ាត** | ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម | សមាជិក |
| ៥. លោកស្រី **សរ ហ៊ីន** | ប្រធានការិយាល័យនៃនាយកដ្ឋានសុខភាពសិក្សា | សមាជិក |
| ៦. លោកស្រី **យក់ វណ្ណា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៧. កញ្ញា **តូច រដ្ឋា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៨. លោក **ជា សេង** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៩. លោកស្រី **ហ្វូ នៃរ័ត្ន** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ | សមាជិក |
| ១០. លោក **សុខ បញ្ញាវឌ្ឍ** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា | សមាជិក |
| ១១. តំណាងអង្គការ | UNICEF | សមាជិក |
| ១២. តំណាងអង្គការ | Save the Children Cambodia | សមាជិក |
| ១៣. តំណាងអង្គការ | Plan International Cambodia | សមាជិក |

| | | |
|---|---|---|
| ១៤. តំណាងអង្គការ | World Vision International Cambodia | សមាជិក |
| ១៥. តំណាងអង្គការ | ChildFund Cambodia | សមាជិក |
| ១៦. តំណាងអង្គការ | Child Right Foundation | សមាជិក |
| ១៧. លោក **ឥ សុវណ្ណារី** | ទីប្រឹក្សាឯករាជ្យផ្នែកសិទ្ធិកុមារ | សមាជិក |
| ១៨. លោក **ឈួន ប៊ុណ្ណា** | ទីប្រឹក្សាឯករាជ្យផ្នែកអភិវឌ្ឍន៍សមត្ថភាព | សមាជិក |
| ១៩. លោកស្រី **ម៉ែន វណ្ណាវី** | អ្នកជំនាញកិច្ចការពារកុមារ | សមាជិក |

# អារម្ភកថា

កិច្ចការពារកុមារ គឺជាកិច្ចការដ៏សំខាន់មួយ ដែលរបស់រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលទៅក្នុងក្របខណ្ឌគោលនយោបាយជាតិ នៅតាមវិស័យពាក់ព័ន្ធសំខាន់ៗ ដើម្បីការពារ ពង្រឹង និងលើកកម្ពស់សិទ្ធិកុមារ។ ជាមួយគ្នានេះ ព្រះរាជាណាចក្រកម្ពុជាក៏ជារដ្ឋហត្ថលេខីមួយនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពី សិទ្ធិកុមារនៅឆ្នាំ១៩៩២ និងបានចាប់ផ្តើមអនុវត្តអនុសញ្ញានេះ រហូតមកទល់បច្ចុប្បន្ន។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រដ្ឋធានារក្សាការពាររបស់សិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ, សិទ្ធិទទួលបានការអប់រំរៀនសូត្រ, សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម, និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។

ដើម្បីចូលរួមចំណែក និងធានាកិច្ចការពារកុមារនៅក្នុងវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តនូវគោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន, គោលការណ៍ណែនាំស្តីពីសាលារៀនសុវត្ថិភាព, សៀវភៅណែនាំស្តីពីការដាក់ពិន័យតាមបែបវិជ្ជមាន ជាដើម ក្នុងគោលបំណងធានាឱ្យកុមារគ្រប់រូបទទួលបាននូវកិច្ចការពារ, បរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព, និងការគាំទ្រដល់កុមារដោយសមធម៌ និងបរិយាបន្ននៅតាមសាលារៀនសាធារណៈ និងឯកជន ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ។

សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវបានរៀបចំឡើង ក្នុងគោលបំណងជំរុញការអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងជាជំនួយដល់សាលារៀននីមួយៗក្នុងការប្រតិបត្តិការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងមានប្រសិទ្ធភាព ដូចជា ការបង្ការទប់ស្កាត់អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ, ការឆ្លើយតប, និងការបញ្ជូនកុមារទៅទទួលសេវាគាំទ្រត្រឹមត្រូវ។ សៀវភៅណែនាំប្រតិបត្តិនេះ នឹងចាប់ផ្តើមអនុវត្តជំហានដំបូងនៅក្នុងកម្រិតបឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងជឿជាក់ថា សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀននេះ ជាឧបករណ៍មគ្គុទ្ទេសក៍ដ៏សំខាន់ សម្រាប់បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ អ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តតួនាទីកាន់តែសកម្ម, ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ, និងមានគណនេយ្យភាពខ្ពស់ចំពោះការងាររបស់ខ្លួន សំដៅធានាដល់កុមារគ្រប់រូបនៅក្នុងសាលារៀន ទទួលបានបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព និងរីករាយ ដោយគ្មានការរើសអើង, អំពើហិង្សា, និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ ដើម្បីឱ្យពួកគេក្លាយជាសមាជិក ឬពលរដ្ឋដ៏មានសក្តានុពល និងសកម្មនៅក្នុងសង្គម។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ក្រសួង ស្ថាប័ន នាយកដ្ឋាន មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា សាលារៀន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលទាំងអស់ដែលបានចូលរួមចំណែកដ៏ធំធេងក្នុងការរៀបចំសៀវភៅណែនាំប្រតិបត្តិនេះឡើង ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារគ្រប់រូបនៅកម្ពុជា។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# ១. សេចក្តីផ្តើម

អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ គឺជាការរំលោភបំពានសិទ្ធិមនុស្ស ហើយបញ្ហានេះត្រូវបានចាត់ទុកជាបញ្ហាសង្គម និងសុខភាពសាធារណៈមួយដ៏ធ្ងន់ធ្ងរ ដែលអាចកើតឡើងនៅគ្រប់ទីកន្លែង ដូចជា នៅតាមផ្ទះ សាលារៀន សហគមន៍ គ្រឹះស្ថាននានា និងតាមប្រព័ន្ធអនឡាញជាដើម។ល។ បញ្ហាទាំងនេះបានផ្តល់ផលវិបាក និងបង្កគ្រោះថ្នាក់ចំពោះកុមារ ក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។ នៅប្រទេសកម្ពុជា មានកុមារអាយុក្រោម១៥ឆ្នាំ ប្រមាណ៣៥% នៃចំនួនប្រជាជនសរុប ដែលជាអត្រាខ្ពស់មួយនៅក្នុងតំបន់។ អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅតែជាបញ្ហាប្រឈម និងមានអត្រាខ្ពស់ បើយោងតាម របកគំហើញពីរបាយការណ៍អង្កេតស្តីពីអំពើហិង្សាលើកុមារនៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ២០១៣ ដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូនីសេហ្វ(UNICEF) បានបង្ហាញឱ្យឃើញថា កុមារច្រើនជាង ៥០% ធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវកាយ ២៥% ទទួលរងការរំលោភបំពានលើផ្លូវចិត្ត ហើយប្រហែលជា ៥% ទទួលរងពីការរំលោភបំពានលើផ្លូវភេទ។ ជាមួយគ្នានេះផងដែរ នៅឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានបឋមសិក្សា បានធ្វើការសិក្សាស្រាវជ្រាវមួយស្តីពីអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាតាមសាលារៀនបានរកឃើញថា សិស្សចំនួន ៧៣% បានធ្លាប់ទទួលរង ឬធ្លាប់ឃើញការដាក់ពិន័យក្នុងទម្រង់ជាទណ្ឌកម្មលើរាងកាយកម្រិតស្រាលពីគ្រូបង្រៀន ខណៈដែលសិស្សចំនួន ៣% បានធ្លាប់ទទួលរង ឬធ្លាប់ឃើញការប្រព្រឹត្តិអំពើហិង្សាលើរាងកាយធ្ងន់ធ្ងរ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងសៀវភៅណែនាំបច្ចេកទេសមួយចំនួន *សូមមើលឧបសម្ព័ន្ធទី ១២ ៖ ឯកសារគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងសាលារៀន (ទំព័រទី៧០)* សំដៅជានាលើកកម្ពស់សិទ្ធិកុមារ និងកិច្ចការពារកុមារជាប្រព័ន្ធ។ សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ជាសមិទ្ធផលថ្មីមួយទៀត ដែលជាផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ឆ្នាំ២០១៩-២០២៣។

សៀវភៅណែនាំប្រតិបត្តិនេះ ក៏ជាវិធានដ៏ជាក់លាក់សម្រាប់ការបង្ការ ការឆ្លើយតប និងការបញ្ជូនកុមារដែលទទួលរងនូវអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន។
សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀនបានបែងចែកជា ៦ផ្នែក រួមមាន៖

- សេចក្តីផ្តើម
- គោលបំណង គោលដៅ និងគោលការណ៍
- វិធីបង្ការអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន
- វិធីឆ្លើយតប និងបញ្ជូនករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- វិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង
- យន្តការគាំទ្រ និងតាមដានត្រួតពិនិត្យការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន។

# ២. គោលបំណង គោលដៅ និងគោលការណ៍

សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន បានផ្តោតលើគោលបំណង គោលដៅ និងគោលការណ៍ដូចខាងក្រោម៖

## ២.១. គោលបំណង

កុមារគ្រប់រូបមានសិទ្ធិទទួលបានបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព និងសុខុមាលភាព ដែលជួយដល់ការអភិវឌ្ឍផ្នែករាងកាយ ផ្លូវចិត្ត បញ្ញា ស្មារតី ដោយគ្មានអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន ទាំងគ្រឹះស្ថានសាធារណៈ និងឯកជន ដើម្បីឱ្យក្លាយជាធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចីរភាព។

## ២.២. គោលដៅ

ដើម្បីសម្រេចគោលបំណងខាងលើ សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន បានកំណត់គោលដៅ ដូចខាងក្រោម៖

- ជំរុញការអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ឆ្នាំ២០១៩-២០២៣ ឱ្យមានប្រសិទ្ធភាព
- អភិវឌ្ឍន៍ប្រព័ន្ធ យន្តការ តួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងកិច្ចការពារកុមារ និងសុខុមាលភាពរបស់កុមារ បុគ្គលិកអប់រំ គ្រូបង្រៀន សិស្សានុសិស្ស អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធ ដោយធានាថា សាលារៀនសាធារណៈ និងឯកជន នៅកម្រិតបឋមសិក្សាជាទីកន្លែងដែលកុមារមានសុវត្ថិភាពដែលគ្មានអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ជាពិសេស កុមារមានពិការភាព កុមារកំព្រា កុមារមិនកំណត់អត្តសញ្ញាណភេទ ។ល។
- ផ្តល់ជាមគ្គុទេសក៍សម្រាប់សាលារៀនបឋមសិក្សានីមួយៗក្នុងការអភិវឌ្ឍសមត្ថភាព និងអនុវត្តកិច្ចការពារកុមារប្រកបដោយប្រសិទ្ធភាព ដូចជា ការបង្ការ ការទប់ស្កាត់ ការឆ្លើយតប និងការបញ្ជូនកុមារដែលរងគ្រោះពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ទៅទទួលសេវាគាំទ្រត្រឹមត្រូវ
- ផ្សារភ្ជាប់ទំនាក់ទំនង និងកិច្ចសហការឱ្យកាន់តែប្រសើរឡើង រវាងយន្តការកិច្ចការពារកុមារនៅក្នុងសាលារៀនជាមួយនឹងយន្តការកិច្ចការពារកុមារនៅក្នុងសហគមន៍ទាំងអស់។

## ២.៣. គោលការណ៍

ដើម្បីអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀនឱ្យមានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ អ្នកអនុវត្តទាំងអស់ត្រូវគោរព និងប្រកាន់ខ្ជាប់នូវគោលការណ៍ដូចខាងក្រោម៖

- ***ឧត្តមប្រយោជន៍របស់កុមារ៖*** រាល់ការសម្រេចចិត្តណាមួយដែលមានឥទ្ធិពលទៅលើកុមារត្រូវតែគិតជាអាទិភាពនូវឧត្តមប្រយោជន៍ដ៏ខ្ពស់បំផុតសម្រាប់កុមារ មានន័យថា នៅពេលធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសកម្មភាពណាមួយ ត្រូវតែគិតពិចារណាយ៉ាងហ្មត់ចត់ ថាតើការសម្រេចចិត្ត និងសកម្មភាពដែលត្រូវអនុវត្តនោះនឹងមានឥទ្ធិពលទៅលើកុមារបែបណាខ្លះ
- ***ការមិនរើសអើងចំពោះកុមារគ្រប់រូប៖*** ការផ្តល់តម្លៃលើកុមារដោយស្មើភាព និងសមធម៌ គឺជាចំណុចចម្បងនៃការសម្រេចចិត្ត និងអនុវត្តសកម្មភាពណាមួយដែលមានឥទ្ធិពលលើកុមារ។ កុមារដែលស្ថិតក្នុងស្ថានភាពគ្រួសារក្រីក្រ យេនឌ័រ កុមារមិនកំណត់អត្តសញ្ញាណភេទ ពូជសាសន៍ ពណ៌សម្បុរ វប្បធម៌ សាសនា សមត្ថភាព រូបរាងកាយ ជនជាតិដើមភាគតិច ការចូលចិត្ត មានពិការភាព ឬទស្សនៈនយោបាយខុសគ្នា គឺមិនត្រូវបានរើសអើង ប៉ុន្តែត្រូវបានយកចិត្តទុកដាក់ និងផ្តល់ឱកាសឱ្យចូលរួម ព្រមទាំងទទួលបានផលប្រយោជន៍ដូចៗគ្នា។ កិច្ចគាំទ្រជាពិសេសដល់កុមារដែលងាយរងគ្រោះជាងគេ ដើម្បីឱ្យមានការចូលរួម និងការទទួលបានផលប្រយោជន៍ពីការសម្រេចចិត្ត និងការអនុវត្តសកម្មភាពនោះ។ ការសម្រេចចិត្ត និងការអនុវត្តសកម្មភាពដែលពាក់ព័ន្ធនឹងកុមារ ត្រូវតែគិតពិចារណា និងរៀបចំជាស្រេចមុនពេលអនុវត្ត
- ***ការគោរពទស្សនៈរបស់កុមារ៖*** កុមារគ្រប់រូបត្រូវបានផ្តល់ឱកាសឱ្យចូលរួមពិគ្រោះយោបល់ និងបញ្ចេញមតិប្រកបដោយសុវត្ថិភាព និងរីករាយក្នុងការសម្រេចចិត្តនានាដែលមានឥទ្ធិពលលើជីវិតរបស់ពួកគេ។ ការសម្របសម្រួល និងការលើកទឹកចិត្តដែលសមស្របត្រូវតែអនុវត្ត ដើម្បីធានាថា មតិ និងគំនិតយោបល់របស់កុមារត្រូវបានគេស្តាប់ និងទទួលយកស្របទៅតាមស្ថានភាព ឬការលូតលាស់របស់កុមារ
- ***ការគោរពឯកជនភាពរបស់កុមារ៖*** ការប្រតិបត្តិកិច្ចការពារកុមារ ត្រូវតែរក្សាការសម្ងាត់ និងឯកជនភាពរបស់កុមារ។ កិច្ចការនេះ គឺជាកត្តាសំខាន់ និងចាំបាច់ដែលត្រូវដាក់បញ្ចូលទៅក្នុងសេចក្តីសម្រេចចិត្ត ឬសកម្មភាពនានាដែលមានឥទ្ធិពលលើកុមារ។ ការមិនយកចិត្តទុកដាក់លើឯកជនភាពរបស់កុមារអាចផ្តល់នូវហានិភ័យបន្ថែមចំពោះកុមារ ឬគំរាមកំហែងដល់សុវត្ថិភាព ឬអាយុជីវិតរបស់ពួកគេ និងគ្រួសារផងដែរ។

## ៣. វិធីបង្ការអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន

ផ្នែកវិធីបង្ការអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀននឹងរៀបរាប់លម្អិតអំពីចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការបង្កើតនីតិវិធីកិច្ចការពារកុមារ និងការតែងតាំងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន
- ការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- ការលើកកម្ពស់ការបង្រៀន និងការទំនាក់ទំនងវិជ្ជមានរវាងគ្រូបង្រៀន និងសិស្សានុសិស្ស
- ការចូលរួមរបស់កុមារប្រកបដោយសុវត្ថិភាព
- ការគ្រប់គ្រងភ្ញៀវ និងអ្នកមកទស្សនកិច្ចសាលារៀន

### ៣.១. ការបង្កើតនីតិវិធីកិច្ចការពារកុមារ និងការតែងតាំងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន

ការបង្កើតនីតិវិធីស្តីពីកិច្ចការពារកុមារសម្រាប់សាលារៀន ជាកិច្ចការបឋម និងចាំបាច់សម្រាប់ការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀនប្រកបដោយប្រសិទ្ធភាព។ គណៈកម្មការគ្រប់គ្រងសាលារៀន ឬនាយក/នាយិកាសាលា ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលកិច្ចការនេះ ដែលពួកគាត់មានតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំបង្កើត និងអនុម័តនីតិវិធីកិច្ចការពារកុមារ និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមាររបស់សាលារៀន ស្របតាមសេចក្តីណែនាំស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ដោយសិក្សាពីបរិបទ និងស្ថានភាពរបស់សាលារៀន និងធ្វើការផ្សព្វផ្សាយនីតិវិធីទាំងនោះដល់បុគ្គលិកសាលារៀន និងគ្រូបង្រៀន អ្នកស្ម័គ្រចិត្ត ភ្ញៀវ និងអ្នកពាក់ព័ន្ធទាំងអស់របស់សាលារៀន។ សូមមើលឧបសម្ព័ន្ធ ដូចខាងក្រោម៖
    - *ឧបសម្ព័ន្ធទី ១ ៖ គំរូមាតិកានៃនីតិវិធីកិច្ចការពារកុមារនៅក្នុងសាលារៀន (ទំព័រទី៤៥)*
    - *ឧបសម្ព័ន្ធទី ២.ក ៖ គំរូក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់បុគ្គលិកសាលារៀន (ទំព័រទី៤៦)*
    - *ឧបសម្ព័ន្ធទី ២.ខ ៖ គំរូក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់ភ្ញៀវ និងអ្នកមកទស្សនកិច្ចនៅសាលារៀន (ទំព័រទី៤៨)*
- តែងតាំងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារប្រចាំសាលារៀន។ *សូមមើលឧបសម្ព័ន្ធទី ៣ ៖ ការណែនាំស្តីពីការរៀបចំជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន (ទំព័រទី៥០)*
- ជ្រើសរើសអ្នកផ្តល់ប្រឹក្សាផ្លូវចិត្តដល់កុមារ ឬភ្នាក់ងារសង្គមកិច្ចប្រចាំសាលារៀនបើមានលទ្ធភាព ឬបំប៉នសមត្ថភាពគ្រូអំពីការផ្តល់សេវាប្រឹក្សាផ្លូវចិត្ត ឬមានកិច្ចគាំទ្រផ្តល់ភ្នាក់ងារសង្គមកិច្ចដោយសហការជាមួយស្ថាប័នជំនាញរបស់រដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ឬទំនាក់ទំនងទៅបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជាលេខ ១២៨០ ដើម្បីឱ្យកុមារទទួលបានការផ្តល់ប្រឹក្សាផ្លូវ

ចិត្តទាន់ពេលវេលា។ *សូមមើលឧបសម្ព័ន្ធទី ៤ ៖ ឯកសារជំនួយសម្រាប់គាំទ្រសុខភាពផ្លូវចិត្តដល់កុមារ (ទំព័រទី៥២)*

- រៀបចំផែនការសកម្មភាពស្តីពីការអនុវត្តកិច្ចការពារកុមាររបស់សាលារៀន ដោយបញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន និងវិភាជន៍ថវិកាសាលារៀនសម្រាប់អនុវត្តផែនការនោះ។

**៣.២. ការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ**

អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ អាចមានទិដ្ឋភាពខុសៗគ្នានៅក្នុងមជ្ឈដ្ឋានផ្សេងៗគ្នា។ នៅក្នុងសាលារៀន អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ អាចប្រព្រឹត្តដោយគ្រូបង្រៀន បុគ្គលិកសាលារៀន ភ្ញៀវមកទស្សនកិច្ច សិស្សានុសិស្ស ឪពុកម្តាយ អ្នកអាណាព្យាបាល ។ល។ ដើម្បីបង្កើនការយល់ដឹងអំពីកិច្ចការពារកុមារនៅក្នុងសាលារៀន អ្នកពាក់ព័ន្ធទាំងអស់គួរស្វែងយល់ឱ្យបានស៊ីជម្រៅអំពីពាក្យគន្លឹះមួយចំនួនដែលទាក់ទងនឹងកិច្ចការពារកុមារ។ *សូមមើលឧបសម្ព័ន្ធទី ១១ ៖ សន្ទានុក្រមពាក្យគន្លឹះ (ទំព័រទី៦៥)*

ដើម្បីការលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ អ្នកពាក់ព័ន្ធត្រូវអនុវត្តកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ការកំណត់នូវអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន
- ការតម្រង់ទិស និងផ្សព្វផ្សាយអំពីកិច្ចការពារកុមារនៅក្នុងសាលារៀនដល់បុគ្គលិកសាលារៀន គ្រូបង្រៀន អ្នកអាណាព្យាបាល អ្នកស្ម័គ្រចិត្តរបស់សាលារៀន និងអ្នកសហគមន៍
- ការបណ្តុះបណ្តាលដល់សិស្សានុសិស្សអំពីកិច្ចការពារខ្លួនពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ

## *ក. ការកំណត់អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន*

## *ក.១. ការកំណត់ទម្រង់ ការប្រព្រឹត្ត/សកម្មភាព និងសញ្ញាណសម្គាល់*

| ទម្រង់ | ការប្រព្រឹត្ត/សកម្មភាព | សញ្ញាណសម្គាល់ |
|---|---|---|
| អំពើហិង្សាផ្លូវកាយ | ▪ ការវាយនឹងរំពាត់ វាយនឹងវត្ថុនានា ទាត់ ដាក់ រុញ ច្រាន វាយតប់ ក្តិច មួល ខ្ទាំ ទះកំផ្លៀង ខោកឬត្បកក្បាល ឬបោចសក់<br>▪ ការធ្វើទារុណកម្មលើកុមារ ដូចជាឱ្យឈរហាលថ្ងៃ ឬនៅលើវត្ថុរឹងរយៈពេលយូរ រត់ជុំវិញដងទង់ជាតិ។ល។ | ▪ មានស្នាមរបួសនៅលើរាងកាយ<br>▪ ឆាប់ខ្លាច និងខឹងនៅពេលមិត្តភក្តិធ្វើអ្វីខុស<br>▪ មិនហ៊ានទៅផ្ទះ ឬមិនហ៊ានទៅសាលារៀន |

| | | |
|---|---|---|
| | ▪ ការវាយធ្វើបាបរវាងសិស្ស និងសិស្ស | |
| អំពើហិង្សាផ្លូវចិត្ត | ▪ ការមិនយកចិត្តទុកដាក់ និងឱ្យអង្គុយនៅខាងក្រោយ<br>▪ ការស្តីបន្ទោស ជេរប្រមាថ គំរាមកំហែង សម្លុត ដាក់ងារ រើសអើង ចំអក ប្រៀបធៀបជាមួយសិស្សដទៃ<br>▪ ការធ្វើទុក្ខបុកម្នេញ ដោយសារតែភេទ ឬអត្តសញ្ញាណយេនឌ័ររបស់សិស្សពីមិត្តភក្តិរបស់ពួកគេ ឬមនុស្សធំ<br>▪ ការរើសអើងចំពោះកុមារដែលមានស្ថានភាពគ្រួសារមិនល្អ មានពិការភាព មិនសូវឆ្លាត និងនិយាយច្រើន<br>▪ ការសម្លុតគំរាមកំហែងរវាងសិស្ស និងសិស្ស | ▪ នៅតែឯង មិននិយាយជាមួយអ្នកណា<br>▪ ចាប់ផ្តើមរៀនខ្សោយជាងមុន<br>▪ មិនសូវនិយាយស្តី ឬនិយាយពាក្យមិនសមរម្យ<br>▪ មិនមានទំនុកចិត្តលើខ្លួនឯង និងមានអារម្មណ៍សោកសៅ<br>▪ ចាប់ផ្តើមមកសាលារៀនលឿន ឬចេញពីសាលារៀនវិញយឺត (កុមារមិនចង់នៅផ្ទះ)<br>▪ មករៀនយឺត ឬអវត្តមានច្រើន (កុមារមិនចង់ទៅសាលារៀន) |
| អំពើហិង្សាផ្លូវភេទ | ▪ ការប៉ះពាល់កន្លែងឯកជន ឬប៉ះពាល់មិនសមរម្យលើកុមារ រំលោភផ្លូវភេទលើកុមារ ការរៀបការជាមួយកុមារក្រោមអាយុ១៨ឆ្នាំ<br>▪ ការថតរូបកុមារដែលមិនបានស្លៀកពាក់សមរម្យ ឬអាក្រាត និងបង្ហោះក្នុងប្រព័ន្ធអនឡាញ<br>▪ ការបៀតបៀន ឬស្ទាបអង្អែលកេរខ្មាស ឬប្រើប្រាស់ឱសថ គ្រឿងញៀនធ្វើឱ្យមានសម្រើប<br>▪ ការបង្ហាញកន្លែងកេរខ្មាស ឬប្រដាប់ភេទ ឬរូបភាពអាសអាភាសនាំឱ្យមានអារម្មណ៍ផ្លូវភេទ | ▪ ស្លៀកពាក់ខោអាវច្រើនជាន់ និងជិត<br>▪ មានអាការៈឈឺពោះនៅពេលអង្គុយ ឬដើរ ឬមានភាពស្លេកស្លាំង<br>▪ មានអាការៈដូចស្ត្រីមានផ្ទៃពោះ<br>▪ មិនហ៊ានចេញក្រៅផ្ទះ ឬទៅធ្វើកិច្ចការអ្វីមួយឆ្ងាយពីផ្ទះ<br>▪ មានអាកប្បកិរិយាខ្លាច អៀន និងនិយាយជាមួយមិត្តភក្តិប្រុស ឬគ្រូបង្រៀនប្រុស<br>▪ មានគំនិតចង់ធ្វើបាបខ្លួនឯង ឬសម្លាប់ខ្លួន<br>▪ មិនមានអារម្មណ៍ ឬយកចិត្តទុកដាក់រៀនសូត្រ |
| ការមិនអើពើ ឬការមិនយកចិត្តទុកដាក់ | ▪ ទុកកុមារចោល មិនយកចិត្តទុកដាក់ចំពោះកុមារ<br>▪ មិនផ្តល់ចំណីអាហារ (ការហូបចុកមិនគ្រប់គ្រាន់)<br>▪ មិននាំកុមារទៅពេទ្យ | ▪ កុមារឈឺ<br>▪ កុមារស្លេកស្លាំង<br>▪ កុមារមិនមានសម្លៀកបំពាក់គ្រប់គ្រាន់<br>▪ កុមារស្ងៀមស្ងាត់ មិនចង់ចូលរួមជាមួយអ្នកដទៃ |

| | | |
|---|---|---|
| | ▪ មិនមើលថែទាំកុមារពេលកុមារត្រូវការ<br>▪ មិនស្តាប់កុមារ ពេលគាត់និយាយ ឬប្រាប់រឿងរ៉ាវរបស់គាត់<br>▪ មិនខ្វល់ខ្វាយជាមួយកុមារ ពេលគាត់ត្រូវការការជួយផ្សេងៗ | |
| ការកេងប្រវ័ញ្ចគ្រប់ទម្រង់ (កេងប្រវ័ញ្ចកម្លាំងពលកម្ម កេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងការកេងប្រវ័ញ្ចផ្លូវភេទ) | ▪ ការប្រើប្រាស់កុមារឱ្យទៅធ្វើការងាររបស់ខ្លួនដោយមិនបានសម្រាក ឬចូលរៀន ឬមានហានិភ័យខ្ពស់ដល់កុមារ<br>▪ ការប្រើឱ្យកុមារលក់ទំនិញឱ្យខ្លួននៅក្នុង ឬក្រៅសាលារៀន<br>▪ ការប្រើកុមារទៅទិញ ឬប្រើប្រាស់គ្រឿងស្រវឹង ឬសារជាតិញៀនដទៃទៀត<br>▪ ការប្រើកុមារប្រព្រឹត្តអំពើពេស្យាចារ ការថតរូប ឬវីដេអូអាក្រាត ឬអាសអាភាសរបស់កុមារ និងការជួញដូរកុមារសម្រាប់បម្រើសកម្មភាពផ្លូវភេទ | ▪ មិនចង់នៅផ្ទះ ឬមិនហ៊ានទៅសាលារៀន<br>▪ មិនខ្វល់ខ្វាយក្នុងការទំនាក់ទំនងជាមួយឪពុកម្តាយ អ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ ឬមិត្តភក្តិ<br>▪ មានប្រាក់ចាយច្រើនជាងមុន និងហ៊ឺហា<br>▪ មានអាការៈស្លេកស្លាំង<br>▪ ខ្លាចក្នុងការទំនាក់ទំនងជាមួយគ្រូបង្រៀន<br>▪ ការសិក្សាធ្លាក់ចុះ |

## *ក.២. តួនាទីរបស់នាយក/នាយិកាសាលា និងគ្រូបង្រៀន*

❖ **នាយក/នាយិកាសាលា**

- ធ្វើការសិក្សាអំពីហានិភ័យនៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ដែលអាចកើតមានក្នុងបរិបទ អប់រំ និងធ្វើការកាត់បន្ថយជាប្រចាំ (យ៉ាងហោចណាស់១ឆ្នាំម្តង ដើម្បីបញ្ចូលសកម្មភាពកាត់បន្ថយទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន)។ *សូមមើលឧបសម្ព័ន្ធទី៥ ៖ ទម្រង់សិក្សា និងកាត់បន្ថយហានិភ័យកិច្ចការពារកុមារ (ទំព័រទី៥៤)*
- ដឹកនាំ និងកំណត់ទីតាំងដែលមានសុវត្ថិភាព កន្លែងមិនមានសុវត្ថិភាពសម្រាប់កុមារពីហានិភ័យនៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងកន្លែងផ្តល់ជំនួយសម្រាប់កុមារនៅក្នុងសាលារៀន និងដាក់សញ្ញាណែនាំ ឬផ្សព្វផ្សាយដល់សិស្សានុសិស្សជាប្រចាំ។

❖ **គ្រូបង្រៀន**

- ធ្វើការសិក្សាអំពីហានិភ័យនៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ព្រមទាំងកាត់បន្ថយនៅគ្រប់ពេលវេលា

- រៀបចំសកម្មភាពជាមួយកុមារនៅក្នុងសាលារៀន ដើម្បីកំណត់ទីតាំងដែលមានសុវត្ថិភាព និង មិនមានសុវត្ថិភាពសម្រាប់កុមារ និងផ្សព្វផ្សាយអំពីសិទ្ធិកុមារដើម្បីឱ្យពួកគេទទួលបានកិច្ចការពារពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់
- ធ្វើការអង្កេតជាប្រចាំនូវអាកប្បកិរិយា និងឥរិយាបថរបស់សិស្សានុសិស្ស បើមានការប្រែប្រួល ឬប្លែក ត្រូវរាយការណ៍ទៅជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ឬនាយក/នាយិកាសាលា។

## *១. ការតម្រង់ទិស និងផ្សព្វផ្សាយអំពីកិច្ចការពារកុមារដល់បុគ្គលិកអប់រំ គ្រូបង្រៀន អ្នកអាណាព្យាបាល អ្នកស្ម័គ្រចិត្តរបស់សាលារៀន និងសហគមន៍*

### *១.១. ប្រធានបទសម្រាប់ការតម្រង់ទិស និងផ្សព្វផ្សាយ*

- អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ រួមទាំងអំពើហិង្សាតាមអនឡាញ វិធីទប់ស្កាត់ និងវិធីកាត់បន្ថយ
- ប្រព័ន្ធការពារកុមារ ការកំណត់នូវករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- ការដាក់វិន័យតាមបែបវិជ្ជមាន
- ការចូលរួមរបស់កុមារប្រកបដោយសុវត្ថិភាព សមភាពយេនឌ័រ ការអប់រំជាបរិយាបន្ននៅក្នុងកិច្ចការពារកុមារ និងឥរិយាបថល្អរបស់កុមារចំពោះកុមារ
- បញ្ជីបច្ចុប្បន្នភាពនៃលេខទូរស័ព្ទជំនួយ សេវាគាំទ្រនានា និងការកំណត់ពីកុមារដែលប្រឈមនឹងហានិភ័យ
- របៀបដោះស្រាយ និងបញ្ជូនកុមារប្រកបដោយសុវត្ថិភាព ក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវ

សម្គាល់៖ ប្រធានបទមួយចំនួនខាងលើអាចស្វែងរកបាននៅក្នុងសៀវភៅណែនាំសម្រាប់គ្រូស្ដីពីការដាក់វិន័យតាមបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ឬឯកសារអំពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារពីអ្នកពាក់ព័ន្ធនានា។

### *១.២. តួនាទីរបស់នាយក/នាយិកាសាលា និងគ្រូបង្រៀន*

❖ **នាយក/នាយិកាសាលា**

- រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធ ជារៀងរាល់ឆ្នាំ ដោយដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិរបស់សាលារៀន
- សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (គ.ក.ន.ក.) និងអង្គការសង្គមស៊ីវិល ដើម្បីផ្ដល់នូវជំនាញ និងឯកសារបច្ចេកទេស(មេរៀន) សម្រាប់ធ្វើ

ការតម្រង់ទិសឱ្យបានទៀងទាត់ ដោយប្រើរយៈពេលខ្លីៗនៅពេលវិស្សមកាលពាក់កណ្ដាលឆ្នាំ និងចុងឆ្នាំដល់គ្រូបង្រៀន និងសមាជិកគណៈកម្មការទាំងអស់របស់សាលារៀន

- ធ្វើការផ្សព្វផ្សាយ បញ្ជ្រាប អប់រំ តម្រង់ទិសពីហានិភ័យ ឬទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ វិធីបង្ការ និងឆ្លើយតបនៅក្នុងកិច្ចប្រជុំទៀងទាត់ជាមួយគ្រូ គណៈកម្មការសុខភាពសិក្សា និងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងថ្នាក់រៀន ក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី ដោយផ្អែកលើសៀវភៅមេរៀនដែលមានស្រាប់ពាក់ព័ន្ធនឹងកិច្ចការពារកុមាររបស់ក្រសួង និងអង្គការដៃគូនានា។

❖ **គ្រូបង្រៀន**

- ចូលរួមផ្សព្វផ្សាយដល់សិស្សានុសិស្ស ឪពុកម្ដាយ និងអ្នកអាណាព្យាបាលស្ដីពីហានិភ័យ និងទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ វិធីបង្ការ និងឆ្លើយតបបញ្ហាកិច្ចការពារកុមារជាប្រចាំនៅក្នុងពេលយុទ្ធនាការចុះឈ្មោះចូលរៀន និងថ្ងៃបើកបវេសនកាលឆ្នាំថ្មី
- ចូលរួមធ្វើការជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (អ.ក.ន.ក.) ក្នុងការផ្សព្វផ្សាយអំពីការជួយកូនឱ្យរៀនសូត្រ និងការពារកូនពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ នៅពេលប្រជុំជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ឬចុះទៅជួបជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្សដល់ផ្ទះ។

## *គ. ការបណ្ដុះបណ្ដាលដល់សិស្សានុសិស្សអំពីកិច្ចការពារខ្លួនពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ*

### *គ.១. ប្រធានបទ និងគោលការណ៍សម្រាប់រៀបចំការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយដល់សិស្សានុសិស្ស*

| ប្រធានបទ | គោលការណ៍ |
|---|---|
| ▪ សិទ្ធិកុមារ និងការអនុវត្តសិទ្ធិរបស់ពួកគេ<br>▪ ការកំណត់នូវទម្រង់ ឬហានិភ័យនៃអំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ និងការសម្លុតធ្វើបាបគ្នា ទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញ<br>▪ ទម្រង់នៃការប៉ះពាល់រាងកាយដែលត្រឹមត្រូវ និងមិនត្រឹមត្រូវ<br>▪ ការកំណត់កន្លែងគ្រោះថ្នាក់ និងកន្លែងសុវត្ថិភាពសម្រាប់កុមារ | ▪ បែបសាលាកុមារមេត្រី និងមានការចូលរួម<br>▪ បរិយាកាស និងទីកន្លែងមានសុវត្ថិភាព និងផាសុកភាព<br>▪ មានភាពសមស្រប និងទទួលយកបានដល់កុមារដែលងាយរងគ្រោះ ដូចជា កុមារី កុមារមានពិការភាព កុមារមិនកំណត់អត្តសញ្ញាណភេទ កុមារដែលធ្លាប់រងគ្រោះពីអំពើហិង្សា និងការកេងប្រវ័ញ្ច និងកុមារជនជាតិដើមភាគតិច |

| | |
|---|---|
| ▪ ឥរិយាបថល្អៗរបស់កុមារចំពោះមិត្តភក្តិ គ្រូបង្រៀន និងចាស់ព្រឹទ្ធាចារ្យ ដោយមិនមានការរើសអើង<br>▪ វិធីសាស្ត្រដោះស្រាយបញ្ហាដោយសន្តិវិធី និងសុវត្ថិភាព<br>▪ វិធីរាយការណ៍ និងស្វែងរកជំនួយប្រកបដោយសុវត្ថិភាព<br>▪ ការចូលរួមរបស់កុមារក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងសារសំខាន់នៃក្រុមប្រឹក្សាកុមារ<br>▪ ការដឹកនាំ និងសម្របសម្រួលក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី និងសកម្មភាពផ្សព្វផ្សាយបន្ត<br>▪ របៀបរៀបចំផែនការ និងវិធីសម្របសម្រួល។ | ▪ ពេលវេលាមិនប៉ះពាល់ដល់ការសិក្សា និងការងារសំខាន់ដទៃទៀតរបស់កុមារ<br>▪ មតិយោបល់ និងការព្រួយបារម្ភរបស់កុមារត្រូវយកមកឆ្លុះបញ្ចាំង និងកែលម្អសម្រាប់សកម្មភាពពេលក្រោយ។ |

## គ.២. តួនាទីរបស់នាយក/នាយិកាសាលា និងគ្រូបង្រៀន

### ❖ នាយក/នាយិកាសាលា

- រៀបចំផែនការច្បាស់លាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់កុមារ និងសិស្សានុសិស្ស
- តម្រង់ទិស និងជួយគាំទ្រដល់គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការថ្នាក់រៀនទាំងអស់ក្នុងការអនុវត្តផែនការនេះ
- រៀបចំការផ្សព្វផ្សាយជាទ្រង់ទ្រាយធំនៅពេលជួបជុំសិស្សានុសិស្សទាំងអស់ ដូចជា ពេលគោរពទង់ជាតិ មតិផ្តាំផ្ញើចុងម៉ោងសិក្សា និងការបើកបវេសនកាលឆ្នាំសិក្សាថ្មី ។ល។ ចំពោះប្រធានបទណាដែលខ្លួនពុំទាន់មានសមត្ថភាព ត្រូវសហការ និងស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋាន ឬអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ដើម្បីរៀបចំការផ្សព្វផ្សាយនោះ
- ស្វែងរក ឬផលិតសម្ភារៈសម្រាប់អប់រំផ្សព្វផ្សាយអំពីហានិភ័យនៃអំពើហិង្សា និងកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ យន្តការរាយការណ៍ និងវិធីការពារដល់សិស្សានុសិស្ស គណៈកម្មការនានា ឪពុកម្តាយ និងអ្នកអាណាព្យាបាល ព្រមទាំងបិទផ្សាយនៅតាមថ្នាក់រៀន និងក្តារខៀនព័ត៌មាននូវសារសំខាន់ៗ ខិត្តប័ណ្ណ ឬផ្ទាំងរូបភាពពាក់ព័ន្ធផ្សេងៗ។

### ❖ គ្រូបង្រៀន

- បណ្តុះបណ្តាលរយៈពេលខ្លីដល់សិស្សានុសិស្សអំពីការអប់រំបែបកុមារមេត្រីជាប្រចាំយ៉ាងតិច ១ដងក្នុង១ឆ្នាំនៅពេលចាប់ផ្តើមបវេសនកាលឆ្នាំសិក្សាថ្មី
- ដាក់បញ្ចូលប្រធានបទអប់រំផ្សព្វផ្សាយពាក់ព័ន្ធនឹងសិទ្ធិកុមារ កិច្ចការពារកុមារ ឥរិយាបថល្អរបស់កុមារទៅក្នុងកិច្ចតែងការបង្រៀនរបស់ខ្លួន ជាពិសេសនៅមុន ឬក្រោយមេរៀនស្នូលប្រចាំថ្ងៃ

- សម្របសម្រួល និងគាំទ្រដល់ក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី ចុះអប់រំផ្សព្វផ្សាយបន្តដល់សិស្សានុសិស្សដទៃទៀត។

## ៣.៣. ការលើកកម្ពស់ការបង្រៀន និងទំនាក់ទំនងវិជ្ជមានរវាងគ្រូបង្រៀន និងសិស្សានុសិស្ស

ការលើកកម្ពស់ការបង្រៀន និងទំនាក់ទំនងវិជ្ជមានរវាងគ្រូបង្រៀន និងសិស្សានុសិស្ស គឺជាសកម្មភាពដែលជួយកាត់បន្ថយអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀនស្របតាមសៀវភៅណែនាំស្តីពីការដាក់វិន័យតាមបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩។ វិន័យបែបវិជ្ជមានសំដៅលើការណែនាំអំពីអាកប្បកិរិយាកុមារ ដោយផ្តោតលើការអភិវឌ្ឍរបស់កុមារ។ តាមរយៈការធ្វើជាគំរូការប្រៀនប្រដៅ និងការផ្តល់នូវការណែនាំច្បាស់លាស់អំពីអាកប្បកិរិយាដែលអាចទទួលយកបាន វិន័យបែបវិជ្ជមានមានគោលដៅកសាងជំនាញ និងប្រព័ន្ធគុណតម្លៃរបស់កុមារដែលនឹងលើកទឹកចិត្តដល់ពួកគេឱ្យបង្កើតអាកប្បកិរិយាវិជ្ជមាន ការគោរព និងឱ្យតម្លៃចំពោះខ្លួនឯង និងមានចរិតរឹងមាំ។ នាយក/នាយិកាសាលា និងគ្រូបង្រៀនមានតួនាទី ភារកិច្ចក្នុងការអនុវត្តវិធីបង្ការនេះ ទៅតាមការណែនាំដូចខាងក្រោម៖

❖ **តួនាទីរបស់នាយក/នាយិកាសាលា**

- រៀបចំ និងអនុវត្តផែនការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន និងជំរុញការអនុវត្តវិធីសាស្ត្រដាក់វិន័យតាមបែបវិជ្ជមាន ការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាព យន្តការបង្ការ រាយការណ៍ និងឆ្លើយតបរបស់សាលារៀន
- ធ្វើជាគំរូល្អក្នុងការទំនាក់ទំនងជាមួយសិស្សានុសិស្ស និងផ្តល់លទ្ធភាពចូលរួម និងធ្វើការសម្រេចចិត្តនានានៅក្នុងសាលារៀនដល់សិស្សានុសិស្ស ព្រមទាំងឆ្លើយតបជាវិជ្ជមាននូវរាល់មតិយោបល់ និងសំណូមពររបស់ពួកគេ
- ទំនាក់ទំនងល្អជាមួយសិស្សានុសិស្សទាំងអស់ដោយស្មើភាព ជាពិសេសសិស្សមានពិការភាព និងសិស្សរៀនយឺត ដើម្បីលើកទឹកចិត្តឱ្យពួកគេខិតខំរៀនសូត្រ និងចូលរួមសកម្មភាពនានានៅក្នុងសាលារៀន
- ធ្វើការត្រួតពិនិត្យតាមដានការបង្រៀន និងសកម្មភាពរបស់គ្រូជាមួយសិស្សានុសិស្សនៅក្នុងថ្នាក់រៀនជាប្រចាំ បើមានលទ្ធភាពមានបំពាក់នូវកាមេរ៉ាសុវត្ថិភាពនៅតាមថ្នាក់រៀននីមួយៗ
- រៀបចំផែនការប្រចាំឆ្នាំរបស់បុគ្គលិកសាលារៀន និងគ្រូបង្រៀន និងមានគណៈកម្មការវាយតម្លៃការប្រតិបត្តិទៅតាមផែនការដែលបានបង្កើត
- រៀបចំការប្រមូលមតិយោបល់ ឬទទួលព័ត៌មានត្រឡប់ពីសិស្សានុសិស្សតាមរយៈប្រអប់សំបុត្រ កិច្ចពិភាក្សាជាមួយសិស្សានុសិស្សជាប្រចាំ ឬកិច្ចប្រជុំក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី និងគណៈកម្មការគ្រប់គ្រងសាលារៀនឱ្យបានទៀងទាត់។

❖ **តួនាទីរបស់គ្រូបង្រៀន**

- ប្រើប្រាស់វិធីបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល ស្របតាមគោលនយោបាយសាលាកុមារមេត្រីតាមរយៈបង្កើតនូវបរិយាកាសដែលផ្តល់នូវភាពកក់ក្តៅ និងមានសុវត្ថិភាពដល់កុមារក្នុងសាលារៀន និងក្នុងថ្នាក់រៀន
- ផ្តល់ភាពកក់ក្តៅ និងការណែនាំបែបវិជ្ជមាន រួមទាំងមានអាកប្បកិរិយា និងឥរិយាបថជាគំរូ ដើម្បីធានាបាននូវសារប្រយោជន៍ដល់ការសិក្សា និងកិច្ចការពារដល់សិស្សានុសិស្ស
- ធ្វើការទំនាក់ទំនងជាមួយសិស្សានុសិស្សនីមួយៗដោយស្មើភាព និងមានការគោរព ដោយមិនគិតពីភេទ មានពិការភាព ជនជាតិ ភាពងាយរងគ្រោះរបស់សិស្សឡើយ ព្រមទាំងជំរុញការអភិវឌ្ឍផ្នែករាងកាយ បញ្ញា ស្មារតី ការទំនាក់ទំនង និងសកម្មភាពសង្គមនានា
- បង្កើតការទំនាក់ទំនងបែបវិជ្ជមាន និងមានសមភាពយេនឌ័រ ដែលមិនបង្កការវាយ ឬធ្វើបាបលើរាងកាយ ការរំលោភបំពានផ្លូវចិត្ត ឬគំរាមកំហែងកុមារ មិនមានទំនាក់ទំនងផ្លូវកាយ ឬផ្លូវភេទជាមួយកុមារ
- លើកគំនិតយោបល់ ឬផ្តល់ជំបូន្មានអ្វីមួយដល់កុមារ ដោយផ្តោតលើបទពិសោធន៍ និងបង្ហាញអារម្មណ៍ល្អដល់សិស្សានុសិស្ស
- ស្តាប់នូវមតិយោបល់របស់កុមារ និងពិភាក្សាឆ្លើយតប ឬអនុវត្តតាមគំនិត និងតម្រូវការទាំងនោះ
- ទំនាក់ទំនងល្អ និងដោយបើកចំហ ក្នុងន័យបង្កើតនូវទំនុកចិត្តរវាងគ្រូ និងសិស្សានុសិស្ស ដោយមិននៅជាមួយសិស្សានុសិស្សតែពីរនាក់នៅកន្លែងស្ងាត់ ឬកន្លែងដែលពុំមានអ្នកណាឃើញ និងមិនធ្វើទំនាក់ទំនងជាមួយសិស្សានុសិស្សតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម និងអនឡាញជាលក្ខណៈឯកជន ដូចជា ហ្វេសប៊ុក តេឡេក្រាម ឡាញ យូធូប វីឆាត ទីកតុក ហ្ស៊ូម ។ល។
- ធ្វើការទំនាក់ទំនង និងចែករំលែកព័ត៌មានដែលសមស្រប ដោយមិនប្រើប្រាស់រូបភាពសិស្សានុសិស្សដាក់លើអេក្រង់ទូរស័ព្ទ កុំព្យូទ័រ ឬលើឧបករណ៍អេឡិចត្រូនិកផ្ទាល់ខ្លួន ដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសិស្សានុសិស្ស ឪពុកម្តាយ និងអ្នកអាណាព្យាបាល ព្រមទាំងមិនផ្តល់ព័ត៌មានទំនាក់ទំនងផ្ទាល់ខ្លួន (ដូចជាលេខទូរស័ព្ទ ឬអ៊ីមែល) ជាពិសេសដល់សិស្សានុសិស្សណាម្នាក់ដែលខ្លួនចាប់អារម្មណ៍ ដែលមិនមែនជាលក្ខណៈទូទៅសម្រាប់សិស្សានុសិស្សទាំងអស់
- រិះរកវិធីសាស្ត្របង្រៀនបែបច្នៃប្រឌិត និងទាក់ទាញ និងណែនាំសិស្សានុសិស្សឱ្យចេះស្វ័យវិន័យ មានការសម្រេចចិត្តត្រឹមត្រូវ និងអនុវត្តបទបញ្ជាផ្ទៃក្នុងសាលារៀនដោយពេញចិត្ត។

### ៣.៤. ការលើកកម្ពស់ការចូលរួមរបស់កុមារប្រកបដោយសុវត្ថិភាពនៅក្នុងសាលារៀន

ការចូលរួម គឺជាសិទ្ធិដ៏ចម្បងមួយរបស់កុមារ ដែលកុមារមានសិទ្ធិចូលរួមរាល់សកម្មភាពឬការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ការរស់នៅ និងសុខុមាលភាពរបស់ពួកគេ រួមទាំងការចូលរួម និង

ដឹកនាំសកម្មភាពបង្ការអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ដែលអាចកើតឡើងលើពួកគេ និងមិត្តភក្តិរបស់ពួកគេ។ ដើម្បីជួយ និងសម្របសម្រួលដល់ការចូលរួមសកម្មភាពនានា ការចូលរួមបញ្ចេញទស្សនៈ ការធ្វើសេចក្តីសម្រេចចិត្ត និងការដឹកនាំសកម្មភាពរបស់កុមារប្រកបដោយសុវត្ថិភាពនៅក្នុងសាលារៀន និងស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារនៅឆ្នាំ២០១៤ សាលារៀនត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- កុមារត្រូវចូលរួមសកម្មភាពដោយស្ម័គ្រចិត្ត និងមិនប៉ះពាល់អវិជ្ជមានដល់ការសិក្សារបស់ពួកគេ
- កុមារត្រូវទទួលបាននូវព័ត៌មានគ្រប់គ្រាន់ជាមុន ឬនៅពេលចាប់ផ្តើមសកម្មភាព ដឹង និងយល់អំពីសកម្មភាពទាំងនោះ រួមទាំងហានិភ័យដែលអាចកើតមានចំពោះពួកគេនៅពេលចូលរួមសកម្មភាព
- រាល់សកម្មភាពដែលកុមារនឹងចូលរួមត្រូវតែផ្តល់នូវឧត្តមប្រយោជន៍ដល់កុមារ ជាពិសេសការសិក្សារបស់ពួកគេ
- កុមារដែលចូលរួមត្រូវទទួលបានកិច្ចការពារនៅគ្រប់ដំណាក់កាលទាំងអស់នៃសកម្មភាព
- កុមារត្រូវបានជ្រើសរើសដោយស្មើភាព និងគ្មានការរើសអើង ជាពិសេសផ្តល់ឱកាសដល់កុមារី កុមារមានពិការភាព កុមាររៀនយឺត ឬខ្សោយ និងកុមារងាយរងគ្រោះដទៃទៀតឱ្យបានចូលរួមសកម្មភាព
- អ្នកសម្របសម្រួល ឬអ្នកនាំកុមារទៅចូលរួមត្រូវមានជំនាញច្បាស់លាស់ពីការសម្របសម្រួល ឬទំនាក់ទំនងជាមួយកុមារ ការឆ្លើយតបការព្រួយបារម្ភរបស់កុមារ និងជួយគាំទ្រដល់កុមារគ្រប់ពេលវេលា។

ដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារ នាយក/នាយិកាសាលា និងគ្រូបង្រៀនត្រូវមានតួនាទី ភារកិច្ចដូចខាងក្រោម៖

❖ **តួនាទីរបស់នាយក/នាយិកាសាលា**

- ចាត់តាំងគ្រូបង្រៀន ឬបុគ្គលិកអប់រំដែលមានចំណេះដឹង ជំនាញ បទពិសោធន៍លើកិច្ចការពារកុមារ និងមានឥរិយាបថល្អជាមួយកុមារ ក្នុងការដឹកនាំ និងរៀបចំការចូលរួមរបស់កុមារ
- ត្រួតពិនិត្យលើឯកសារពាក់ព័ន្ធ និងបញ្ជីឈ្មោះកុមារដែលចូលរួមដើម្បីធានា និងស្របតាមគោលការណ៍នៃការអនុវត្តការចូលរួមរបស់កុមារខាងលើ។

❖ **តួនាទីរបស់គ្រូបង្រៀន ឬបុគ្គលិកសាលារៀន**

គ្រូបង្រៀន ឬបុគ្គលិកសាលារៀនដែលត្រូវទទួលបន្ទុក ត្រូវរៀបចំសកម្មភាពដូចខាងក្រោម៖

## *ក. សកម្មភាពរៀបចំនៅក្នុងសាលារៀន*

## *ក.១. ដំណាក់កាលមុនចូលរួមសកម្មភាព*

- បង្ហាញដល់កុមារអំពីគោលបំណងនៃសកម្មភាពច្បាស់លាស់ និងភាពចាំបាច់នៃការចូលរួមរបស់កុមារ ព្រមទាំងរៀបចំការជ្រើសរើសប្រកបដោយសមធម៌ដែលមានលក្ខណៈវិនិច្ឆ័យ

ជ្រើសរើសប្រកបដោយបរិយាបន្ន សម្រាប់លើកទឹកចិត្តដល់កុមារី កុមារមានពិការភាព និងកុមារងាយរងគ្រោះ (កុមារអាចធ្វើការជ្រើសរើសកុមារជាអ្នកតំណាងពួកគេដោយខ្លួនឯង គ្រូបង្រៀន គឺជាអ្នកជួយសម្របសម្រួល)

- ធ្វើការសិក្សាអំពីហានិភ័យដែលអាចកើតឡើងចំពោះកុមារ ព្រមទាំងសកម្មភាពឆ្លើយតបទៅតាមទម្រង់នៅក្នុងឧបសម្ព័ន្ធទី៥
- ធ្វើការណែនាំអំពីក្រមសីលធម៌ និងគោលការណ៍ស្តីពីកិច្ចការពារកុមារដល់អ្នករៀបចំ និងកុមារ។

### *ក.២. ដំណាក់កាលអំឡុងពេលចូលរួមសកម្មភាព*

- រៀបចំទីកន្លែងអង្គុយដែលអាចមើលឃើញ វិធីសាស្ត្រសម្របសម្រួលបែបកុមារមេត្រី និងភាសាដែលប្រើប្រាស់សមស្របតាមស្ថានភាពជាក់ស្តែងរបស់កុមារដែលចូលរួម ដូចជា កុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច កុមាររៀនយឺត និងកុមារងាយរងគ្រោះ ដើម្បីជួយពួកគេបានចូលរួមពេញលេញ
- ណែនាំ បង្រៀន និងពិភាក្សាអំពីកិច្ចការពារខ្លួនឯង យន្តការរាយការណ៍ និងបទបញ្ញាផ្ទៃក្នុងនៃសកម្មភាពនោះ
- ដោះស្រាយភ្លាមៗ និងប្រកបដោយវិជ្ជមាននូវរាល់បញ្ហាដែលកើតឡើងចំពោះកុមារ និងតម្រូវការរបស់កុមារដែលបានស្នើឡើង។

### *ក.៣. ដំណាក់កាលពេលសកម្មភាពបានបញ្ចប់*

- ផ្តល់ព័ត៌មាន ឬរបាយការណ៍អំពីលទ្ធផលនៃសកម្មភាពដល់កុមារ នៅពេលចុងបញ្ចប់ ឬក្រោយពេលបញ្ចប់សកម្មភាព។

## *ខ. សកម្មភាពរៀបចំនៅខាងក្រៅសាលារៀន*

### *ខ.១. ដំណាក់កាលមុនចូលរួមសកម្មភាព*

- បង្ហាញអំពីគោលបំណងនៃសកម្មភាពឱ្យបានច្បាស់លាស់ និងភាពចាំបាច់នៃការចូលរួមរបស់កុមារ និងភាពសមស្របដល់កុមារា កុមារី ដូចជា ទីកន្លែង ពេលវេលា ឬវិធីសាស្ត្រនៃការសម្របសម្រួលសកម្មភាព
- ចែករំលែកព័ត៌មានចាំបាច់ដល់កុមារគ្រប់រូប រៀបចំការជ្រើសរើសប្រកបដោយសមធម៌ មានលក្ខណៈវិនិច្ឆ័យ ជ្រើសរើសប្រកបដោយបរិយាបន្នសម្រាប់លើកទឹកចិត្តដល់កុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមារងាយរងគ្រោះ (កុមារអាចជ្រើសរើសគ្នាគេដោយខ្លួនឯង គ្រូបង្រៀន មានតួនាទីជួយសម្របសម្រួលតែប៉ុណ្ណោះ)
- ស្នើសុំការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារ ព្រមទាំងផ្តល់ដំណឹងជូនអាជ្ញាធរមូលដ្ឋាន។ *សូមមើលឧបសម្ព័ន្ធទី ៦ ៖ ទម្រង់នៃការយល់ព្រមឯកភាពពីកុមារ ឪពុកម្តាយ និងអ្នកអាណាព្យាបាល (ទំព័រទី៥៥)*

- ធ្វើការសិក្សាអំពីហានិភ័យដែលអាចកើតឡើងចំពោះកុមារ ព្រមទាំងសកម្មភាពឆ្លើយតបទៅតាមទម្រង់នៅក្នុងឧបសម្ព័ន្ធទី៥
- ជ្រើសរើសអ្នកមើលថែ ឬអ្នកនាំកុមារទៅចូលរួមសកម្មភាពដែលមានជំនាញ ចំណេះដឹង និងឆន្ទៈក្នុងការគាំទ្រដល់កុមារ ព្រមទាំងណែនាំដល់ពួកគេអំពីគោលការណ៍ស្ដីពីកិច្ចការពារកុមារ។ *សូមមើលឧបសម្ព័ន្ធទី ៧ ៖ ទម្រង់នៃការយល់ព្រមពីអ្នកមើលថែកុមារ ( ទំព័រទី៥៦)*
- ជ្រើសរើសដោយប្រុងប្រយ័ត្ននូវមធ្យោបាយធ្វើដំណើរ កន្លែងស្នាក់នៅ និងអាហារដែលមានសុវត្ថិភាពដល់កុមារ
- ត្រូវពិភាក្សាជាមួយអ្នករៀបចំកម្មវិធី លើការធានារ៉ាប់រងសម្រាប់កុមារពេលចូលរួមសកម្មភាព។

## *ខ.២. ដំណាក់កាលអំឡុងពេលចូលរួមសកម្មភាព*

- ស្នើសុំដល់អ្នករៀបចំកម្មវិធី អំពីការរៀបចំទីកន្លែងអង្គុយដែលអាចមើលឃើញ វិធីសាស្ត្រសម្របសម្រួល បែបកុមារមេត្រី និងភាសាដែលប្រើប្រាស់ស្របតាមស្ថានភាពជាក់ស្ដែងរបស់កុមារដែលចូលរួម ជាពិសេសកុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមារងាយរងគ្រោះឱ្យបានចូលរួមពេញលេញ
- ស្នើសុំព័ត៌មាន ឬឱ្យមានការបង្ហាញ ណែនាំ និងពិភាក្សាអំពីកិច្ចការពារខ្លួនឯង យន្តការរាយការណ៍ និងបទបញ្ជាផ្ទៃក្នុងនៃសកម្មភាពនោះ
- ស្នើសុំបង្កើតយន្តការស្ដីពីការផ្ដល់មតិយោបល់ ឬក្ដីបារម្ភសម្រាប់អ្នកចូលរួមជាកុមារ
- ជួយកុមារក្នុងការទំនាក់ទំនងជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់ពួកគេនៅពេលមានការស្នើសុំ ឬក្នុងករណីចាំបាច់
- ធ្វើការជាមួយអ្នករៀបចំកម្មវិធីក្នុងការដោះស្រាយភ្លាមៗ និងប្រកបដោយវិជ្ជមាននូវរាល់បញ្ហាដែលកើតឡើងចំពោះកុមារ និងតម្រូវការរបស់កុមារដែលបានស្នើឡើង ព្រមទាំងបង្កើតជានីតិវិធីសម្រាប់ថតរូប ការដកស្រង់សំដី ឬករណីសិក្សារបស់កុមារណាម្នាក់សម្រាប់សកម្មភាពនោះ។

## *ខ.៣. ដំណាក់កាលពេលសកម្មភាពបានបញ្ចប់*

- ផ្ដល់ដំណឹងជាមុនដល់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលពីការវិលត្រឡប់របស់កុមារ
- ប្រគល់ដោយផ្ទាល់ឱ្យឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ហើយត្រូវទំនាក់ទំនងទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាលដើម្បីបញ្ជាក់ថាកុមារបានទៅដល់ផ្ទះដោយសុវត្ថិភាព
- ទាក់ទងអ្នករៀបចំកម្មវិធីដើម្បីស្នើសុំព័ត៌មាន ឬរបាយការណ៍អំពីលទ្ធផលនៃសកម្មភាពសម្រាប់ចែករំលែកទៅកុមារដែលបានចូលរួមសកម្មភាព។

## ៣.៥. ការគ្រប់គ្រងភ្ញៀវ និងអ្នកមកទស្សនកិច្ចសាលារៀន

ភ្ញៀវ និងអ្នកមកទស្សនកិច្ច គឺជាបុគ្គលដែលមកកាន់សាលារៀន ក្នុងគោលបំណងជាក់លាក់ណាមួយ អាចជាសាច់ញាតិ អ្នកម៉ៅការ សប្បុរសជនជាតិ និងអន្តរជាតិ មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការសង្គមស៊ីវិល

អ្នកសិក្សាស្រាវជ្រាវ តំណាងស្ថាប័ននានា អ្នកមានបំណងស្វែងរកការងារជាបុគ្គលិកសាលារៀន ឬសាធារណជនទូទៅដែលមកសាលារៀន។ អ្នកទាំងអស់នេះក៏អាចបង្កហានិភ័យនៃអំពើហិង្សា ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ដូចនេះ នាយក/នាយិកាសាលា និងគ្រូបង្រៀនមានតួនាទី ភារកិច្ចក្នុងការគ្រប់គ្រងភ្ញៀវ និងអ្នកមកទស្សនកិច្ចសាលារៀន។ ដើម្បីគ្រប់គ្រងកិច្ចការនេះឱ្យមានប្រសិទ្ធភាព នាយក/នាយិកាសាលា និងគ្រូបង្រៀន ឬបុគ្គលិកសាលារៀនត្រូវមានតួនាទី ភារកិច្ចដូចខាងក្រោម៖

❖ **តួនាទីរបស់នាយក/នាយិកាសាលា**

- តម្រូវឱ្យភ្ញៀវទាំងអស់ដែលមកទស្សនកិច្ចសាលារៀន ឬបំពេញការងារ ត្រូវចុះឈ្មោះក្នុងបញ្ជីភ្ញៀវ និងអ្នកមកទស្សនកិច្ច។ ផ្តល់ការណែនាំសង្ខេបអំពីគោលការណ៍កិច្ចការពារកុមារដល់ពួកគេ និងផ្តល់ទម្រង់ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់ភ្ញៀវ ដើម្បីអាន និងចុះហត្ថលេខា (សូមមើលឧបសម្ព័ន្ធទី២.ខ)
- ចាំបាច់ត្រូវមានការរក្សាទុកកំណត់ត្រាជាលាយលក្ខណ៍អក្សរ ដោយរៀបរាប់ពីឈ្មោះភ្ញៀវ អាសយដ្ឋានទំនាក់ទំនង ព័ត៌មានលម្អិតអំពីអង្គភាព ឬស្ថាប័ន គោលបំណង និងទីតាំងដែលពួកគេនឹងធ្វើទស្សនកិច្ច ឬបំពេញការងារនៅក្នុងសាលារៀន ។ល។

❖ **តួនាទីរបស់គ្រូបង្រៀន ឬបុគ្គលិកសាលារៀន**

- ត្រូវនៅជាប់ជានិច្ចជាមួយភ្ញៀវ ឬអ្នកមកទស្សនកិច្ច គ្រប់ពេលវេលាអំឡុងពេលទស្សនកិច្ចរហូតដល់ភ្ញៀវចាកចេញពីសាលារៀន
- មិនអនុញ្ញាតជាដាច់ខាតឱ្យភ្ញៀវ ឬអ្នកមកទស្សនកិច្ច ទៅជួបសិស្សានុសិស្សណាម្នាក់ ឬចូលក្នុងបន្ទប់រៀនណាមួយ ឬដោះដូរព័ត៌មានទំនាក់ទំនង ឬថតរូបសិស្សានុសិស្សណាម្នាក់ ដោយពុំបានចុះឈ្មោះជាមុន និងពុំមានការអនុញ្ញាតពីនាយក/នាយិកាសាលាឡើយ។

## ៤. វិធីឆ្លើយតប និងបញ្ជូនករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ

ផ្នែកវិធីឆ្លើយតប និងបញ្ជូនករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនឹងរៀបរាប់លម្អិតអំពីយន្តការរាយការណ៍ យន្តការឆ្លើយតប និងបញ្ជូនកុមារទៅរកសេវាគាំទ្រត្រឹមត្រូវ។

### ៤.១. យន្តការរាយការណ៍

*ក. លំហូរនៃយន្តការរាយការណ៍*

នៅពេលបានដឹង ឬបានឮនូវរាល់ករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ដូចជា ការសង្ស័យ ពាក្យចចាមអារ៉ាម ឧប្បទ្ទវហេតុ ការចោទប្រកាន់ ការអនុវត្តខុស ការបំពានក្រមសីលធម៌ និងគោលនយោបាយកិច្ចការពារកុមារ ។ល។ គ្រូបង្រៀន បុគ្គលិកសាលារៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធជាមួយសាលារៀនទាំងអស់ ត្រូវរាយការណ៍ជាបន្ទាន់ទៅជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន តាមរយៈការរាយការណ៍ដោយផ្ទាល់មាត់ ការហៅទូរស័ព្ទ ការសរសេរសំបុត្រ ជាដើម។

កុមារអាចរាយការណ៍ទៅអ្នកណាដែលកុមារមានទំនុកចិត្ត និងជឿជាក់ ដូចជា មិត្តភក្តិ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល គ្រូបន្ទុកថ្នាក់ គ្រូបង្រៀនដទៃទៀត បុគ្គលិកសាលារៀន ឬជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន តាមរយៈផ្ទាល់មាត់ ទូរស័ព្ទ ឬជាលាយលក្ខណ៍អក្សរ។ អ្នកដែលទទួលបាននូវការរាយការណ៍ពីកុមារណាម្នាក់ ត្រូវរាយការណ៍បន្តទៅជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន។ បន្ទាប់មកជនបង្គោលនឹងផ្តល់ដំណឹងទៅនាយក/នាយិកាសាលា ដើម្បីពិភាក្សា កំណត់ និងវាយតម្លៃករណីដែលបានរាយការណ៍។ នៅគ្រប់ដំណាក់កាលនៃការរាយការណ៍ត្រូវរក្សាការសម្ងាត់ជានិច្ចនូវព័ត៌មានរបស់កុមារ អ្នករាយការណ៍ និងជនសង្ស័យ។ សូមពិនិត្យមើលគំនូសបំព្រួញខាងក្រោមអំពីលំហូរនៃយន្តការរាយការណ៍៖



*គោលការណ៍សម្រាប់ការអនុវត្តនៃយន្តការរាយការណ៍*

- ☑ *ត្រូវធ្វើសកម្មភាពភ្លាមៗគ្រប់ពេលទទួលបានករណី។ ប្រសិនបើនៅស្ងៀម ឬពន្យាពេលអាចធ្វើឱ្យកុមារមានគ្រោះថ្នាក់បន្ថែមទៀត*
- ☑ *ត្រូវផ្តល់អទិភាពខ្លាំងជាងគេអំពីកិច្ចការពារកុមារ បើប្រៀបធៀបនឹងការការពារមុខមាត់ស្ថាប័ន មុខមាត់ជនសង្ស័យ ឬជនប្រព្រឹត្តិ ឬហេតុផលដទៃទៀត*
- ☑ *ត្រូវធានា និងរក្សាការសម្ងាត់ និងភាពថ្លៃថ្នូររបស់កុមារគ្រប់ពេលវេលា*

## *ខ. ការកំណត់ និងវាយតម្លៃករណី*

បន្ទាប់ពីទទួលបាននូវករណី វិធីកំណត់ថាករណីនេះជាអំពើហិង្សា ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ គឺត្រូវធ្វើឡើងស្របតាមនិយមន័យដែលបានកំណត់នៅឧបសម្ព័ន្ធទី១១។ ករណីដែលបានរាយការណ៍មកអាចជាករណីកើតឡើងនៅក្នុង និងនៅក្រៅសាលារៀន ប្រព្រឹត្តដោយបុគ្គលិកសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស អ្នកពាក់ព័ន្ធជាមួយសាលារៀន និងអ្នកសហគមន៍។ ប្រសិនបើក្នុងករណីប្រហែលជាកើតឡើង សាលារៀនត្រូវស្វែងរកព័ត៌មានបន្ថែម ហើយបើក្នុងករណីមិនមានការកើតឡើង សាលារៀនគ្រាន់តែបង្កើត ឬបង្កើនកិច្ចការពារកុមារនៅក្នុងសាលារៀន និងត្រូវរក្សាការសម្ងាត់ និងឯកសារឱ្យបានត្រឹមត្រូវនូវករណីដែលទទួលបាន។ ការវាយតម្លៃករណីនឹងជួយទៅដល់ការកំណត់ស្ថានភាពធ្ងន់ មធ្យម ឬស្រាលរបស់កុមារ ដែលមានលក្ខណៈដូចខាងក្រោម ដើម្បីធ្វើការឆ្លើយតបបន្ទាន់ និងការស្វែងរកដំណោះស្រាយឱ្យទាន់ពេលវេលា។

- **កម្រិតស្ថានភាពកុមាររងគ្រោះធ្ងន់ធ្ងរ៖** កុមារត្រូវការសេវាពិនិត្យ និងព្យាបាលសុខភាពទាំងផ្លូវកាយ ឬផ្លូវចិត្តជាបន្ទាន់ មិនអាចទៅសាលារៀនបាន និងត្រូវការកិច្ចការពារ និងការគាំទ្ររយៈពេលយូរ។
- **កម្រិតស្ថានភាពកុមាររងគ្រោះមធ្យម៖** កុមារមិនមានសញ្ញាណហានិភ័យខ្ពស់ដល់សុខភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ការប្រឈមនឹងការរំលោភបំពានម្តងទៀត និងកុមារអាចសម្រាក១ ឬ២ថ្ងៃ រួចអាចចូលរៀនវិញបាន។
- **កម្រិតស្ថានភាពកុមាររងគ្រោះស្រាល៖** កុមារអាចទៅរៀនបានជាធម្មតា ប៉ុន្តែត្រូវការកិច្ចការពារ និងការគាំទ្រ។

ការវាយតម្លៃត្រូវអនុវត្តជាពីរដំណាក់កាល៖

- **ដំណាក់កាលទី១៖** សាលារៀនអាចអនុវត្តការវាយតម្លៃបឋមទៅតាមកម្រិតនៃស្ថានភាពរបស់កុមាររងគ្រោះ និងធ្វើការឆ្លើយតបបន្ទាន់ ដើម្បីធានាសុវត្ថិភាពរបស់កុមារ ព្រមទាំងបំពេញតម្រូវការជាក់ស្តែងរបស់កុមារ ដូចជា អាហារ ជម្រកសុវត្ថិភាព ការថែទាំសុខុមាលភាព ការប្រឹក្សាផ្លូវចិត្តបឋម ការព្យាបាលផ្នែកវេជ្ជសាស្ត្រ ។ល។ ក្នុងករណីដែលសាលារៀនមិនទាន់មានជំនាញ ឬចំណេះដឹង សាលារៀនអាចទំនាក់ទំនងទៅអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(អ.ក.ន.ក.) ដើម្បីស្វែងរកជំនួយបច្ចេកទេស និងកិច្ចសហការ។
- **ដំណាក់កាលទី២៖** សាលារៀនផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(អ.ក.ន.ក.) ភ្នាក់ងារសង្គម ឬបុគ្គលិកមកពីស្ថាប័នជំនាញ ដើម្បីធ្វើការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ បន្ទាប់ពីការវាយតម្លៃបឋម និងការផ្តល់សេវាបន្ទាន់ដល់កុមារត្រូវបានធ្វើរួច។ ការវាយតម្លៃនេះ គឺពិនិត្យមើលឱ្យបានស៊ីជម្រៅនូវស្ថានភាពរបស់កុមារ (តម្រូវការផ្នែកវេជ្ជសាស្ត្រ ច្បាប់ ចិត្តសាស្ត្រ សេដ្ឋកិច្ច ។ល។) លើសពីនេះ គឺតម្រូវការជាក់ស្តែងរបស់កុមារ។ ការវាយតម្លៃនេះនឹងពិនិត្យអំពីសេវាគាំទ្រដែលកុមារកំពុងទទួល តាមរយៈការសិក្សាស្ថានភាពគ្រួសារ សមត្ថភាពឪពុកម្តាយ ឬអ្នកអាណាព្យាបាលក្នុងកិច្ចការពារកុមារ សមត្ថភាពរបស់កុមារក្នុងកិច្ចការពារខ្លួន ហានិភ័យនៅពេលធ្វើសមាហរណកម្មត្រឡប់មកគ្រួសារ ឬសាលារៀនវិញ ។ល។

## *គ. ការទទួលខុសត្រូវជាក់លាក់នៅក្នុងការអនុវត្តយន្តការរាយការណ៍ប្រកបដោយប្រសិទ្ធភាព*

នាយក/នាយិកាសាលា ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន គ្រូបង្រៀន បុគ្គលិកសាលារៀន និងអ្នកពាក់ព័ន្ធជាមួយនឹងសាលារៀនទាំងអស់មានតួនាទីភារកិច្ចក្នុងអនុវត្តនូវយន្តការរាយការណ៍ ករណីដែលពួកគេបានដឹង ឬបានឮ តាមការណែនាំដូចខាងក្រោម៖

- **នាយក/នាយិកាសាលាត្រូវ៖**
  - បង្កើតយន្តការរាយការណ៍ប្រចាំសាលារៀនរបស់ខ្លួនស្របតាមបរិបទ និងស្ថានភាពរបស់សាលារៀននីមួយៗ រួមទាំងការបញ្ជាក់ពីលេខទូរស័ព្ទសម្រាប់រាយការណ៍ និងសេវាគាំទ្រដែលមាននៅក្នុង និងក្រៅសាលារៀន
  - គ្រប់គ្រងនូវការរាយការណ៍ទៅតាមនីតិវិធីដែលបានបង្កើត និងផ្សព្វផ្សាយពីយន្តការរាយការណ៍របស់សាលារៀនទៅដល់បុគ្គលិកសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស ឪពុកម្តាយ អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធទាំងអស់ និងរបៀបដែលពួកគេអាចរាយការណ៍បានដោយផ្ទាល់មាត់ សរសេរសំបុត្រ ឬការហៅទូរស័ព្ទ
  - ចាត់វិធានការរដ្ឋបាលទៅលើបុគ្គលិកសាលារៀន ឬគ្រូបង្រៀនទាំងអស់ដែលមិនបាន ឬខកខានក្នុងការរាយការណ៍
  - ពិភាក្សាជាមួយជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន អំពីការកំណត់ និងវាយតម្លៃករណីដែលទទួលបាន។ បើជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលា

រៀន គឺជាជនជាប់សង្ស័យនៅក្នុងករណីដែលទទួលបាន ត្រូវបង្កើតនូវគណៈកម្មការឆ្លើយតបបន្ទាន់ ឬគណៈកម្មការវិន័យរបស់សាលារៀន ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ឬអាជ្ញាធរមូលដ្ឋាន ដោយគោរពគោលការណ៍រក្សាការសម្ងាត់

- ជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ឪពុកម្ដាយ និងអ្នកអាណាព្យាបាលកុមារ ក្នុងការធ្វើការវាយតម្លៃករណី និងផ្ដល់ការគាំទ្របន្ទាន់បើចាំបាច់
- រៀបចំបិទផ្សាយលេខទូរស័ព្ទបន្ទាន់ និងសេវាគាំទ្រមួយចំនួននៅតាមថ្នាក់រៀននីមួយៗ នៅក្នុងបណ្ណាល័យ និងនៅលើក្ដារខៀនព័ត៌មានរបស់សាលារៀន ប្រើប្រាស់គំរូដូចខាងក្រោម៖

**លេខទូរស័ព្ទបន្ទាន់ និងសេវាជំនួយ**

| | |
|---|---|
| ទូរស័ព្ទនគរបាលជាតិ **១១៧** | ទូរស័ព្ទជំនួយកុមារ **១២៨០** |
| ទូរស័ព្ទប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់...................... | ទូរស័ព្ទមេឃុំ ចៅសង្កាត់............................. |
| ទូរស័ព្ទនាយក/នាយិកាសាលា................................. | ទូរស័ព្ទមណ្ឌលសុខភាព............................. |

ទូរស័ព្ទជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន......................................................

ទូរស័ព្ទអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(អ.ក.ន.ក.)......................................................

ទូរស័ព្ទអ្នកផ្ដល់សេវាផ្លូវចិត្ត ឬភ្នាក់ងារសង្គមកិច្ច.......................................................................

ទូរស័ព្ទស្ថាប័នផ្ដល់សេវាដទៃទៀត..................................................................................

❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**

- ជូនដំណឹងទៅនាយក/នាយិកាសាលា និងពិភាក្សាអំពីសកម្មភាពដែលត្រូវអនុវត្ត។ ក្នុងករណីនាយក/នាយិកាសាលា គឺជាជនជាប់សង្ស័យប្រព្រឹត្តករណី ត្រូវជូនដំណឹងទៅការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ឬក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការគាំទ្រ និងអន្តរាគមន៍ក្នុងការឆ្លើយតប
- កំណត់ឱ្យបានច្បាស់អំពីឧប្បត្តិហេតុដែលកើតឡើងនៅក្នុងសាលារៀន ឬខាងក្រៅសាលារៀន ករណីនោះប្រព្រឹត្តដោយបុគ្គលិកសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស អ្នកពាក់ព័ន្ធនានារបស់សាលារៀន ឬដោយអ្នកសហគមន៍ដទៃទៀត
- ចុះបញ្ជីករណីនៅក្នុងទម្រង់កត់ត្រាករណី។ *សូមមើលឧបសម្ព័ន្ធទី ៨ ៖ ទម្រង់ចុះបញ្ជី និងបញ្ជូនករណី (ទំព័រទី៥៨)*
- សហការជាមួយគ្រូទទួលបន្ទុក ទីប្រឹក្សាកុមារីក្នុងការវាយតម្លៃ បើកុមារីជាអ្នកទទួលរងគ្រោះនៅក្នុងករណីនោះនៅដំណាក់កាលទី១
- ផ្ដល់កិច្ចសហការ និងជួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ឬភ្នាក់ងារសង្គមកិច្ច ឬបុគ្គលិកមកពីស្ថាប័នជំនាញ ក្នុងការធ្វើសកម្មភាពវាយតម្លៃលើករណីដែលកើតឡើងនៅ

ដំណាក់កាលទី២ និងរក្សាឯកសារឱ្យបានត្រឹមត្រូវ និងរក្សាការសម្ងាត់ ព្រមទាំងជូនដំណឹងទៅនាយក/នាយិកាសាលា។

- ❖ **គ្រូបង្រៀន បុគ្គលិកសាលារៀន ឪពុកម្តាយ អ្នកអាណាព្យាបាល ភ្ញៀវ និងអ្នកពាក់ព័ន្ធនឹងសាលារៀនទាំងអស់ត្រូវ៖**
  - រាយការណ៍ទៅជនបង្គោលកិច្ចការពារកុមារភ្លាមៗ និងយ៉ាងយូរ២៤ម៉ោង នូវរាល់ករណីដែលបានដឹង និងឃើញ ទោះជាពាក្យចចាមអារ៉ាម ការសង្ស័យ ការលេចឮពីអ្នកដទៃ ។ល។ បើក្នុងករណី ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ជាជនសង្ស័យនៅក្នុងករណីនោះ ត្រូវរាយការណ៍ទៅនាយក/នាយិកាសាលាជំនួសវិញ ហើយបើមិនមានទំនុកចិត្តលើយន្តការរាយការណ៍របស់សាលារៀន ត្រូវធ្វើការរាយការណ៍ទៅយន្តការរាយការណ៍របស់រដ្ឋបាលឃុំ សង្កាត់នៅក្នុងសហគមន៍ដែលទុកចិត្ត ឬទៅលេខទូរស័ព្ទនគរបាលជាតិ ១១៧
  - ស្តាប់ដោយយកចិត្តទុកដាក់ និងរក្សាការសម្ងាត់នូវរាល់ករណី ឬក្តីបារម្ភដែលកុមារបានប្រាប់ ព្រមទាំងបញ្ជាក់ជាមួយកុមារអំពីការឆ្លើយតប និងការផ្តល់ការគាំទ្រដល់កុមារឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើបាន ជាពិសេស កុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច ។ល។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពុំគួរធ្វើការសន្យាជាក់លាក់ជាមួយកុមារឡើយ ដោយសារក្នុងករណីការសន្យានោះមិនអាចបំពេញបាន ធ្វើឱ្យកុមារបាត់បង់ទំនុកចិត្ត និងក្តីសង្ឃឹមមកលើអ្នក និងប្រព័ន្ធកិច្ចការពារកុមារទាំងមូល។

## ៤.២. យន្តការឆ្លើយតប និងបញ្ជូនកុមារទៅរកសេវាគាំទ្រត្រឹមត្រូវ

### *ក. លំហូរនៃយន្តការឆ្លើយតប និងបញ្ជូនរបស់សាលារៀន*

បន្ទាប់ពីទទួលបានការរាយការណ៍ និងការកំណត់ករណី និងវាយតម្លៃករណីដំណាក់កាលដំបូង ការឆ្លើយតប និងការបញ្ជូនករណីត្រូវបានអនុវត្តបន្ទាប់ ដោយគោរពនូវគោលការណ៍ឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ ស្តាប់ និងឆ្លើយតបនូវទស្សនៈ ឬតម្រូវការរបស់កុមារ គុណភាពនៃសេវាដែលមានកិច្ចសហការគ្នា ការរក្សាការសម្ងាត់ និងភាពថ្លៃថ្នូររបស់កុមារ។ ការឆ្លើយតប និងការបញ្ជូនអាចធ្វើឡើងទៅតាមករណី ដូចខាងក្រោម៖

- បើករណីនោះជាអំពើហិង្សា និងការកេងប្រវ័ញ្ចលើកុមារ ឬការបំពានលើក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ ហើយកើតឡើងនៅក្នុងសាលារៀន ការឆ្លើយតបត្រូវធ្វើឡើងក្នុងក្របខណ្ឌសាលារៀន ស្របតាមសេចក្តីណែនាំរបស់សាលារៀន និងនីតិវិធីពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ប្រសិនបើករណីជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវដោះស្រាយតាមនីតិវិធីច្បាប់ សាលារៀនត្រូវធ្វើការបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចភ្លាម និងទៅគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ក្នុងការសម្របសម្រួលសេវាគាំទ្រដែលមាននៅក្នុងសហគមន៍ ឬនៅតំបន់នោះ នៅពេលមានតម្រូវការ

- បើករណីនោះជាអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារដែលកើតឡើងនៅក្នុងសហគមន៍ សាលារៀនត្រូវធ្វើការបញ្ជូនព័ត៌មានភ្លាមទៅ គ.ក.ន.ក. ឬអាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុត ឬតាមលេខទូរស័ព្ទបន្ទាន់របស់នគរបាលជាតិ **១១៧** ឬភ្នាក់ងារផ្តល់សេវាដទៃទៀតទៅតាមកម្រិតនៃស្ថានភាពកុមាររងគ្រោះធ្ងន់ មធ្យម ឬស្រាលដើម្បីទទួលសេវាគាំទ្រដែលចាំបាច់
- បើករណីនោះមិនមែនជាទម្រង់អំពើហិង្សា ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ តែប៉ះពាល់ដល់សុខុមាលភាពរបស់កុមារ សាលារៀនត្រូវផ្តល់សេវាគាំទ្រដែលមាននៅសាលារៀន ដូចជាសេវាសង្គ្រោះបឋម ការផ្តល់ប្រឹក្សាផ្លូវចិត្តបឋម អាហារ និងជម្រកបណ្តោះអាសន្ន ។ល។ ឬបញ្ជូនទៅរកសេវាគាំទ្រនៅក្នុងសហគមន៍តាមរយៈគ.ក.ន.ក.។លំហូរនៃយន្តការឆ្លើយតប និងបញ្ជូនរបស់សាលារៀន សូមពិនិត្យមើលគំនូសបំព្រួញ ដូចខាងក្រោមៈ



**គោលការណ៍សម្រាប់ការអនុវត្តនៃយន្តការឆ្លើយតប និងបញ្ជូនទៅរកសេវាគាំទ្រ**

- ☑ ផ្តល់នូវឧត្តមប្រយោជន៍របស់កុមារ និងស្តាប់នូវទស្សនៈ និងតម្រូវការរបស់កុមារ
- ☑ ធានាថាសេវាដែលត្រូវបញ្ជូនទៅ គឺមានអជ្ញាបណ្ណត្រឹមត្រូវ និងការអនុញ្ញាតឱ្យផ្តល់សេវាពីរាជរដ្ឋាភិបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានកិច្ចសហការជាប្រព័ន្ធ
- ☑ រក្សាសុវត្ថិភាពកុមារ គោរពគោលការណ៍រក្សាការសម្ងាត់ និងភាពថ្លៃថ្នូររបស់កុមារនៅគ្រប់ដំណាក់កាល។

## ២. ការទទួលខុសត្រូវក្នុងការឆ្លើយតបករណីដែលកើតឡើងនៅក្នុងសាលារៀនប្រកបដោយប្រសិទ្ធភាព

នាយក/នាយិកាសាលា និងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន មានតួនាទីភារកិច្ចក្នុងការឆ្លើយតបករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ដូចមានការណែនាំខាងក្រោម៖

❖ **នាយក/នាយិកាសាលាត្រូវ៖**

- ស្តាប់ និងឆ្លើយតបសមស្របទៅនឹងកង្វល់ មតិយោបល់ និងតម្រូវការរបស់កុមារ
- បង្កើតក្រុមប្រឹក្សាវិន័យស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដោះស្រាយករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារដែលប្រព្រឹត្តដោយគ្រូបង្រៀន ឬបុគ្គលិកសាលារៀនដទៃទៀត។ នៅពេលករណីត្រូវបានបិទ (ដោះស្រាយចប់សព្វគ្រប់ទៅតាមនីតិវិធី) ក្រុមប្រឹក្សាវិន័យនេះនឹងអស់សុពលភាពដោយគោរពគោលការណ៍រក្សាការសម្ងាត់ សុវត្ថិភាព និងជួយកុមារត្រូវបានណែនាំដល់សមាជិកក្រុមប្រឹក្សាវិន័យ
- ក្នុងករណីរកឃើញថាបុគ្គលិកសាលារៀន ឬគ្រូបង្រៀនពិតជាបានប្រព្រឹត្តអំពើទាំងនោះមែនដែលខុសពីក្រមសីលធម៌វិជ្ជាជីវៈ ត្រូវទទួលទណ្ឌកម្មទៅតាមវិន័យរដ្ឋបាលថ្នាក់ទី១ ឬថ្នាក់ទី២ ស្របតាមកម្រិតនៃការបំពាន ប្រសិនបើករណីបទល្មើសព្រហ្មទណ្ឌត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច អនុវត្តទៅតាមផ្លូវច្បាប់
- ដឹកនាំអនុវត្តតាមនីតិវិធីនៃការស្នើ ឬការតវ៉ា ការប្តឹង និងដំណោះស្រាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ប្រកាសលេខ២២៨០ នៅឆ្នាំ២០១២
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំទៅតាមឋានានុក្រមនៃប្រព័ន្ធអប់រំ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងស្នើសុំជំនួយ និងការអន្តរាគមន៍ក្នុងករណីចាំបាច់
- ដោះស្រាយករណីតាមបែបកុមារមេត្រី ដោយផ្អែកទៅតាមប្រភេទករណី ប្រភេទកុមាររងគ្រោះតាមរយៈការសម្រុះសម្រួល ការប្រមូលព័ត៌មាន ការស៊ើបអង្កេត ឬការបញ្ជូនទៅអាជ្ញាធរមាន

សមត្ថកិច្ចស្របតាមច្បាប់ ដោយកត់ត្រានូវកំណត់ហេតុឱ្យបានច្បាស់លាស់ទៅតាមកម្រិតនៃស្ថានភាពគ្រោះថ្នាក់របស់កុមារ ដូចខាងក្រោម៖

- **កម្រិតស្ថានភាពកុមាររងគ្រោះធ្ងន់ធ្ងរ៖** ការឆ្លើយតបត្រូវធ្វើភ្លាមៗ និងទំនាក់ទំនងជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក.) មណ្ឌលសុខភាព និង/ឬនគរបាល
- **កម្រិតស្ថានភាពកុមាររងគ្រោះមធ្យម៖** ត្រូវឆ្លើយតបភ្លាមៗបន្ទាប់ពីទទួលករណី តាមដានស្ថានភាពរបស់កុមារដែលរងគ្រោះ និងទំនាក់ទំនងទៅអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវាពិសេសចាំបាច់មួយចំនួនដល់កុមារស្របតាមតម្រូវការដែលទទួលបានពីការវាយតម្លៃ
- **កម្រិតស្ថានភាពកុមាររងគ្រោះស្រាល៖** ត្រូវឆ្លើយតបភ្លាមៗបន្ទាប់ពីទទួលករណី និងតាមដាននូវស្ថានភាពរបស់កុមារដែលរងគ្រោះ

▪ ជូនដំណឹងដល់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលកុមារ បើករណីប្រព្រឹត្តដោយសិស្សានុសិស្សណាម្នាក់ (ក្នុងករណីមិនបង្កគ្រោះថ្នាក់ដល់សិស្សានុសិស្សដែលប្រព្រឹត្ត ឬសិស្សានុសិស្សដែលរងគ្រោះ)។

❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**

▪ ពិនិត្យឯកសារដែលបានបំពេញលើករណី និងធ្វើការឆ្លើយតប
▪ ទទួលបណ្តឹង តវ៉ា ឬស្នើរបស់សិស្សានុសិស្ស ឪពុកម្តាយ អ្នកអាណាព្យាបាល គ្រូបង្រៀន និងអ្នកពាក់ព័ន្ធផ្សេងៗ
▪ កំណត់ករណី និងរាយការណ៍ទៅក្រុមប្រឹក្សាវិន័យ និងនាយក/នាយិកាសាលា
▪ ទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងចងក្រងបញ្ជីសេវាគាំទ្រនានា
▪ ផ្តល់ព័ត៌មានត្រឹមត្រូវអំពីសេវាគាំទ្រនានាដែលមានស្រាប់ដល់កុមារ និងទំនាក់ទំនងជាមួយក្រុមគ្រួសារ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល របស់កុមារ
▪ បើករណីកើតឡើងនៅក្រៅសាលារៀន និងប្រព្រឹត្តិដោយសហគមន៍ ត្រូវរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ឬតាមទូរស័ព្ទបន្ទាន់របស់នគរបាលជាតិ ១១៧ ដើម្បីស្នើសុំអន្តរាគមន៍ និងឆ្លើយតប
▪ បើករណីកើតឡើងមិនមែនជាទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ តែមានការប៉ះពាល់ដល់សុខុមាលភាពកុមារ ត្រូវបញ្ជូនទៅរកសេវាគាំទ្ររបស់សាលារៀន ឬសេវាគាំទ្រនៅសហគមន៍។

### *គ. ការទទួលខុសត្រូវក្នុងការបញ្ជូនប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព*

នាយក/នាយិកាសាលា និងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន មានតួនាទីភារកិច្ចក្នុងការបញ្ជូនករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារដែលរងគ្រោះ ដូចមានការណែនាំខាងក្រោម៖

- ❖ **នាយក/នាយិកាសាលាត្រូវ៖**
  - សហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការចងក្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវលេខទូរស័ព្ទ និងសេវាគាំទ្រសំខាន់ៗដែលមាននៅក្នុងសហគមន៍ រួមទាំង សេវាសង្គមកិច្ច សុខាភិបាល ផ្នែកច្បាប់ ការផ្តល់ប្រឹក្សាផ្លូវចិត្ត ជម្រកសុវត្ថិភាព ។ល។
  - ផ្សព្វផ្សាយដល់បុគ្គលិកសាលារៀន គ្រូបង្រៀន និងអ្នកពាក់ព័ន្ធទាំងអស់ជាប្រចាំនូវតួនាទីភារកិច្ចរបស់ពួកគេនៅក្នុងការអនុវត្តនូវយន្តការបញ្ជូន
  - ពង្រឹងសមត្ថភាពដល់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ស្តីពីការដោះស្រាយ និងបញ្ជូនករណីព្រមទាំងការផ្តល់នូវសេវាផ្តល់ប្រឹក្សាផ្លូវចិត្តបឋមដល់កុមារ
  - ជ្រើសរើសអ្នកផ្តល់សេវាប្រឹក្សាផ្លូវចិត្តប្រចាំសាលា ឬមានកិច្ចសហការជាមួយភ្នាក់ងារសង្គមកិច្ចពីស្ថាប័នដទៃ ឬទំនាក់ទំនងទៅសេវាផ្តល់ប្រឹក្សាតាមទូរស័ព្ទពីបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា ១២៨០
  - សម្របសម្រួល និងផ្តល់សេវាគាំទ្រដែលសាលារៀនអាចធ្វើបានដល់កុមារ ដូចជា អាហារ ការធ្វើដំណើរទៅរកសេវាផ្នែកវេជ្ជសាស្ត្រ កម្រៃសេវា ការស្នាក់នៅកន្លែងសុវត្ថិភាពនៅពេលផ្ទះរបស់កុមារមិនទាន់មានសុវត្ថិភាព ឬអាចផ្តល់ហានិភ័យបន្ថែមដល់កុមារ។ល។ ដោយប្រើប្រាស់ថវិការបស់សាលានៅក្នុងខ្ទង់ចំណាយសុខភាពសិក្សា ឬការកៀរគរពីអ្នកពាក់ព័ន្ធ។

- ❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**
  - ជូនដំណឹងដល់នាយក/នាយិកាសាលាអំពីការអនុវត្តការបញ្ជូននៅក្នុងសាលារៀន ឬតម្រូវការនៃការបញ្ជូនទៅសេវាគាំទ្រខាងក្រៅផ្អែកលើការវាយតម្លៃករណីបឋម
  - បំពេញនូវទម្រង់បញ្ជូន *សូមមើលឧបសម្ព័ន្ធទី ៩ ៖ ទម្រង់បច្ចុប្បន្នភាពពីស្ថានភាពកុមារ (ទំព័រទី ៦០)* និងទំនាក់ទំនងទៅសេវាគាំទ្រសមស្របសម្រាប់កុមារ
  - ស្នើសុំការយល់ព្រមពីកុមារ ឪពុកម្តាយ និងអ្នកអាណាព្យាបាលកុមារមុននឹងបញ្ជូន លើកលែងតែក្នុងករណីចាំបាច់បន្ទាន់ដែលត្រូវសង្គ្រោះជីវិត និងរក្សាការទំនាក់ទំនងជាមួយឪពុកម្តាយ និងអ្នកអាណាព្យាបាលកុមារជាប្រចាំ
  - ស្នើសុំការសម្របសម្រួលពីគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការចាត់ចែង និងសម្របសម្រួលសេវាគាំទ្រដែលចាំបាច់ស្របតាមការវាយតម្លៃករណី និងស្ថានភាពរបស់កុមារដែលរងគ្រោះជាពិសេសកុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច ។ល។
  - សហការជាមួយអ្នកផ្តល់សេវាកិច្ចការពារកុមារ ដើម្បីបញ្ជូនកុមារទៅរកសេវាគាំទ្រត្រឹមត្រូវ និងផ្តល់ព័ត៌មានអំពីតម្រូវការរបស់កុមារទៅដល់អ្នកផ្តល់សេវា
  - ធ្វើការតាមដានជាប្រចាំយ៉ាងតិច១សប្តាហ៍ម្តង ដោយស្នើទៅអ្នកផ្តល់សេវាអំពីបច្ចុប្បន្នភាពអំពីករណី និងស្ថានភាពកុមារ ព្រមទាំងបំពេញទម្រង់បច្ចុប្បន្នភាពករណី (សូមមើលឧបសម្ព័ន្ធទី៩)

- ចុះទៅជួបកុមារ និងគ្រួសារកុមារដោយផ្ទាល់ដោយស្នើទៅអ្នកផ្តល់សេវា និងពិភាក្សាជាមួយពួកគេ ដើម្បីដឹងពីស្ថានភាពរបស់កុមារ និងតម្រូវការបន្ថែមរបស់កុមារ ហើយត្រូវធ្វើការវាយតម្លៃបន្ថែមក្នុងការឆ្លើយតបតម្រូវការនោះ
- រៀបចំរបាយការណ៍ និងរាយការណ៍ដល់គណៈកម្មការគ្រប់គ្រងសាលារៀន
- រក្សានូវរាល់ឯកសារនៃការបញ្ជូន និងរបាយការណ៍បច្ចុប្បន្នភាពនៅកន្លែងដែលមានសុវត្ថិភាព និងគោរពគោលការណ៍រក្សាការសម្ងាត់។

ការសង្ខេបទំនាក់ទំនងនៃលំហូររបស់យន្តការយន្តការរាយការណ៍ និងយន្តការឆ្លើយតប និងបញ្ជូនកុមារទៅរកសេវាគាំទ្រ សូមមើលគំនូសបំព្រួញ ដូចខាងក្រោម៖


សំណុំនៃយន្តការរាយការណ៍
ករណីអំពើហិង្សា ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
ការសង្ស័យ ពាក្យចចាមអារ៉ាម ឧប្បទ្ទវហេតុ ការចោទប្រកាន់ និងការបំពានក្រមសីលធម៌ ឬគោលនយោបាយ ។ល។
បុគ្គលិក
គ្រូបង្រៀន
សិស្សានុសិស្ស
ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធរបស់សាលារៀន
ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន
ឈ្មោះ........................................................
លេខទូរស័ព្ទ................................................
នាយក/នាយិកាសាលា
ឈ្មោះ.........................
លេខទូរស័ព្ទ................
ការកំណត់ និង វាយតម្លៃករណី
ការវាយតម្លៃដំណាក់កាលទី១
ការវាយតម្លៃដំណាក់កាលទី២
សំណុំនៃយន្តការឆ្លើយតប និងបញ្ជូនកុមារទៅរកសេវា
ករណីនេះជាអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ឬបំពាន ក្រមសីលធម៌ស្ដីពីកិច្ចការពារកុមារដែលកើតឡើងនៅក្នុងសាលារៀន
ករណីនេះជាអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារកើតឡើងនៅក្នុងសហគមន៍
ករណីមិនមែនជាអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ តែមានការប៉ះពាល់ដល់សុខុមាលភាពរបស់កុមារ
ការឆ្លើយតប និងការគាំទ្រទៅតាមយន្តការរបស់សាលារៀន
ករណីបទល្មើសព្រហ្មទណ្ឌ ឬត្រូវការសេវាគាំទ្រដល់កុមារ
ការជូនដំណឹងទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្សនៅក្នុងករណីមិនបង្កគ្រោះថ្នាក់ដល់កុមារ
បញ្ជូនទៅគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ភ្នាក់ងារផ្ដល់សេវាសង្គមកិច្ច ឬអាជ្ញាធរមានសមត្ថកិច្ច
ទៅសេវាគាំទ្រនៅក្នុងសហគមន៍
ទៅសេវាគាំទ្ររបស់សាលារៀន
សេវាសុខាភិបាល
សេវាអន្តរាគមន៍ និងជំនួយផ្នែកច្បាប់
សេវាផ្ដល់ការប្រឹក្សាផ្លូវចិត្ត
សេវាធ្វើសមាហរណកម្ម

### *ឃ. ការសហការក្នុងការធ្វើសមាហរណកម្មកុមារត្រឡប់មកសាលារៀនវិញប្រកបដោយសុវត្ថិភាព*

ការធ្វើសមាហរណកម្មកុមារ គឺជាដំណើរការមួយនៃការវិលត្រឡប់របស់កុមារចូលរៀននៅក្នុងសាលារៀនវិញបន្ទាប់ពីពួកគេអវត្តមានមួយរយៈពេល ដើម្បីទទួលបានសេវាគាំទ្រនានានៅខាងក្រៅសាលារៀន។ គោលការណ៍នៃការធ្វើសមាហរណកម្មកុមារ គឺជាការបង្កលក្ខណៈដល់កុមារទៅធ្វើសកម្មភាពដូចពីមុនដែលកុមារធ្លាប់ធ្វើជាមួយមិត្តភក្តិ ការសិក្សារៀនសូត្រ ការចូលរួមសកម្មភាពនានានៅក្នុងសាលារៀន។ល។ នាយក/នាយិកាសាលា និងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន មានតួនាទី ភារកិច្ចក្នុងការធ្វើសមាហរណកម្មកុមារត្រឡប់មកសាលារៀនវិញដោយសុវត្ថិភាព និងបរិយាបន្នទៅតាមការណែនាំខាងក្រោម៖

- **នាយក/នាយិកាសាលាត្រូវ៖**
  - **មុនពេលធ្វើសមាហរណកម្ម**
    - សហការជាមួយអ្នកផ្តល់សេវា ឬគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) ក្នុងការត្រៀមធ្វើសមាហរណកម្មកុមារចូលសាលារៀនវិញ រួមបញ្ចូលទាំងការពិគ្រោះយោបល់ និងការផ្តល់កិច្ចគាំទ្រដល់ឪពុកម្តាយ និងអ្នកអាណាព្យាបាលកុមារ
    - ត្រៀមរកសេវាគាំទ្រផ្សេងៗសម្រាប់កុមារ ទាំងនៅផ្ទះ និងនៅក្នុងសាលារៀន ទៅតាមតម្រូវការជាក់ស្តែងរបស់កុមារដោយរៀបចំខុសៗគ្នា និងជាពិសេស កុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច កុមារមិនកំណត់អត្តសញ្ញាណភេទ កុមារកំព្រា កុមារងាយរងគ្រោះ ។ល។
    - ប្រជុំណែនាំដល់គ្រូបន្ទុកថ្នាក់អំពីអាកប្បកិរិយា និងកិច្ចគាំទ្រដែលចាំបាច់សម្រាប់កុមារ ឬរាយការណ៍ជូនជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន។

  - **អំឡុងពេលធ្វើសមាហរណកម្ម**
    - ផ្តល់នូវសេវាគាំទ្រចាំបាច់ភ្លាមៗដល់កុមារ ប្រសិនបើកុមារត្រូវការ ដូចជា ការប្រឹក្សាផ្លូវចិត្ត សម្ភារសិក្សា ។ល។
    - ពិភាក្សាជាប្រចាំជាមួយជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន និងគ្រូបន្ទុកថ្នាក់ពីស្ថានភាពរបស់កុមារ និងទំនាក់ទំនងជាប្រចាំជាមួយឪពុកម្តាយ និងអ្នកអាណាព្យាបាលអំពីស្ថានភាពកុមារនៅផ្ទះ និងនៅសាលារៀន
    - សហការជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (អ.ក.ន.ក.) ក្នុងការតាមដាន និងពិភាក្សាជាមួយកុមារជាប្រចាំយ៉ាងតិច២សប្តាហ៍ម្តង នៅរយៈពេល៦ខែដំបូង និង១ខែម្តងនៅពេលបន្ទាប់រហូតមានការជឿជាក់ថាកុមារអាចសិក្សា និងចូលរួមសកម្មភាពនានានៅក្នុងសាលារៀនដូចធម្មតា។

❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**

- **មុនពេលធ្វើសមាហរណកម្ម**
  - សិក្សាពីហានិភ័យដែលកុមារអាចប្រឈមនៅពេលត្រឡប់ទៅសាលារៀន និងរៀបចំសកម្មភាពបង្ការពីការប្រឈម និងហានិភ័យនានាពីអំពើហិង្សា និងកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារម្តងទៀត ការឆ្លើយតប និងកាត់បន្ថយហានិភ័យទាំងនោះ។

- **អំឡុងពេលធ្វើសមាហរណកម្ម**
  - ពិគ្រោះយោបល់ជាមួយគ្រូទទួលបន្ទុកថ្នាក់ ឪពុកម្តាយ និងអ្នកអាណាព្យាបាលកុមារ ដើម្បីទទួលបានព័ត៌មានអំពីកុមារ និងធ្វើការជូនដំណឹងដល់នាយក/នាយិកាសាលា ឬគណៈកម្មការគ្រប់គ្រងសាលារៀន។

❖ **បុគ្គលិកសាលារៀន និងគ្រូបង្រៀនត្រូវ៖**

- **អំឡុងពេលធ្វើសមាហរណកម្ម**
  - ផ្តល់នូវការណែនាំខ្លីៗអំពីកិច្ចការពារខ្លួន បច្ចុប្បន្នភាពសាលារៀន ឬកម្មវិធីសិក្សាក្នុងថ្នាក់ និងឥរិយាបថល្អរបស់សិស្សានុសិស្សដល់កុមារដែលត្រឡប់មករៀនវិញ
  - ធ្វើការអង្កេតអាកប្បកិរិយា និងឥរិយាបថរបស់កុមារ ជាប្រចាំ ជាពិសេសកុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច កុមារងាយរងគ្រោះ និងផ្តល់ព័ត៌មានដល់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន។

### *ង. ការបិទករណី*

ការបិទករណី គឺជាសកម្មភាពចុងក្រោយបង្អស់នៃការដោះស្រាយ និងឆ្លើយតបករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន។ ការបិទករណីអាចបណ្តាលមកពីកត្តាជាច្រើន ដូចជា៖

- ករណីត្រូវបានដោះស្រាយចប់សព្វគ្រប់ទៅតាមនីតិវិធី ហើយកុមារមិនត្រូវការជំនួយបន្ថែមទៀត
- មិនមានសញ្ញាណហានិភ័យចំពោះកុមារ ឪពុកម្តាយ និងអ្នកអាណាព្យាបាលមានលទ្ធភាពការពារកុមារបាន
- ករណីសង្ស័យត្រូវបានតាមដានរយៈពេល៣ខែ ប្រសិនបើមិនមានសញ្ញាណហានិភ័យអ្វីមួយកើតឡើងពិតប្រាកដចំពោះកុមារ
- កុមារត្រូវបានផ្លាស់ប្តូរកន្លែងរស់នៅ ឬផ្លាស់ប្តូរសាលារៀន។

នាយក/នាយិកាសាលា និងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន មានតួនាទីភារកិច្ចក្នុងការបិទករណីប្រកបដោយប្រសិទ្ធភាព ទៅតាមការណែនាំខាងក្រោម៖

❖ **នាយក/នាយិកាសាលាត្រូវ៖**

- ប្រឹក្សាយោបល់ជាមួយអ្នកទទួលបន្ទុកកិច្ចការពារនារី និងកុមារឃុំ សង្កាត់ ដើម្បីស្វែងយល់ពីព័ត៌មាន និងបច្ចុប្បន្នភាព នៃស្ថានភាពរបស់កុមារ

- ពិនិត្យលើឯកសារ និងចុះហត្ថលេខាដើម្បីបិទករណីជាស្ថាពរ។

❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**

- រៀបចំឯកសារ និងអំណះអំណាងក្នុងការបិទករណីណាមួយ ផ្អែកលើកត្តា ឬលក្ខណៈនៃករណី
- រក្សាទុកឯកសារពាក់ព័ន្ធនឹងការបិទករណីនៅកន្លែងមានសុវត្ថិភាព និងឈរលើគោលការណ៍រក្សាការសម្ងាត់។

## ៥. វិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង

ផ្នែកវិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លងនឹងរៀបរាប់លម្អិតអំពីចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ប្រភេទគ្រោះមហន្តរាយផ្សេងៗដែលអាចកើតឡើងមកលើកុមារ
- ជំហាននៃវិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង
- ការទទួលខុសត្រូវក្នុងការឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង

### ៥.១. ប្រភេទគ្រោះមហន្តរាយផ្សេងៗដែលអាចកើតឡើងមកលើកុមារ

បញ្ហាអំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងគ្រោះថ្នាក់ផ្សេងៗលើកុមារអាចកើតឡើងគ្រប់ពេលវេលា និងស្ថានភាពទាំងអស់។ កុមារអាចចាត់ទុកជាក្រុមជនងាយរងគ្រោះ ដែលធ្លាប់ ឬងាយទទួលផលប៉ះពាល់ពីគ្រោះមហន្តរាយផ្សេងៗ។ គ្រោះមហន្តរាយទាំងនោះ អាចផ្តុំជាប្រភេទ ឬក្រុមធំៗ រួមមានដូចខាងក្រោម៖

- *គ្រោះមហន្តរាយពីធម្មជាតិ៖* គ្រោះមហន្តរាយកើតដោយធម្មជាតិ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ រន្ទះបាញ់ រញ្ជួយដី បាក់ស្រុតដី ការកើនឡើងកំដៅ ភ្លើងឆេះព្រៃ ដើមឈើរលំ ឬបាក់មែក ។ល។
- *គ្រោះមហន្តរាយពីស្នាដៃមនុស្ស៖* គ្រោះមហន្តរាយកើតឡើងដោយមនុស្សជាអ្នកបង្កដូចជា អគ្គីភ័យ គ្រោះថ្នាក់ចរាចរណ៍ ការបាក់ស្រុត ឬរលំអាគារ ការបំពុលខ្យល់ធ្ងន់ធ្ងរ ការប្រើប្រាស់ថ្នាំពុលកសិកម្ម ការប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀន កាប់បំផ្លាញព្រៃឈើ ការបំពុលបរិស្ថាន ការបំពុលចំណីអាហារ ការលង់ទឹក សង្គ្រាមនានា ។ល។
- *គ្រោះមហន្តរាយពីជំងឺឆ្លង៖* ការផ្ទុះ និងការរីករាលដាល ឬផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរបណ្តាលមកពីជំងឺមួយចំនួន ដូចជា អាសន្នរោគ គ្រុនឈាម គ្រុនចាញ់ ផ្តាសាយបក្សី ផ្តាសាយជ្រូក កូវីដ-១៩ គ្រុនឈីក អេដស៍ និងជំងឺដទៃទៀត ដោយមានការប្រកាស ឬចេញសេចក្តីណែនាំពីក្រសួងពាក់ព័ន្ធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ
- *គ្រោះមហន្តរាយផ្សេងៗ៖* គ្រោះមហន្តរាយដែលបង្កឡើងដោយសត្វនានា ដូចជា៖ ឆ្កែខាំ ឆ្មាខាំ កណ្តុរខាំ ពស់ចឹក ឱម៉ាល់ទិច ឃ្មុំទិច ស្រាំងទិច ក្អែបទិច ខ្ជួយទិច ។ល។

### ៥.២. ជំហាននៃវិធីឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង

ការឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង ត្រូវតែគិតគូរពិចារណា និងអនុវត្តន៍ទៅតាមជំហានដូចខាងក្រោម៖

## វដ្តនៃការឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង




### ៥.៣. ការទទួលខុសត្រូវក្នុងការឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង

### *ក. ការរៀបចំផែនការត្រៀមឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លង*

អ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តជំហាននេះ រួមមាន នាយក/នាយិកាសាលា និងគណៈកម្មការសុខភាពសិក្សា។

❖ **នាយក/នាយិកាសាលាត្រូវ៖**

- ណែនាំអ្នកដែលចូលរួមក្នុងសកម្មភាពឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លងទាំងអស់ឱ្យបានយល់ដឹងអំពីក្រមសីលធម៌ និងសេចក្តីណែនាំស្តីពីកិច្ចការពារកុមារ
- បង្កើតឱ្យមានគណៈកម្មការសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា ស្របតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា (សម្រាប់សាលារៀនដែលមិនទាន់បង្កើត)
- ផ្តល់យោបល់ដល់គណៈកម្មការសុខភាពសិក្សា នៅតាមគ្រឹះស្ថានសិក្សាឱ្យដាក់បញ្ចូលកិច្ចការពារកុមារ យន្តការរាយការណ៍ទៅក្នុងផែនការសកម្មភាព ស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

❖ **គណៈកម្មការសុខភាពសិក្សាត្រូវ៖**

- ដាក់បញ្ចូលកិច្ចការពារកុមារ និងយន្តការឆ្លើយតបទៅក្នុងផែនការត្រៀមឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លង
- ពង្រឹង និងអនុវត្តតួនាទី ភារកិច្ចរបស់គណៈកម្មការឱ្យមានប្រសិទ្ធភាពក្នុងការគាំទ្រកិច្ចការពារកុមារ នៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង។

## *ខ. ការស្ទាបស្ទង់ និងវិភាគអំពីតម្រូវការនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង*

អ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តជំហាននេះ រួមមាន នាយក/នាយិកាសាលា គណៈកម្មការសុខភាពសិក្សា ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន និងគ្រូបង្រៀន។

❖ **នាយក/នាយិកាសាលាត្រូវ៖**

- រៀបចំរបាយការណ៍ពីការស្ទាបស្ទង់ និងផែនការឆ្លើយតប បង្ហាញជូនដល់គណៈគ្រប់គ្រងសាលារៀន គណៈកម្មការសុខភាពសិក្សា និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ដើម្បីប្រមូលជាធាតុចូលក្នុងការរៀបចំផែនការឆ្លើយតប
- ស្នើដល់គណៈកម្មការសុខភាពសិក្សា និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ សង្កាត់ ដើម្បីចូលរួមគាំទ្រ និងរកដំណោះស្រាយបានទាន់ពេលវេលា។

❖ **គណៈកម្មការសុខភាពសិក្សាត្រូវ៖**

- ដាក់បញ្ចូលនូវបញ្ហាកិច្ចការពារកុមារទៅក្នុងសកម្មភាពស្ទាបស្ទង់ និងវិភាគពីតម្រូវការ ដើម្បីស្ទាបស្ទង់អំពីតម្រូវការ ដូចជា ករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ដែលបានកើតឡើង តម្រូវការកុមាររងគ្រោះ ស្ថានភាពសេវាគាំទ្រកុមារ បញ្ហាសមធម៌យេនឌ័រ និងបរិយាបន្ន សមត្ថភាពរបស់សហគមន៍ កុមារាកុមារី និងគ្រូបង្រៀន នៅក្នុងការឆ្លើយតបកិច្ចការពារកុមារនៅពេលមានគ្រោះមហន្តរាយ និងជំងឺឆ្លង។

❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**

- រៀបចំបង្កើតនូវបញ្ជីសំណួរស្ទាបស្ទង់ស្តីពីកិច្ចការពារកុមារនៅក្នុងគ្រោះមហន្តរាយ និងជំងឺឆ្លង
- កត់ត្រា និងរក្សាទុកដាក់ឯកសារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសាលារៀន។

❖ **គ្រូបង្រៀនត្រូវ៖**

- រៀបចំកិច្ចពិគ្រោះយោបល់បែបកុមារមេត្រីជាមួយកុមារា កុមារី ឪពុកម្តាយ អ្នកអាណាព្យាបាល និងសហគមន៍ អំពីការព្រួយបារម្ភនានា ដែលអាចកើតឡើងលើបញ្ហាកិច្ចការពារកុមារ និងការធ្វើដំណើរទៅ-មកសាលារៀនជាប្រចាំរបស់កុមារ។

### គ. ការរៀបចំផែនការឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លង

អ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តជំហាននេះ រួមមាន នាយក/នាយិកាសាលា គណៈកម្មការសុខភាពសិក្សា ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន និងគ្រូបង្រៀន។

- **នាយក/នាយិកាសាលាត្រូវ៖**
  - ពិភាក្សាអំពីការទទួលខុសត្រូវ និងថវិកាសម្រាប់អនុវត្តសកម្មភាព
  - អនុវត្តការជ្រើសរើសអ្នកឆ្លើយតប ឬអ្នកស្ម័គ្រចិត្ត ស្របតាមសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន
  - រៀបចំផែនការ ដើម្បីទប់ស្កាត់អំពីហានិភ័យដែលអាចកើតឡើងចំពោះកុមារ គ្រួសារ និងសហគមន៍។

- **គណៈកម្មការសុខភាពសិក្សាត្រូវ៖**
  - ពិភាក្សា និងសម្រេចទៅលើផែនការ រៀបចំនូវសម្ភារ និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាលារៀន ដែលជួយឱ្យកុមារមានសុវត្ថិភាពពីគ្រោះមហន្តរាយ និងជំងឺឆ្លង ដោយឱ្យកុមារា កុមារីគ្រប់រូបអាចមកសាលារៀនបាន
  - ពិភាក្សាអំពីសូចនាករកិច្ចការពារកុមារ ដើម្បីត្រួតពិនិត្យពីភាពរីកចម្រើននៃការអនុវត្តផែនការ។

- **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**
  - បង្កើតនូវសូចនាករស្តីពីកិច្ចការពារកុមារសម្រាប់តាមដានផែនការឆ្លើយតប និងដាក់ក្នុងដំណើរការកិច្ចពិភាក្សា
  - រៀបចំសម្ភារផ្សព្វផ្សាយ និងយន្តការរាយការណ៍ និងបញ្ចូលទៅក្នុងសកម្មភាពឆ្លើយតប។

- **គ្រូបង្រៀនត្រូវ៖**
  - ចែករំលែកនូវមតិយោបល់ និងការព្រួយបារម្ភអំពីកិច្ចការពារកុមារ អំពីផែនការឆ្លើយតប
  - អប់រំ ណែនាំ ផ្សព្វផ្សាយដល់សិស្សានុសិស្សជាប្រចាំ ពីការទប់ស្កាត់នូវគ្រោះមហន្តរាយ និងជំងឺឆ្លងដែលអាចកើតមានឡើង។

### ឃ. ការអនុវត្ត និងត្រួតពិនិត្យលើផែនការឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លង

អ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តជំហាននេះ រួមមាន នាយក/នាយិកាសាលា គណៈកម្មការសុខភាពសិក្សា ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន និងគ្រូបង្រៀន។

- **នាយក/នាយិកាសាលាត្រូវ៖**
  - ណែនាំដល់បុគ្គលិកសាលារៀន និងគ្រូបង្រៀនអំពីការដោះស្រាយកិច្ចការពារកុមារនៅក្នុងស្ថានភាពនេះ

- ដាក់បញ្ចូលការអប់រំ ផ្សព្វផ្សាយ យន្តការរាយការណ៍ ស្ដីពីកិច្ចការពារកុមារទៅក្នុងសកម្មភាពនានា ដូចជា ការផ្ដល់ស្បៀងអាហារ និងសម្ភារដល់អ្នកទទួលរងផលប៉ះពាល់
- ធ្វើការត្រួតពិនិត្យជាប្រចាំនូវសកម្មភាពដែលអនុវត្ត និងបង្ហាញរបាយការណ៍ក្នុងកិច្ចប្រជុំរបស់គណៈកម្មការសុខភាពសិក្សា និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ដោយធ្វើការបែងចែកទិន្នន័យទៅតាមអាយុ ភេទ ពិការភាព ជនជាតិ និងស្ថានភាពគ្រួសាររបស់កុមារ។

❖ **គណៈកម្មការសុខភាពសិក្សាត្រូវ៖**

- សហការជាមួយអ្នកផ្ដល់សេវាឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លងក្នុងការជួយដល់ការឆ្លើយតប កិច្ចការពារកុមារ និងគាំទ្រដល់កុមារដែលរងគ្រោះឱ្យបានទាន់ពេលវេលា។

❖ **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**

- ផ្ដល់ការគាំទ្រក្នុងការដោះស្រាយករណីដែលបានទទួល ឬមានការរាយការណ៍
- កត់ត្រា និងបញ្ជូនករណីទៅរកសេវាគាំទ្រ
- ផ្សព្វផ្សាយពីហានិភ័យនៃកិច្ចការពារកុមារនៅអំឡុងពេលសកម្មភាពឆ្លើយតប។

❖ **គ្រូបង្រៀនត្រូវ៖**

- រាយការណ៍រាល់ករណីសង្ស័យដែលទាក់ទងទៅនឹងអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- រៀបចំកន្លែងដែលមានសុវត្ថិភាព ឬជម្លៀសកុមារទៅរកកន្លែងដែលមានសុវត្ថិភាពតាមបែបកុមារមេត្រី ដើម្បីឱ្យកុមារជៀសផុតពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់
- ធ្វើការអប់រំ ផ្សព្វផ្សាយដល់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលអំពីកិច្ចការពារកុមារ ដូចជា វិធីបង្ការ និងការពារខ្លួនឱ្យមានសុវត្ថិភាពពីគ្រោះមហន្តរាយ និងជំងឺឆ្លងនានា។

## *៥. ការវាយតម្លៃលើផែនការឆ្លើយតបគ្រោះមហន្តរាយ និងជំងឺឆ្លង*

អ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តជំហាននេះ រួមមាន នាយក/នាយិកាសាលា គណៈកម្មការសុខភាពសិក្សា និងជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន។

❖ **នាយក/នាយិកាសាលាត្រូវ៖**

- ចងក្រងនូវរាល់ការអនុវត្តល្អៗ និងចំណុចខ្វះខាតក្នុងការឆ្លើយតបទៅនឹងកិច្ចការពារកុមារក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង ឬករណីអាសន្ននានា ដើម្បីផ្ដល់ជាមេរៀនសម្រាប់ការអនុវត្តលើកក្រោយឱ្យកាន់តែល្អប្រសើរ។

- **គណៈកម្មការសុខភាពសិក្សាត្រូវ៖**
  - ដាក់បញ្ចូលសូចនាករកិច្ចការពារកុមារនៅក្នុងផែនការវាយតម្លៃ ស្របតាមស្ថានភាពជាក់ស្តែង។

- **ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀនត្រូវ៖**
  - រៀបចំឧបករណ៍វាយតម្លៃតាមបែបកុមារមេត្រីជាមួយកុមារា កុមារី គ្រួសារ ឪពុកម្តាយ អ្នកអាណាព្យាបាល និងសហគមន៍។

## ៦. យន្តការគាំទ្រ និងតាមដានត្រួតពិនិត្យការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន

ស្ថាប័នដែលមានតួនាទីដ៏សំខាន់ក្នុងការគាំទ្រ តាមដានត្រួតពិនិត្យ លើការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន រួមមានដូចខាងក្រោម៖

- ក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់
- គណៈកម្មការគ្រប់គ្រងសាលារៀន។

### ៦.១. ក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ប្រកបដោយប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- រៀបចំបង្កើតនូវការទទួលខុសត្រូវបន្ថែមស្តីពីកិច្ចការពារកុមារដល់គណៈកម្មាធិការ នាយកដ្ឋាន ឬការិយាល័យពាក់ព័ន្ធដែលមានស្រាប់ នៅថ្នាក់ក្រសួង មន្ទីរ រួមទាំងការគ្រប់គ្រងទិន្នន័យ និងតាមដានការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន
- រៀបចំបង្កើតនូវសារាចរណែនាំ ប្រកាស និងសេចក្តីសម្រេចក្នុងការគាំទ្រដល់ការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀនឱ្យមានប្រសិទ្ធភាព ជាពិសេស សាលារៀននៅជនបទ សាលារៀននៅតំបន់ជនជាតិដើមភាគតិច និងសាលារៀនឯកជន។ល។
- ពង្រឹងនីតិវិធីជ្រើសរើសគ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់ រួមទាំង សាលារៀនឯកជន ដើម្បីធានាថាបុគ្គលដែលបានជ្រើសរើសមានគុណវុឌ្ឍិគ្រប់គ្រាន់ និងមិនធ្លាប់ប្រព្រឹត្តការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- រៀបចំបង្កើត និងដាក់បញ្ចូលមេរៀនស្តីពីកិច្ចការពារកុមារ តួនាទីគ្រូបង្រៀន ទៅក្នុងកម្មវិធីសិក្សានៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងបញ្ចូលមេរៀនស្តីពីវិធីការពារខ្លួនឯងពីគ្រោះថ្នាក់ផ្សេងៗ ដូចជា អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារទៅក្នុងកម្មវិធីសិក្សា
- ពង្រឹងការអនុវត្តវិន័យរដ្ឋបាល និងការអនុវត្តច្បាប់ នៅពេលមានករណីគ្រោះថ្នាក់ ឬការប្រព្រឹត្តអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ពីសំណាក់នាយក/នាយិកាសាលា បុគ្គលិកអប់រំ និងបុគ្គលិកនៅក្នុងប្រព័ន្ធអប់រំទាំងអស់
- ផ្សព្វផ្សាយនូវគោលនយោបាយ ឬសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងកិច្ចការពារកុមារដែលបង្កើតដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឬក្រសួងពាក់ព័ន្ធ ទៅក្នុងប្រព័ន្ធអប់រំទាំងអស់
- ផ្តល់ការអភិវឌ្ឍសមត្ថភាពអំពីកិច្ចការពារកុមារដល់សាលារៀន និងអ្នកពាក់ព័ន្ធ

- ចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចការពារកុមារនៅក្នុងសាលារៀន។ *សូមមើលឧបសម្ព័ន្ធទី ១០ ៖ ឧបករណ៍សម្រាប់ត្រួតពិនិត្យការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន (ទំព័រទី៦១)*
- កៀរគរធនធានពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ឬសប្បុរសជនក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងសាលារៀន និងការពង្រឹងសមត្ថភាពដល់បុគ្គលិកអប់រំ និងគ្រូបង្រៀន។

## ៦.២. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

ដើម្បីអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ប្រកបដោយប្រសិទ្ធភាព មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- រៀបចំតួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀនទៅដល់មន្ត្រីដែលពាក់ព័ន្ធ ដូចជា អនុប្រធានមន្ទីរទទួលបន្ទុកការិយាល័យបឋម ការិយាល័យអធិការកិច្ច ការិយាល័យសុខភាពសិក្សា ការិយាល័យអប់រំក្រៅប្រព័ន្ធ ការិយាល័យអប់រំពិសេស ។ល។
- ពង្រឹងសមត្ថភាពនាយក/នាយិកាសាលា និងគ្រូបង្រៀននៅតាមសាលារៀនអំពីសេចក្តីណែនាំ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងកិច្ចការពារកុមារ
- តាមដានត្រួតពិនិត្យជាប្រចាំការអនុវត្តនូវវិធីសាស្ត្រនៃការដាក់វិន័យតាមបែបវិជ្ជមាន និងការអនុវត្តរបស់ក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី ស្របតាមសិទ្ធិកុមារ សមភាពយេនឌ័រ សមធម៌យេនឌ័រ និងបរិយាបន្ន និងគាំទ្រដល់សាលារៀនបន្ថែមទៀតក្នុងការបំពេញចំណុចខ្វះខាតផ្សេងៗ
- ដាក់ចេញនូវសេចក្តីណែនាំ ឬសេចក្តីសម្រេចចាំបាច់ទៅដល់សាលារៀននីមួយៗក្នុងការពង្រឹងការអនុវត្តកិច្ចការពារកុមារប្រកបដោយប្រសិទ្ធភាព និងជំរុញការអនុវត្តយន្តការរាយការណ៍ និងឆ្លើយតប និងរៀបចំជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន
- ពង្រឹង និងដោះស្រាយយ៉ាងមានប្រសិទ្ធភាពជាមួយអាជ្ញាធរមានសមត្ថកិច្ច និងគណៈកម្មការគ្រប់គ្រងសាលា ចំពោះបុគ្គលិកអប់រំណាដែលប្រព្រឹត្តិអំពើហិង្សា និង/ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- ផ្សារភ្ជាប់ និងកសាងទំនាក់ទំនងជាមួយមន្ទីរ និងការិយាល័យពាក់ព័ន្ធ ជាពិសេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការសម្របសម្រួលសេវាគាំទ្រដល់កុមារនៅពេលមានករណីអំពើហិង្សា និង/ឬការកេងប្រវ័ញ្ចណាមួយកើតឡើង ឬធ្វើសមាហរណកម្មកុមារបានចូលរៀនវិញ
- ចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចការពារកុមារនៅក្នុងសាលារៀន (សូមមើលឧបសម្ព័ន្ធទី១០)

- កៀរគរធនធានពីរដ្ឋបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ឬសប្បុរសជនក្នុងការអនុវត្តសកម្មភាពស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងការពង្រឹងសមត្ថភាពដល់បុគ្គលិកអប់រំទាំងអស់។

## ៦.៣. ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ

ដើម្បីអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ប្រកបដោយប្រសិទ្ធភាព ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- អនុវត្តតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន
- ដាក់បញ្ចូលរបៀបវារៈអំពីកិច្ចការពារកុមារក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់
- ចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីកិច្ចការពារកុមារនៅក្នុងសាលារៀន (សូមមើលឧបសម្ព័ន្ធទី១០)
- ចូលរួមពង្រឹងសមត្ថភាពនាយក/នាយិកាសាលា និងគ្រូបង្រៀននៅតាមសាលាអំពីសេចក្តីណែនាំ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងកិច្ចការពារកុមារ
- ចូលរួមតាមដានត្រួតពិនិត្យការអនុវត្តនូវវិធីសាស្ត្រការដាក់វិន័យតាមបែបវិជ្ជមាន និងការងារក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី ស្របតាមសិទ្ធិកុមារ សមភាពយេនឌ័រ សមធម៌យេនឌ័រ និងបរិយាបន្ន និងគាំទ្រដល់សាលាបន្ថែមទៀតក្នុងការបំពេញកង្វះខាត
- សហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីដោះស្រាយឱ្យមានប្រសិទ្ធភាពរាល់អំពើហិង្សា ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- ចូលរួមក្នុងដំណើរការសម្របសម្រួលសេវាគាំទ្រដល់កុមារនៅពេលមានករណីអំពើហិង្សា និង/ឬការកេងប្រវ័ញ្ចណាមួយកើតឡើង ឬធ្វើសមាហរណកម្មកុមារចូលទៅក្នុងសាលារៀនវិញ
- កៀរគរធនធានអំពីរដ្ឋបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ឬសប្បុរសជនក្នុងការអនុវត្តសកម្មភាពស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងការពង្រឹងសមត្ថភាពដល់បុគ្គលិកអប់រំទាំងអស់។

## ៦.៤. រដ្ឋបាលឃុំ សង្កាត់

ដើម្បីអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ប្រកបដោយប្រសិទ្ធភាព រដ្ឋបាលឃុំ សង្កាត់ មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- សហការ ចែករំលែកព័ត៌មាន និងសម្របសម្រួលជាមួយសាលារៀនអំពីការអនុវត្តសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់ និងសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន

- ចូលរួម និងសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីអប់រំផ្សព្វផ្សាយអំពីកិច្ចការពារកុមារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួម និងសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ជាពិសេសសាលារៀននៅក្នុងដែនដីរបស់ខ្លួន ដើម្បីដោះស្រាយឱ្យមានប្រសិទ្ធភាពរាល់អំពើហិង្សា ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ
- ដាក់បញ្ចូលរបៀបវារៈអំពីកិច្ចការពារកុមារក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឬកិច្ចប្រជុំ គ.ក.ន.ក. តាមការចាំបាច់
- ចូលរួមសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ក្នុងដំណើរការសម្របសម្រួលសេវាគាំទ្រដល់កុមារនៅពេលមានករណីអំពើហិង្សា ឬ/និងការកេងប្រវ័ញ្ចណាមួយកើតឡើង ឬធ្វើសមាហរណកម្មកុមារចូលទៅក្នុងសាលារៀន និងសហគមន៍វិញ។
- ចាត់តាំង អ.ក.ន.ក. ចូលរួមតាមដាន និងត្រួតពិនិត្យអំពីកិច្ចការពារកុមារនៅក្នុងសាលារៀន។

## ៦.៥. គណៈកម្មការគ្រប់គ្រងសាលារៀន

ដើម្បីអនុវត្តសៀវភៅណែនាំប្រតិបត្តិស្ដីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ប្រកបដោយប្រសិទ្ធភាព គណៈកម្មការគ្រប់គ្រងសាលារៀន មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការតាមដានត្រួតពិនិត្យប្រចាំឆ្នាំ ដោយកំណត់ សកម្មភាព ឧបករណ៍ ក្រុមគោលដៅ និងពេលវេលាជាក់លាក់ (សូមមើលឧបសម្ព័ន្ធទី១០)
- រៀបចំកិច្ចប្រជុំជាមួយជនបង្គោលកិច្ចការពារកុមារនៅក្នុងសាលារៀនប្រចាំត្រីមាស ដើម្បីពិនិត្យអំពីភាពរីកចម្រើន និងបញ្ហាប្រឈមដើម្បីដោះស្រាយទាន់ពេលវេលា ឬកែសម្រួលនូវនីតិវិធីស្ដីពីកិច្ចការពារកុមារ យន្តការរាយការណ៍ ឬយន្តការបញ្ជូន
- ដាក់បញ្ចូលកិច្ចពិភាក្សាអំពីការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀនទៅក្នុងកិច្ចប្រជុំជាមួយគ្រូបង្រៀនទាំងអស់ (យ៉ាងតិច២ដងក្នុង១ឆ្នាំ)
- ណែនាំដល់គ្រូបង្រៀនឱ្យរៀបចំកិច្ចពិគ្រោះយោបល់ជាមួយកុមារ ដោយប្រើវិធីសាស្ត្របែបកុមារមេត្រី និងជាមួយឪពុកម្ដាយ អ្នកអាណាព្យាបាល អំពីការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន និងរៀបចំរបាយការណ៍ជូននាយក/នាយិកាសាលាយ៉ាងតិច២ដងនៅក្នុង១ឆ្នាំ
- ចងក្រងជាឯកសារ រូបភាព ឬជាវីដេអូ ស្ដីពីការអនុវត្តល្អ និងចំណុចដែលគួរកែលម្អនៅក្នុងសៀវភៅណែនាំប្រតិបត្តិស្ដីពីកិច្ចការពារកុមារនៅក្នុងសាលារៀន១ឆ្នាំម្ដង ដើម្បីពង្រឹងការអនុវត្តផែនការសម្រាប់ឆ្នាំបន្ទាប់ និងចែករំលែកទៅសាលារៀនដទៃទៀត។
- សហការ ចែករំលែកព័ត៌មាន និងសម្របសម្រួលជាមួយរដ្ឋបាលឃុំ សង្កាត់អំពីការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្ដីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងសៀវភៅណែនាំស្ដីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់

- ផ្សព្វផ្សាយឱ្យបានទូលំទូលាយស្ដីពីកិច្ចការពារកុមារក្នុងសាលារៀន ដល់បុគ្គលិកសាលារៀន គ្រូបង្រៀន អ្នកសហគមន៍ និងអ្នកពាក់ព័ន្ធនានា
- រៀបចំបន្ទប់ពិគ្រោះយោបល់សម្រាប់កុមារា និងកុមារី
- រៀបចំចងក្រង និងទុកដាក់ឯកសារស្ដីពីកិច្ចការពារកុមារនៅក្នុងសាលារៀនក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសាលារៀន។

**ឧបសម្ព័ន្ធទី ១ ÷ គំរូមាតិកានៃនីតិវិធីកិច្ចការពារកុមារនៅក្នុងសាលារៀន**

សាលារៀននីមួយៗ គួររៀបចំនីតិវិធីជាប្រព័ន្ធសម្រាប់កិច្ចការពារកុមារនៅក្នុងសាលារៀន ដែលមានមាតិកា ដូចខាងក្រោម៖

១. និយមន័យ (អំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ កិច្ចការពារកុមារ និងអ្នកពាក់ព័ន្ធ)

២. គោលបំណង គោលដៅ និងគោលការណ៍ណែនាំសម្រាប់អនុវត្តនីតិវិធីស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន

៣. ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់បុគ្គលិកសាលារៀន គ្រូបង្រៀន អ្នកស្ម័គ្រចិត្ត ភ្ញៀវ និងអ្នកពាក់ព័ន្ធ

៤. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន

៥. យន្តការបង្ការ និងពង្រឹងសមត្ថភាពដល់បុគ្គលិកសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស

៦. យន្តការរាយការណ៍ក្នុងសាលារៀន និងយន្តការរាយការណ៍របស់អាជ្ញាធរមូលដ្ឋាន

៧. ការឆ្លើយតបស្របតាមប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា

៨. យន្តការបញ្ជូនទៅរកសេវាគាំទ្រ

៩. ការគ្រប់គ្រងឯកសារករណី និងនីតិវិធីថតរូបកុមារ

១០. ការត្រួតពិនិត្យតាមដាន និងកែសម្រួល

- ឧបសម្ព័ន្ធចាំបាច់នានា

**សម្គាល់៖** មាតិកាអាចប្រែប្រួលបន្តិចបន្តួចទៅតាមបរិបទ និងស្ថានភាពរបស់សាលារៀននីមួយៗ ជាពិសេសសាលារៀននៅតំបន់ជនបទ សាលារៀននៅសហគមន៍ជនជាតិដើមភាគតិច សាលារៀននៅតំបន់ដែលមិនសូវមានសេវាគាំទ្រកិច្ចការពារកុមារ ។ល។

## ឧបសម្ព័ន្ធទី ២.ក ÷ គំរូក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់បុគ្គលិកសាលារៀន

មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត.................
សាលារៀន......................................................

### សេចក្តីប្រកាសនៃក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ

សាលារៀន................................. ជឿជាក់ថា កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារពីអំពើហិង្សា (ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ការមិនអើពើ) ការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងការគ្រោះថ្នាក់ផ្សេងៗ។ កុមារគួរទទួលបានចំណេះដឹងអំពីសិទ្ធិក្នុងការទទួលបានកិច្ចការពារផងដែរ។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................ភេទ.........តួនាទី.......................................
នៅក្នុងសាលារៀន..............................................................ភូមិ.........................................
ឃុំ សង្កាត់.....................ក្រុង ស្រុក ខណ្ឌ............................រាជធានី ខេត្ត.............................។

ខ្ញុំបាទ/នាងខ្ញុំបានទទួលការណែនាំ និងបានយល់ដឹងពីខ្លឹមសារនៃនីតិវិធីស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន គោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ។ ខ្ញុំបាទ/នាងខ្ញុំយល់ព្រម និងអនុវត្តតាមក្រមសីលធម៌នេះ ទាំងក្នុងការគ្រប់គ្រង ការងារបង្រៀនប្រចាំថ្ងៃ និងសកម្មភាពដែលមានការចូលរួមពីសិស្សានុសិស្សទាំងក្នុង និងក្រៅសាលារៀន ដើម្បីធានាថា កុមារា កុមារី ដែលជាសិស្សានុសិស្សទាំងអស់ទទួលបាននូវសុវត្ថិភាពពេញលេញ។ ក្នុងករណីដែលខ្ញុំបាទ/នាងខ្ញុំ ប្រព្រឹត្តល្មើសនឹងក្រមសីលធម៌នេះ ខ្ញុំបាទ/នាងខ្ញុំព្រមទទួលទណ្ឌកម្មទៅតាមវិន័យរដ្ឋបាលរបស់សាលារៀន ឬតាមនីតិវិធីច្បាប់។

### ១. ទង្វើសមរម្យដែលត្រូវប្រព្រឹត្ត

- ធានាថារាល់ការប្រាស្រ័យទាក់ទងជាមួយកុមារ មានសុវត្ថិភាព សមរម្យ បែបកុមារមេត្រី និងគិតគូរដល់អារម្មណ៍របស់កុមារ
- ស្តាប់យ៉ាងយកចិត្តទុកដាក់នូវមតិយោបល់ ការព្រួយបារម្ភ តម្រូវការរបស់កុមារ និងឆ្លើយតបឱ្យបានត្រឹមត្រូវ និងសមស្របដោយវិជ្ជមាន
- ផ្តល់ឱកាស លើកទឹកចិត្ត និងជួយគាំទ្រដល់កុមារទាំងអស់ ជាពិសេសដល់កុមារី កុមារពិការ កុមារជនជាតិដើមភាគតិច កុមារមិនកំណត់អត្តសញ្ញាណភេទ កុមារងាយគ្រោះដទៃទៀតឱ្យបានចូលរួមសកម្មភាពនានាយ៉ាងពេញលេញ និងទទួលបានការសិក្សាប្រកបដោយសុវត្ថិភាព និងរីករាយ
- រាយការណ៍ភ្លាមនូវរាល់ករណីសង្ស័យ ឬអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារទៅជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ស្របតាមយន្តការរាយការណ៍របស់សាលារៀន

- ផ្តល់កិច្ចសហការយ៉ាងសកម្ម និងមានសុវត្ថិភាពនៅក្នុងសកម្មភាពឆ្លើយតបករណី ឬការស៊ើបអង្កេតណាមួយដោយសាលារៀន ឬអាជ្ញាធរមានសមត្ថកិច្ច ដោយរក្សាការសម្ងាត់
- សុំការយល់ព្រមពីកុមារ ឪពុកម្តាយ និងអ្នកអាណាព្យាបាលនៅពេលអញ្ជើញកុមារចូលរួមសកម្មភាពនានា ដូចជា ពេលថតរូប ឬដកស្រង់ករណីសិក្សាណាមួយ ដោយធានាថា រូបថត និងករណីសិក្សាទាំងនោះមានលក្ខណៈសមរម្យ ហើយមិនប្រើប្រាស់នៅក្នុងសកម្មភាពមិនល្អ ឬបង្កគ្រោះថ្នាក់ដល់កុមារ។

**២. ទង្វើដែលមិនត្រូវប្រព្រឹត្ត**

- ប្រើអំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់ទម្រង់ ការដាក់ទណ្ឌកម្មលើកុមារ និងសកម្មភាព ឬឥរិយាបថគ្រោះថ្នាក់ដទៃទៀត ដែលធ្វើឱ្យកុមារឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ
- ប្រើភាសា ការផ្តល់មតិយោបល់ ឬដំបូន្មានដែលមិនសមរម្យចំពោះកុមារ ឬពាក្យសំដីបែបរំលោភបំពាន រួមមាន ភាសាដែលបណ្តាលឱ្យកុមារមានភាពខ្មាសអៀន អាម៉ាស់មុខ ប្រមាថ ការដាក់ងារ ឬអាប់អោនតម្លៃជាដើម
- សម្តែងនូវអាកប្បកិរិយាមិនសមរម្យ ដូចជា ការស្ទាបអង្អែល កាន់ ថើប អោប លូក ឬប៉ះពាល់កន្លែងឯកជនរបស់កុមារក្នុងបំណងបង្កើតទំនាក់ទំនងផ្លូវភេទជាមួយកុមារ
- នៅជាមួយកុមារតែ២នាក់ នៅកន្លែងស្ងាត់ ឬកំបាំងពីភ្នែកអ្នកដទៃ ឬអំឡុងពេលធ្វើដំណើរជាមួយកុមារ
- ចូលរួម ឬលើកទឹកចិត្តកុមារឱ្យប្រព្រឹត្តសកម្មភាពខុសច្បាប់ គ្មានសុវត្ថិភាព ឬបែបរំលោភបំពាន រួមទាំងសកម្មភាពបែបប្រពៃណី ឬជំនឿសាសនាដែលប៉ះពាល់ដល់សិទ្ធិរបស់កុមារ
- ប្រើឧបករណ៍អេឡិចត្រូនិក ឬប្រព័ន្ធអនឡាញក្នុងការមើល ទាញយក ចែកចាយ ឬបង្កើតរូបភាព ឬវីដេអូអាសអាភាស ឬមិនសមរម្យរបស់កុមារ។

ថ្ងៃ..............ខែ............ ឆ្នាំ..........ព.ស............

ធ្វើនៅ.............ថ្ងៃទី......... ខែ...........ឆ្នាំ...........

ហត្ថលេខា និងឈ្មោះ

**សម្គាល់៖** សាលារៀននីមួយៗអាចយកគំរូនេះទៅពិភាក្សា និងបង្កើតក្រមសីលធម៌ស្តីពីកិច្ចការពារកុមារស្របតាមបរិបទ និងតម្រូវការរបស់សាលារៀន។

## ឧបសម្ព័ន្ធទី ២.៦÷ គំរូក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់គ្រូ និងអ្នកមកបំពេញកិច្ចនៅសាលារៀន

មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត.............
សាលារៀន..................................................

### សេចក្តីប្រកាសនៃក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ

សាលារៀន................................. ជឿជាក់ថា កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារពីអំពើហិង្សា (ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ការមិនអើពើ) ការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងការគ្រោះថ្នាក់ផ្សេងៗ។ កុមារគួរទទួលបានចំណេះដឹងអំពីសិទ្ធិក្នុងការទទួលបានកិច្ចការពារផងដែរ។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................ភេទ.........តួនាទី........................................
មកក្នុងគោលបំណង.......................................................................................................
នៅក្នុងសាលារៀន.......................................... ភូមិ.......................... ឃុំសង្កាត់......................
ក្រុង ស្រុក ខណ្ឌ....................................... រាជធានី ខេត្ត.....................................................។

ខ្ញុំបាទ/នាងខ្ញុំបានទទួលការណែនាំ និងបានយល់ដឹងពីខ្លឹមសារនៃនីតិវិធីស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន គោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ។ ខ្ញុំបាទ/នាងខ្ញុំយល់ព្រម និងអនុវត្តតាមក្រមសីលធម៌នេះ មុននិងក្នុងអំឡុងពេលទស្សនកិច្ច ដើម្បីធានាថា កុមារាកុមារីដែលជាសិស្សានុសិស្សទទួលបានសុវត្ថិភាពពេញលេញដូចខាងក្រោម។ ក្នុងករណីដែលខ្ញុំបាទ/នាងខ្ញុំប្រព្រឹត្តល្មើសនឹងក្រមសីលធម៌នេះ ខ្ញុំបាទ/នាងខ្ញុំព្រមទទួលទណ្ឌកម្មទៅតាមវិន័យរដ្ឋបាលរបស់សាលារៀន។

- ខ្ញុំមកបំពេញភារកិច្ចនៅសាលារៀនបានលុះត្រាតែមានការអនុញ្ញាត និងអញ្ជើញពីគណៈគ្រប់គ្រងសាលារៀន
- ខ្ញុំគោរពសិទ្ធិកុមារ និងមិនប្រព្រឹត្តអំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់ទម្រង់ ការដាក់ទណ្ឌកម្មលើកុមារ និងសកម្មភាព ឬឥរិយាបថគ្រោះថ្នាក់ដទៃទៀតដែលធ្វើឱ្យកុមារឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទឡើយ។
- ខ្ញុំទទួលការអមដំណើរពីគ្រូ ឬការណែនាំពីគ្រូ ឬនាយក/នាយិកាសាលា និងមិននៅទីកន្លែងស្ងាត់កំបាំងតែពីរនាក់ជាមួយកុមារ
- ខ្ញុំមិនប្រាប់កុមារពីព័ត៌មានផ្ទាល់ខ្លួន(អាសយដ្ឋានស្នាក់នៅ លេខទូរស័ព្ទ ឬអ៊ីម៉ែល ឬគណនីបណ្តាញសង្គម) ឬមិនស្នើសុំ និងផ្សព្វផ្សាយព័ត៌មានផ្ទាល់ខ្លួនរបស់កុមារណាម្នាក់ឡើយ
- ខ្ញុំមិនថតរូប វីដេអូ សំឡេង ឬរឿងរ៉ាវរបស់កុមារដោយមិនមានការសុំអនុញ្ញាតជាមុនពីកុមារ ឪពុកម្តាយ អ្នកអាណាព្យាបាលកុមារ និងគណៈគ្រប់គ្រងសាលារៀន។ ក្នុងករណីទទួលបានការអនុញ្ញាតឱ្យថតរូប ឬវីដេអូរបស់កុមារ សូមកុំថតបង្ហាញពិការភាព ឬស្ថានភាពលំបាករបស់

កុមារ ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់កុមារ និងសួរកុមារពីទីតាំងដែលពួកគេមានទំនុកចិត្តក្នុងការថតរូប

- ខ្ញុំមិនប្រើកាយវិការ ឬពាក្យសំដីមិនសមរម្យ បែបរំលោភបំពានរួមមាន ភាសាដែលបណ្តាលឲ្យកុមារមានភាពខ្មាសអៀន អាម៉ាស់មុខ ប្រមាថ ការដាក់ងារ ឬអាប់អោនតម្លៃជាដើម
- ខ្ញុំស្លៀកពាក់សម្លៀកបំពាក់ដែលសមរម្យ ក្នុងអំឡុងពេលទស្សនកិច្ច។

ថ្ងៃ..............ខែ............ ឆ្នាំ..........ព.ស............
ធ្វើនៅ.............ថ្ងៃទី......... ខែ............ឆ្នាំ...........
ហត្ថលេខា និងឈ្មោះ

**សម្គាល់៖** សាលារៀននីមួយៗអាចយកគំរូនេះទៅពិភាក្សា និងបង្កើតក្រមសីលធម៌ស្តីពីកិច្ចការពារកុមារស្របតាមបរិបទ និងតម្រូវការរបស់សាលារៀន។

## ឧបសម្ព័ន្ធទី ៣ ៖ ការណែនាំស្តីពីការរៀបចំជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន

### ១. ការតែងតាំង និងអាណត្តិនៃជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន

សាលារៀននីមួយៗ ត្រូវរៀបចំឱ្យមានជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន តាមរយៈកិច្ចបង្គាប់ការពីនាយក/នាយិកាសាលា ឬគណៈកម្មការគ្រប់គ្រងសាលា។ ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន គួរជានាយក/នាយិការង ទទួលបន្ទុកវិន័យ ឬរដ្ឋបាល ឬបុគ្គលិកមានឥទ្ធិពលក្នុងការទំនាក់ទំនងជាមួយបុគ្គលិកសាលារៀន និងគ្រូបង្រៀននៅក្នុងសាលារៀន។ អាណត្តិរបស់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ត្រូវកំណត់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យមានការចូលរួម និងស្ម័គ្រចិត្តក្នុងការអនុវត្តតួនាទីនេះ។ ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ត្រូវបានលើកទឹកចិត្តពីគណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ព្រមទាំងទទួលបាននូវការបណ្តុះបណ្តាលសំខាន់ៗពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ជាប្រចាំក្នុងការអនុវត្តតួនាទី ភារកិច្ចទាំងនោះ។

### ២. ប្រធានបទសម្រាប់ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន

- សិទ្ធិកុមារ ការចូលរួមរបស់កុមារ កិច្ចការពារកុមារ ប្រព័ន្ធកិច្ចការពារកុមារ សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ព្រមទាំងច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា
- ការរៀបចំ និងអនុវត្តយន្តការរាយការណ៍ យន្តការឆ្លើយតប និងការរៀបចំឯកសារស្តីពីការគ្រប់គ្រងករណី
- ការបង្ការ និងឆ្លើយតបកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ ជំងឺឆ្លង និងការគាំទ្រសុខភាពផ្លូវចិត្ត និងសង្គមសម្រាប់កុមារដែលស្ថិតក្នុងហានិភ័យ ឬក្នុងស្ថានភាពអាសន្ន។
- ។ល។

### ៣. តួនាទី និងការទទួលខុសត្រូវជារួម របស់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន

- សិក្សាពីហានិភ័យផ្សេងៗនៃអំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់ទម្រង់ កិច្ចការពារកុមារ និងរៀបចំសកម្មភាពទប់ស្កាត់ ដោយមានការគាំទ្រពីគណៈកម្មការគ្រប់គ្រងសាលារៀន
- ផ្តល់ការគាំទ្រ និងដំបូន្មានក្នុងការដោះស្រាយបញ្ហានានាទាក់ទងនឹងកិច្ចការពារកុមារដែលបានកើតឡើង ព្រមទាំងជូនដំណឹងទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ចនៅពេលករណីប្រព្រឹត្តដោយគណៈកម្មការគ្រប់គ្រងសាលារៀន
- ទំនាក់ទំនងជាប្រចាំជាមួយរដ្ឋបាលឃុំ សង្កាត់ជាពិសេស ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ (អ.ក.ន.ក.) អាជ្ញាធរមូលដ្ឋាន ឬអ្នកផ្តល់សេវាគាំទ្រនានាក្នុងការធ្វើបច្ចុប្បន្នភាពស្ថានភាពកុមារ

- ចូលរួមកិច្ចប្រជុំរបស់គណៈកម្មការពាក់ព័ន្ធរបស់សាលា ដើម្បីពង្រឹងកិច្ចការពារកុមារនៅក្នុងរបៀបវារៈ ដោយមានការគាំទ្រពីនាយក/នាយិកាសាលា
- ចងក្រងបញ្ជីទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេស អ.ក.ន.ក. អ្នកផ្តល់សេវា និងអង្គការសង្គមស៊ីវិល ដើម្បីពង្រឹង និងដោះស្រាយករណីកិច្ចការពារកុមារនៅក្នុងសាលារៀន
- រក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់កុមារ ទាំងកុមាររងគ្រោះ និងកុមារបង្ក ចុះបញ្ជី កត់ត្រាករណី និងរក្សាឯកសារនៅកន្លែងមានសុវត្ថិភាព
- អនុវត្តតួនាទីភារកិច្ច ចាំបាច់បន្ថែមទៀតដែលមានចែងនៅក្នុងសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងតម្រូវការជាក់ស្តែងរបស់សាលារៀន។

## ឧបសម្ព័ន្ធទី ៤ ៖ ឯកសារជំនួយសម្រាប់គាំទ្រសុខភាពផ្លូវចិត្តដល់កុមារ

កុមារអាចឆ្លងកាត់ពិសោធន៍ និងអារម្មណ៍មិនល្អជាច្រើន ដោយសារបងប្អូន ឪពុកម្តាយ អ្នកអាណាព្យាបាល មិត្តភក្តិ បុគ្គលិកសាលារៀន គ្រូបង្រៀន នាយក/នាយិកាសាលា និងមជ្ឈដ្ឋានជុំវិញរបស់ពួកគេ។ កុមារប្រហែលអាចរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់។

ហេតុនេះគ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលា និងបុគ្គលិកសាលារៀន ត្រូវសិក្សាឈ្វេងយល់ អង្កេតពីសិស្សានុសិស្ស និងការជួយគាំទ្រផ្លូវចិត្តដល់កុមារ ដូចខាងក្រោម៖

### ១. អាកប្បកិរិយារបស់កុមារដែលអាចមានបញ្ហាផ្លូវចិត្ត

- ងងុយគេង ព្រោះពួកគេអាចពិបាកគេង ឬសុបិនអាក្រក់ច្រើននៅពេលយប់
- ភ័យខ្លាច ឆាប់ភ្ញាក់ មមើមមាយ
- មិនចង់និយាយស្តី
- ឆាប់ខឹង និងធុញថប់ជាមួយមិត្តភក្តិ និងអ្នកដទៃ
- មានអារម្មណ៍ហេវហត់ អស់កម្លាំង
- គ្មានការផ្ចង់អារម្មណ៍រៀនសូត្រ និងលទ្ធផលនៃការសិក្សាធ្លាក់ចុះ
- ត្អូញត្អែរពីការឈឺពោះ ឬឈឺក្បាល
- ចាប់ផ្តើមបញ្ចេញអាកប្បកិរិយាក្មេងជាងអាយុ
- បញ្ចេញអាកប្បកិរិយាគ្មានឯករាជ្យភាព
- លែងសូវចាប់អារម្មណ៍ក្នុងការលេង ឬសកម្មភាពកម្សាន្តផ្សេងៗ
- ចូលចិត្តនៅតែឯង និងមិនចូលចិត្តមិត្តភក្តិមកលេងជាមួយ
- និយាយពាក្យសម្តីប្លែក ឬអាចពាក់ព័ន្ធនឹងការរួមភេទ
- មករៀនមិនទៀងទាត់ (មករៀនលឿន ចេញលឿន មករៀនយឺត ចេញក្រោយគេ ។ល។)
- ក្រៀមក្រំ ឆាប់តូចចិត្ត សោកសៅ យំច្រើនខុសពីធម្មតា និងគ្មានហេតុផល។

### ២. តម្រូវការយល់ដឹងពីគណៈកម្មការគ្រប់គ្រងសាលា គ្រូបង្រៀន និងបុគ្គលិកសាលារៀន

- អាកប្បកិរិយាទាំងនោះគឺជាការឆ្លើយតបទូទៅ និងធម្មតារបស់កុមារ ដែលអាចមានការប្រែប្រួលអារម្មណ៍ ឬអាកប្បកិរិយា នៅពេលពួកគេបានឆ្លងកាត់ព្រឹត្តិការណ៍ដែលធ្វើឱ្យពួកគេមានការឈឺចាប់ ឬមានការតានតឹងផ្លូវចិត្ត ឬផ្លូវអារម្មណ៍
- គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ និងស្តាប់នូវកង្វល់របស់កុមារដែលបានឆ្លងកាត់បទពិសោធន៍បណ្តាលឱ្យពួកគេមានការតានតឹងផ្លូវអារម្មណ៍/ផ្លូវចិត្ត ព្រមទាំងផ្តល់មតិយោបល់ក្នុងការស្វែងរកដំណោះស្រាយ ឬបញ្ជូនកុមារទៅរកសេវាគាំទ្រដែលសមស្រប សម្រាប់ពួកគេ ដោយមានការឯកភាពពីកុមារ ឪពុកម្តាយ និងអ្នកអាណាព្យាបាលកុមារ។

**៣. គណៈកម្មការគ្រប់គ្រងសាលា ឬនាយក/នាយិកាសាលា**

- ត្រូវទាក់ទងអ្នកជំនាញដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀន បុគ្គលិកសាលារៀន ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន អំពីការផ្តល់ប្រឹក្សាផ្លូវចិត្តបឋម
- ត្រូវទាក់ទងទូរស័ព្ទជំនួយកុមារលេខ១២៨០ សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័នដៃគូពាក់ព័ន្ធនានា ក្នុងការផ្តល់សេវាប្រឹក្សាផ្លូវចិត្តដល់បុគ្គលិកសាលារៀន និងកុមារ
- ត្រូវផ្តល់ការគាំទ្រផ្នែកសង្គមដល់បុគ្គលិកសាលារៀន និងសិស្សានុសិស្ស ដើម្បីឱ្យពួកគេចេះវិធីសាស្ត្រក្នុងការទប់ទល់នឹងជំងឺធ្លាក់ទឹកចិត្ត ចេះគ្រប់គ្រងការថប់អារម្មណ៍ ដូចជា ការរស់នៅដាច់ដោយឡែក និងការរស់នៅក្នុងកន្លែងដែលមិនមានសុវត្ថិភាព
- ត្រូវបន្តណែនាំបុគ្គលិកសាលារៀន និងសិស្សានុសិស្សក្នុងសាលារៀន ឱ្យចេះ ឬអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អដោយមិនត្រូវស្ថិតនៅក្រោមទស្សនៈ «ភ័យខ្លាច និងរើសអើង» ដែលអាចធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ
- រៀបចំបន្ទប់សម្រាប់ផ្តល់ប្រឹក្សាផ្លូវចិត្ត ឬនិងបន្ទប់ពិគ្រោះយោបល់សម្រាប់កុមារា កុមារី តាមបែបកុមារមេត្រី។

**៤. គ្រូបង្រៀន**

- លើកកម្ពស់បរិយាកាសរៀនសូត្រប្រកបដោយការគាំទ្រ ព្រោះវាជាគន្លឹះក្នុងការជួយកុមារឱ្យបញ្ចេញអារម្មណ៍តានតឹង ឈឺចាប់ និងយកឈ្នះទុក្ខសោកទាំងនោះ
- បង្កើតសកម្មភាពសិល្បៈ កីឡា ល្បែងសិក្សា ដើម្បីកាត់បន្ថយភាពតានតឹងផ្លូវចិត្តរបស់កុមារ
- យកចិត្តទុកដាក់ទៅលើអាកប្បកិរិយា និងអារម្មណ៍របស់កុមារ
- ស្តាប់យ៉ាងយកចិត្តទុកដាក់ និងឆ្លើយតបតាមតម្រូវការរបស់កុមារ
- ផ្តល់អាទិភាពដល់ការគាំទ្រសុខុមាលភាពសង្គម និងដោះស្រាយបញ្ហាផ្លូវចិត្តរបស់សិស្ស ជាជាងលទ្ធផលនៃការសិក្សា ក្នុងអំឡុងពេលដែលកុមារកំពុងមានវិបត្តិ។
- អាចសម្គាល់អាកប្បកិរិយា ឬសញ្ញាភាពតានតឹងធ្ងន់ធ្ងរ និងសហការជាមួយឪពុកម្តាយ អ្នកអាណាព្យាបាល ដើម្បីចែករំលែកបញ្ហាទាក់ទងនឹងសុខុមាលភាពរបស់កុមារ និងលទ្ធភាពដែលអាចវិលមករកភាពធម្មតាឡើងវិញ។

## ឧបសម្ព័ន្ធទី ៥ ៖ ទម្រង់សិក្សា និងកាត់បន្ថយហានិភ័យកិច្ចការពារកុមារ

សាលាបឋមសិក្សាឈ្មោះ........................................................ នៅភូមិ..................................
ឃុំ សង្កាត់............................ ក្រុង ស្រុក ខណ្ឌ............................. រាជធានី ខេត្ត....................

| ហានិភ័យដែលអាចកើតមាន | កុមារ ឬក្រុមកុមារប្រភេទណាដែលមានហានិភ័យខ្ពស់ | សកម្មភាពបង្ការ និងកាត់បន្ថយហានិភ័យ | អ្នកទទួលខុសត្រូវ | ពេលវេលា | | |
|---|---|---|---|---|---|---|
| | | | | មុនពេល | អំឡុងពេល | ក្រោយពេល |
| ហានិភ័យពីអំពើហិង្សា និងកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារក្នុងសាលារៀន | | | | | | |
| ហានិភ័យលើការធ្វើដំណើរ ទីកន្លែងការស្នាក់នៅ សម្ភារ និងអាហារ | | | | | | |
| ហានិភ័យផ្នែកសុខភាព | | | | | | |
| ហានិភ័យផ្នែកសន្តិសុខ និងសុវត្ថិភាព | | | | | | |
| ហានិភ័យពីឥរិយាបថរបស់កុមារដទៃ | | | | | | |
| ហានិភ័យពីឥរិយាបថរបស់គ្រូបង្រៀន និងអ្នកមើលថែកុមារ | | | | | | |
| ហានិភ័យដទៃទៀត ................................. | | | | | | |

រៀបចំដោយ៖ ឈ្មោះ............................. ហត្ថលេខា....................កាលបរិច្ឆេទ..........................
យល់ព្រមពីនាយក/នាយិកាសាលា៖ ឈ្មោះ.................ហត្ថលេខា...............កាលបរិច្ឆេទ...............

**សម្គាល់៖** ទម្រង់នេះនឹងត្រូវធ្វើជាប្រចាំឆ្នាំសម្រាប់សាលារៀននីមួយៗ និងនៅរាល់ពេលរៀបចំសកម្មភាពដែលមានកុមារចូលរួម ឬអញ្ជើញកុមារទៅចូលរួមសកម្មភាពនានានៅខាងក្រៅសាលាដែលសម្របសម្រួលដោយគណៈគ្រប់គ្រងសាលារៀន។

## ឧបសម្ព័ន្ធទី ៦ ÷ ទម្រង់នៃការយល់ព្រមឯកភាពពីកុមារ ឪពុកម្ដាយ និងអ្នកអាណាព្យាបាល

សាលាបឋមសិក្សាឈ្មោះ...................................................... នៅភូមិ............................
ឃុំ សង្កាត់........................... ក្រុង ស្រុក ខណ្ឌ............................ រាជធានី ខេត្ត.........................
១. ឈ្មោះកុមារដែលត្រូវចូលរួម......................................រៀនថ្នាក់ទី......... ភេទ......... អាយុ........ឆ្នាំ
២. ឈ្មោះឪពុកម្ដាយ ឬអ្នកអាណាព្យាបាលកុមារ......................................... ភេទ....... អាយុ........ឆ្នាំ
អាសយដ្ឋាន.........................................................................................................................
លេខទូរស័ព្ទ...................... បានយល់ព្រមអនុញ្ញាតឱ្យកូនៈ ចូលរួមសកម្មភាព ថតរូប ថតសំឡេង ដកស្រង់ជាករណីសិក្សា ដែលមិនប៉ះពាល់ដល់ភាពថ្លៃថ្នូរ និងកិត្តិយសកុមារ សម្រាប់គោលបំណងប្រើប្រាស់នៅក្នុងសកម្មភាពដែលជួយដល់ការអភិវឌ្ឍសង្គម និងលើកកម្ពស់សិទ្ធិ និងសុខុមាលភាពរបស់កុមារដទៃទៀត។
៣. ព័ត៌មានអំពីសកម្មភាពដែលត្រូវនាំកុមារទៅចូលរួម.................................................................

.......................................................................................................................................
៤. ទីកន្លែងសកម្មភាព.........................................................................................................
៥. រយៈពេលនៃការចូលរួមសកម្មភាពចំនួន.....ថ្ងៃ ចាប់ពីថ្ងៃទី.....ខែ...... ទៅដល់ថ្ងៃ......ខែ....... ឆ្នាំ.......
៦. ព័ត៌មានពីស្ថាប័នរៀបចំសកម្មភាព...........................................................................................

.......................................................................................................................................
៧. អ្នករៀបចំសកម្មភាពឈ្មោះ............................................ លេខទូរស័ព្ទ.................................

កាលបរិច្ឆេទៈ............................................
ស្នាមមេដៃ និងឈ្មោះរបស់កុមារ ស្នាមមេដៃ និងឈ្មោះឪពុកម្ដាយ ឬអ្នកអាណាព្យាបាល

................................................ ................................................

**សម្គាល់៖** ទម្រង់នេះនឹងត្រូវប្រើប្រាស់សម្រាប់អញ្ជើញកុមារទៅចូលរួមសកម្មភាពនានា ដែលសម្របសម្រួលដោយគណៈគ្រប់គ្រងសាលារៀននៅខាងក្រៅសាលារៀន ដូចជា នៅក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តផ្សេងៗ ឬក្រៅប្រទេស។

## ឧបសម្ព័ន្ធទី ៧ ÷ ឧម្រង់នៃការយល់ព្រមពីអ្នកមើលថែកុមារ

សាលាបឋមសិក្សាឈ្មោះ....................................................នៅភូមិ..............................
ឃុំ សង្កាត់........................... ក្រុង ស្រុក ខណ្ឌ............................. រាជធានី ខេត្ត........................
១. ឈ្មោះកុមារដែលត្រូវចូលរួម..................................រៀនថ្នាក់ទី......... ភេទ.......... អាយុ...........
២. ព័ត៌មានអំពីសកម្មភាពដែលត្រូវនាំកុមារទៅចូលរួម....................................................................
...................................................................................................................................
៣. ទីកន្លែងសកម្មភាព.................................................................................................................
៤. រយៈពេលនៃការចូលរួមសកម្មភាពចំនួន......ថ្ងៃ ចាប់ពីថ្ងៃទី......ខែ.......ទៅដល់ថ្ងៃ.......ខែ......ឆ្នាំ......
៥. ព័ត៌មានពីស្ថាប័នរៀបចំសកម្មភាព..............................................................................................
៦. អ្នករៀបចំសកម្មភាពឈ្មោះ................................................ លេខទូរស័ព្ទ.............................
៧. ឈ្មោះអ្នកមើលថែកុមារ.................................... ភេទ....... អាយុ......ឆ្នាំ តួនាទី.......................
អាសយដ្ឋាន.........................................................................លេខទូរស័ព្ទ........................

**បានយល់ព្រមទៅតាមកាតព្វកិច្ចរបស់អ្នកមើលថែកុមារដូចខាងក្រោម៖**

- ***កាតព្វកិច្ចត្រូវធ្វើ៖***
  - ផ្តល់នូវការលើកទឹកចិត្តកុមារឱ្យចូលរួម និងធ្វើដំណើរដោយសុវត្ថិភាព
  - ផ្តល់ឱកាសស្មើគ្នាដល់កុមារក្នុងការចែករំលែកនូវគំនិតរបស់ពួកគេនៅពេលធ្វើដំណើរ
  - ស្វែងរកកន្លែង ឬមធ្យោបាយធ្វើដំណើរដែលមានសុវត្ថិភាព និងផាសុកភាពសម្រាប់កុមារ
  - ការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ការកេងប្រវ័ញ្ច រាយការណ៍ និងបញ្ជូនកុមារទៅរកសេវាគាំទ្រដែលសមស្រប
  - សម្របសម្រួលទំនាក់ទំនងរវាងកុមារជាមួយនឹងគ្រួសារពួកគេនៅពេលមានតម្រូវការពីកុមារ
  - ស្នើសុំ ឬជួយបកប្រែភាសាសម្រាប់កុមារនៅពេលមានតម្រូវការនៅអំឡុងពេលនៃការចូលរួម
  - ស្នើសុំទៅអ្នករៀបចំជាបន្ទាន់នៅពេលមានតម្រូវការចាំបាច់សម្រាប់កុមារដែលចូលរួម ជាពិសេសសម្រាប់កុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច កុមារងាយរងគ្រោះ និងកុមាររងគ្រោះ ។ល។

- ***កាតព្វកិច្ចមិនត្រូវធ្វើ ៖***
  - វាយដំ ឬរំលោភបំពានលើរាងកាយ ផ្លូវចិត្ត ដល់កុមារ
  - បង្កើតទំនាក់ទំនង ឬបង្ហាញអាកប្បកិរិយាដែលបំពានផ្លូវកាយ ផ្លូវភេទលើកុមារ
  - បង្កើតទំនាក់ទំនងជាមួយកុមារ ដែលអាចចាត់ទុកថាជាការកេងប្រវ័ញ្ច ឬការរំលោភបំពាន
  - ប្រព្រឹត្តសកម្មភាពដែលអាចជាការរំលោភបំពាន ឬធ្វើឱ្យកុមារប្រឈមនឹងហានិភ័យនៃការរំលោភបំពាន

- ប្រើប្រាស់ភាសា ផ្តល់គំនិតយោបល់ ដំបូន្មានដែលមានលក្ខណៈមិនសមស្រប វាយប្រហារ ឬការរំលោភបំពាន
- គេងក្នុងបន្ទប់ ឬគ្រែជាមួយកុមារតែ២នាក់(អាចធ្វើបានតែក្នុងករណីចាំបាច់ និងមានការអនុញ្ញាតពីជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន ឪពុកម្តាយ និងអ្នកអាណាព្យាបាល)
- ថតរូបកុមារ និងយកទៅប្រើប្រាស់នៅក្នុងគោលបំណងផ្ទាល់ខ្លួន ឬធ្វើជាអំពើខុសច្បាប់
- ប្រព្រឹត្តសកម្មភាពរំលោភបំពានផ្លូវចិត្តលើកុមារដូចជា ធ្វើឱ្យមានការអៀនខ្មាស អាម៉ាស់ ការដាក់ងារ ឬអាប់អោនតម្លៃជាដើម
- អសកម្មក្នុងការរាយការណ៍ នូវសកម្មភាពការរំលោភបំពានលើកុមារដល់អាជ្ញាធរមានសមត្ថកិច្ច ឬអ្នករៀបចំសកម្មភាព។

កាលបរិច្ឆេទ៖....................................

| | |
|---|---|
| ស្នាមមេដៃ និងឈ្មោះអ្នកមើលថែទាំ | ស្នាមមេដៃ និងឈ្មោះនាយក/នាយិកាសាលា |
| ................................................ | ...................................................... |
| ស្នាមមេដៃ និងឈ្មោះរបស់កុមារ | ស្នាមមេដៃ និងឈ្មោះរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល |
| ............................................... | ..................................................... |

**សម្គាល់៖** ទម្រង់នេះនឹងត្រូវប្រើប្រាស់សម្រាប់អញ្ជើញកុមារទៅចូលរួមសកម្មភាពនានា ដែលសម្របសម្រួលដោយគណៈគ្រប់គ្រងសាលារៀននៅខាងក្រៅសាលារៀន ដូចជា នៅក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តផ្សេងៗ ឬក្រៅប្រទេស។

**ឧបសម្ព័ន្ធទី ៨ ÷ ទម្រង់ចុះបញ្ជី និងបញ្ជូនករណី**

សាលាបឋមសិក្សាឈ្មោះ..............................................នៅភូមិ..................................
ឃុំ សង្កាត់............................ ក្រុង ស្រុក ខណ្ឌ........................... រាជធានី ខេត្ត......................

## ទម្រង់ចុះបញ្ជី និងបញ្ជូនករណី

| |
|---|
| **១. ព័ត៌មានពីកុមារ** |
| ឈ្មោះកុមារ.........................................ភេទ ☐ប្រុស ☐ស្រី ☐ មិនកំណត់អត្តសញ្ញាណភេទ<br>លេខកូដចុះបញ្ជី( * )..................................................................................................<br>កាលបរិច្ឆេទចុះបញ្ជី...................................................................................................... |
| ថ្ងៃខែឆ្នាំកំណើត.................................................................................................................. |
| ជនជាតិ.............................................កម្រិតវប្បធម៌...................................................... |
| ស្ថានភាពជាក់ស្តែងរបស់កុមារ៖ ☐កុមារមានពិការភាព ☐កុមារជនជាតិដើមភាគតិច<br>☐ កុមារមិនចេះភាសាខ្មែរ បើមានពិការភាព ឬជនជាតិដើមភាគតិច ឬភាសាដែលកុមារចេះ<br>សូមបញ្ជាក់.................................................................................................................. |
| ឈ្មោះ...........................................................☐ឪពុក ☐ឬម្តាយ ☐ឬអ្នកអាណាព្យាបាល<br>មុខរបរ............... ............អាសយដ្ឋាន.......................................................................<br>លេខទូរស័ព្ទ.................................................................................................................. |
| **២. ពិពណ៌នាអំពីករណីដែលកើតឡើង** |
| ទទួលរងនូវអំពើ *(អាចគូសបានច្រើនជាង១)* ☐អំពើហិង្សាផ្លូវកាយ ☐អំពើហិង្សាផ្លូវចិត្ត ☐អំពើហិង្សាផ្លូវភេទ<br>☐ការមិនអើពើ ☐ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ☐ការបង្ខំឱ្យប្រើប្រាស់ ឬជួញដូរគ្រឿងញៀន ឬស្រវឹង<br>☐ការជួញដូរកុមារ ☐អាពាហ៍ពិពាហ៍ដោយបង្ខំ ☐អំពើហិង្សាដទៃទៀត<br>សូមបញ្ជាក់.................................................................................................................. |
| ទីកន្លែងកើតហេតុ.............................................................................................................. |
| ពេលវេលាកើតហេតុ នៅម៉ោង.......................នៅថ្ងៃខែឆ្នាំ.................................................... |
| ស្ថានភាពជនសង្ស័យ អាយុ......................ភេទ ☐ប្រុស ☐ស្រី ☐មិនកំណត់អត្តសញ្ញាណភេទ<br>អាសយដ្ឋាន....................................................................................................................<br>ត្រូវជា ☐ឪពុក ☐ឬម្តាយ ☐ឬសាច់ញាតិ ☐ឬគ្រូបង្រៀន ☐ឬនាយក/នាយិកាសាលា<br>☐ឬបុគ្គលិកសាលារៀន ☐ឬអ្នកដទៃ សូមបញ្ជាក់.................................................................. |
| សង្ខេបអំពីហេតុការណ៍ដែលបានកើតឡើងជាក់ស្តែង...........................................................<br>.......................................................................................................................................<br>.......................................................................................................................................<br>....................................................................................................................................។ |

| ៣. ការឆ្លើយតបរបស់សាលារៀន |
|---|
| កាលបរិច្ឆេទឆ្លើយតប...........................................................................................................<br>សង្ខេបអំពីការឆ្លើយតបរបស់សាលារៀន..........................................................................................<br>.........................................................................................................................................<br>.........................................................................................................................................<br>......................................................................................................................................... |
| ៤. ការបញ្ជូនករណី |
| កាលបរិច្ឆេទបញ្ជូន................................................................................................................<br>ឈ្មោះអ្នកបញ្ជូន.............................ភេទ......តួនាទី..........................លេខទូរស័ព្ទ................<br>ឈ្មោះស្ថាប័នទទួល.......................................... អាសយដ្ឋាន...............................................<br>...............................................................................................លេខទូរស័ព្ទ......................<br>ឈ្មោះបុគ្គលិកដែលទទួល..................................ភេទ..........តួនាទី.......................................<br>លេខទូរស័ព្ទ.........................................................................................................................<br>មូលហេតុនៃការបញ្ជូន.............................................................................................................<br>.........................................................................................................................................<br>យោបល់របស់កុមារ ឪពុកម្ដាយ និងអ្នកអាណាព្យាបាលអំពីបញ្ហា និងតម្រូវការ...............................<br>.........................................................................................................................................<br>សេវាគាំទ្រដែលស្នើសុំ..............................................................................................................<br>......................................................................................................................................... |
| ហត្ថលេខា និងឈ្មោះអ្នកចុះបញ្ជី ហត្ថលេខា និងឈ្មោះអ្នកបញ្ជូន<br><br>ហត្ថលេខា និងឈ្មោះនាយក/នាយិកាសាលា |

សម្គាល់៖ (*) របៀបដាក់លេខកូដចុះបញ្ជី ត្រូវប្រើ លេខបីខ្ទង់/ឆ្នាំ/ឈ្មោះអក្សរកាត់សាលារៀន។ ឧទាហរណ៍៖ ០០១/២០២២/សបស។ ការដាក់លេខកូដចុះបញ្ជីនេះនឹងមានការណែនាំពីក្រសួងអប់រំ យុវជន និងកីឡា។

**ឧបសម្ព័ន្ធទី ៩÷ ទម្រង់បច្ចុប្បន្នភាពពីស្ថានភាពកុមារ**

សាលាបឋមសិក្សាឈ្មោះ........................................................នៅភូមិ...................................
ឃុំ សង្កាត់...............................ក្រុង ស្រុក ខណ្ឌ............................. រាជធានី ខេត្ត.....................

## ទម្រង់បច្ចុប្បន្នភាពពីស្ថានភាពកុមារ

១. កាលបរិច្ឆេទនៃការធ្វើបច្ចុប្បន្នភាព៖.........................................................................................
២. ឈ្មោះកុមារ(ឬលេខកូដចុះបញ្ជី )........................................................ភេទ.......អាយុ.......ឆ្នាំ
៣. ឈ្មោះឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាល.................................ភេទ....លេខទូរស័ព្ទ................
៤. ឈ្មោះស្ថាប័នទទួល..........................................អាសយដ្ឋាន................................................
..........................................................................................................លេខទូរស័ព្ទ.........................
៥. ឈ្មោះបុគ្គលិកដែលទទួល......................................ភេទ......តួនាទី.......................................
លេខទូរស័ព្ទ.........................................................................................................................
៦. សេវាគាំទ្រដែលកុមារបានទទួល...........................................................................................
.........................................................................................................................................
.........................................................................................................................................
៧. តម្រូវការបន្ថែមដែលកុមារត្រូវការ.........................................................................................
.........................................................................................................................................
.........................................................................................................................................
៨. សកម្មភាពគាំទ្របន្ថែមពីសាលារៀន......................................................................................
.........................................................................................................................................
....................................................................................................................................... ។

ហត្ថលេខា និងឈ្មោះអ្នកធ្វើបច្ចុប្បន្នភាព ហត្ថលេខា និងឈ្មោះនាយក/នាយិកាសាលា

## ឧបសម្ព័ន្ធទី ១០ ÷ ឧបករណ៍សម្រាប់ត្រួតពិនិត្យការអនុវត្តកិច្ចការពារកុមារនៅក្នុងសាលារៀន

កាលបរិច្ឆេទចុះត្រួតពិនិត្យ ................................... សាលារៀន.......................................
ឃុំ សង្កាត់........................... ក្រុង ស្រុក ខណ្ឌ............................ រាជធានី ខេត្ត..........................

| តារាងសូចនាករសម្រាប់ផ្ទៀងផ្ទាត់ | កម្រិតនៃការអនុវត្ត | | | សកម្មភាពដែលត្រូវអនុវត្តបន្ត |
|---|---|---|---|---|
| | មិនបាន | បានខ្លះ | បានពេញលេញ | |
| **ក. ការពិនិត្យទូទៅ** | | | | |
| ក.១. ការយល់ដឹងអំពីសៀវភៅណែនាំប្រតិបត្តិស្ដីពីកិច្ចការពារក្នុងសាលារៀនសម្រាប់បុគ្គលិកសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស | | | | |
| ក.២. ការអនុវត្តគោលការណ៍ឧត្តមប្រយោជន៍របស់កុមារក្នុងកិច្ចការពារកុមារ | | | | |
| ក.៣. ការអនុវត្តគោលការណ៍ មិនរើសអើង និងការគិតគូរជាពិសេសដល់កុមារី កុមារមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមារងាយរងគ្រោះដទៃទៀតក្នុងកិច្ចការពារកុមារ | | | | |
| ក.៤. ការអនុវត្តគោលការណ៍គោរពទស្សនៈរបស់កុមារក្នុងកិច្ចការពារកុមារ | | | | |
| ក.៥. ការអនុវត្តគោលការណ៍គោរពឯកជនភាពរបស់កុមារក្នុងកិច្ចការពារកុមារ | | | | |
| ក.៦. គោរពគោលការណ៍រក្សាការសម្ងាត់របស់កុមារ | | | | |
| **ខ. ការបង្ការ** | | | | |
| ខ.១. សាលារៀនបានបង្កើតនីតិវិធីស្ដីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងតែងតាំងជនបង្គោលទទួល | | | | |

| | | | | |
|---|---|---|---|---|
| បន្ទុកកិច្ចការពារកុមារក្នុងសាលារៀន | | | | |
| ខ.២. ការអនុវត្តតាមគោលការណ៍ ឬនីតិវិធីស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀនដែលបានបង្កើត | | | | |
| ខ.៣. ការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ជនបង្គោលទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងសាលារៀន | | | | |
| ខ.៤. ការអនុវត្តសកម្មភាពពង្រឹងសមត្ថភាពកិច្ចការពារកុមារក្នុងសាលារៀនដល់បុគ្គលិកសាលារៀន គ្រូបង្រៀន ក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី និងសិស្សានុសិស្ស | | | | |
| ខ.៥. កាអនុវត្តការផ្សព្វផ្សាយបន្តរបស់គ្រូបង្រៀនដល់សិស្សានុសិស្ស ឪពុកម្តាយ អ្នកអាណាព្យាបាល អាជ្ញាធរមានសមត្ថកិច្ច និងសហគមន៍ | | | | |
| ខ.៦. ការអនុវត្តរបស់បុគ្គលិកសាលារៀន គ្រូបង្រៀនក្នុងការបង្រៀន និងទំនាក់ទំនងបែបវិជ្ជមានជាមួយសិស្សានុសិស្ស | | | | |
| ខ.៧. ការអនុវត្តក្នុងការផ្តល់ប្រឹក្សាផ្លូវចិត្តបឋមដល់កុមារ | | | | |
| ខ.៨. ការអនុវត្តការចូលរួមរបស់កុមារប្រកបដោយសុវត្ថិភាពនៅក្នុងសាលារៀន | | | | |
| ខ.៩. ការអនុវត្តនីតិវិធីសម្រាប់ភ្ញៀវ ឬអ្នកមកទស្សនកិច្ចនៅក្នុងសាលារៀន | | | | |
| **គ. វិធីការពារ និងឆ្លើយតប** | | | | |

| | | | | |
|---|---|---|---|---|
| គ.១. ការបង្កើត និងផ្សព្វផ្សាយយន្តការរាយការណ៍របស់សាលារៀនដល់គ្រូបង្រៀន សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធ | | | | |
| គ.២. ការអនុវត្តរបស់គ្រូបង្រៀន ក្រុមប្រឹក្សាកុមារ ទីប្រឹក្សាកុមារី សិស្សានុសិស្ស ឪពុកម្តាយ និងអ្នកអាណាព្យាបាលលើយន្តការរាយការណ៍ | | | | |
| គ.៣. ការអនុវត្តវិធីកំណត់ និងវាយតម្លៃករណីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារនៅក្នុងសាលារៀន | | | | |
| គ.៤. ការអនុវត្តការឆ្លើយតបរបស់សាលារៀន | | | | |
| គ.៥. ការអនុវត្តយន្តការបញ្ជូន និងផ្តល់សេវាគាំទ្រ | | | | |
| គ.៦. ការអនុវត្តនៃការធ្វើសមាហរណកម្មកុមារចូលក្នុងសាលារៀនវិញ | | | | |
| គ.៧. ការអនុវត្តស្តីពីការបំពេញទម្រង់រាយការណ៍ បញ្ជូនករណី និងទម្រង់ដទៃទៀត ព្រមទាំងការទុកដាក់ឯកសារប្រកបដោយសុវត្ថិភាព និងរក្សាការសម្ងាត់ | | | | |
| **ឃ. វិធីការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង** | | | | |
| ឃ.១. ការអនុវត្តកិច្ចការពារកុមារនៅក្នុងការរៀបចំផែនការត្រៀមឆ្លើយតប | | | | |
| ឃ.២. ការអនុវត្តកិច្ចការពារកុមារនៅក្នុងការស្ទាបស្ទង់ និងវិភាគអំពីតម្រូវការ | | | | |

| | | | | |
|---|---|---|---|---|
| ឃ.៣. ការអនុវត្តកិច្ចការពារកុមារនៅក្នុងការរៀបចំផែនការឆ្លើយតប | | | | |
| ឃ.៤. ការអនុវត្តកិច្ចការពារកុមារនៅក្នុងការអនុវត្ត និងត្រួតពិនិត្យផែនការឆ្លើយតប | | | | |
| ឃ.៥. ការអនុវត្តកិច្ចការពារកុមារនៅក្នុងការវាយតម្លៃលើការអនុវត្តផែនការឆ្លើយតប | | | | |
| **ង. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ** | | | | |
| ង.១. កិច្ចសហការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា | | | | |
| ង.២. កិច្ចសហការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត | | | | |
| ង.៣.កិច្ចសហការគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ | | | | |
| ង.៤. កិច្ចសហការគាំទ្រពីរដ្ឋបាលឃុំ សង្កាត់ | | | | |

ការសង្កេតរបស់អ្នកចុះត្រួតពិនិត្យ

..............................................................................................................................

..............................................................................................................................

.............................................................................................................................។

មតិយោបល់ពីគ្រូបង្រៀន បុគ្គលិកសាលារៀន សិស្សានុសិស្ស ឪពុកម្ដាយ អ្នកអាណាព្យាបាល

..............................................................................................................................

..............................................................................................................................

.............................................................................................................................។

រៀបចំដោយ

ហត្ថលេខា និងឈ្មោះអ្នកចុះត្រួតពិនិត្យ

បានឃើញ និងពិនិត្យ

ហត្ថលេខា និងឈ្មោះរបស់នាយក/នាយិកាសាលា

## ឧបសម្ព័ន្ធទី ១១ ៖ សន្ទានុក្រមពាក្យគន្លឹះ

### កុមារ

កុមារ គឺជាមនុស្សគ្រប់រូបដែលមានអាយុក្រោម១៨ឆ្នាំ ស្របតាមមាត្រា១នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

### កិច្ចការពារកុមារ

កិច្ចការពារកុមារ គឺជាសកម្មភាព និងវិធានការដោយរួមបញ្ចូលនូវការទទួលខុសត្រូវគ្រប់ភាគីពាក់ព័ន្ធ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ ព្រមទាំងបញ្ជូនកុមារឱ្យទាន់ពេលវេលាទៅរក និងទទួលសេវាគាំទ្រនានាអំពីកិច្ចការពារកុមារដែលត្រឹមត្រូវ។

### សាលារៀនកុមារមេត្រី

សាលារៀនកុមារមេត្រី គឺជាសាលារៀនមួយ ដែលផ្តល់ឱកាសឱ្យកុមារបានចូលរួមក្នុងការអប់រំ និងអាចទទួលបានការយកចិត្តទុកដាក់ និងការជួយគាំទ្រពីសំណាក់អ្នកពាក់ព័ន្ធ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីឱ្យពួកគេមានសុខភាពល្អ មានសុវត្ថិភាព និងជៀសផុតពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ។

### ប្រព័ន្ធកិច្ចការពារកុមារ

ប្រព័ន្ធកិច្ចការពារកុមារ សំដៅដល់បណ្តុំនៃវិធានការដែលបង្កើតឡើងក្នុងគោលបំណងជំរុញ និងលើកកម្ពស់កិច្ចការពារកុមារពីការរំលោភបំពាននានា ការមិនអើពើ ការកេងប្រវ័ញ្ចគ្រប់ទម្រង់ និងអំពើហិង្សាលើកុមារ។ ប្រព័ន្ធកិច្ចការពារកុមារផ្តោតលើ ការបង្ការ និងការឆ្លើយតប។

### ការបង្ការ

ការបង្ការ គឺជាបណ្តុំសកម្មភាព និងសេវាគាំទ្រនានាដែលត្រូវអនុវត្តដើម្បីបញ្ចៀសពីហានិភ័យផ្សេងៗកុំឱ្យកើតមានចំពោះកុមារ ដូចជា ការលើកកម្ពស់ការយល់ដឹង សមត្ថភាពទូទៅរបស់អ្នកពាក់ព័ន្ធនឹងកុមារខ្លួនឯងផ្ទាល់ដើម្បីឱ្យកុមារក្លាយជាម្ចាស់សិទ្ធិពេញលេញ។

### ការឆ្លើយតប

ការឆ្លើយតប គឺជាបណ្តុំសកម្មភាពអន្តរាគមន៍នៅមានពេលហានិភ័យកើតឡើងចំពោះកុមារ ឬក្រោយពេលមានហានិភ័យ ទៅតាមប្រភេទហានិភ័យនីមួយៗដើម្បីគាំទ្រ និងស្តារសុខុមាលភាពរបស់កុមារឡើងវិញតាមរយៈសេវាគាំទ្រនានាដែលជួយកុមារឱ្យទទួលបាននូវអត្ថប្រយោជន៍ខាងផ្លូវកាយ ផ្លូវចិត្តសម្ភារ ដើម្បីពួកគេអាចវិលត្រឡប់មករស់នៅក្នុងផ្ទះ សាលារៀន និងសហគមន៍វិញ ប្រកបដោយផាសុកភាព សុវត្ថិភាព និងការអភិវឌ្ឍ។

**ការបញ្ជូនកុមារ**

ការបញ្ជូនកុមារ គឺជាសកម្មភាពបញ្ជូនកុមារ ដែលទទួលរងគ្រោះ ឬទទួលរងហានិភ័យពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ទៅរកសេវាគាំទ្រនានាដែលត្រឹមត្រូវ។ ការបញ្ជូនកុមារទៅរកសេវាគាំទ្រនានា អាចធ្វើឡើងតាមវិធីចំនួនបី រួមមានៈ កុមារទៅរកសេវាដោយខ្លួនឯង ការបញ្ជូនកុមារដោយអន្តរស្ថាប័ន និងការបញ្ជូនកុមារផ្ទៃក្នុងស្ថាប័ន។

**កុមារទៅរកសេវាដោយខ្លួនឯង**

កុមារទៅរកសេវាដោយខ្លួនឯង គឺជាសកម្មភាពកើតមានឡើងនៅពេលកុមារធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកផ្តល់សេវាគាំទ្រនានា ហើយកុមារមិនត្រូវបានបញ្ជូន ឬអន្តរាគមន៍ដោយបុគ្គលណាផ្សេងឡើយ។

**ការបញ្ជូនកុមារដោយអន្តរស្ថាប័ន**

ការបញ្ជូនកុមារដោយអន្តរស្ថាប័ន គឺជាសកម្មភាពបញ្ជូនកុមារពីស្ថាប័នមួយទៅស្ថាប័នមួយទៀត ឧទាហរណ៍ ការបញ្ជូនកុមារពីស្ថាប័នទទួលករណីដំបូងទៅស្ថាប័នផ្តល់សេវាផ្នែកសុខភាព បន្តទៅសេវាជំនួយផ្នែកច្បាប់ និងការបញ្ជូនកុមារបន្តទៅស្ថាប័នផ្តល់សេវាពិគ្រោះយោបល់ផ្លូវចិត្ត ឬស្ថាប័នផ្តល់សេវាថែទាំ ។ល។ ឬការបញ្ជូនកុមារពីស្ថាប័នរដ្ឋទៅអង្គការមិនមែនរដ្ឋាភិបាលនានា។

**ការបញ្ជូនកុមារផ្ទៃក្នុងស្ថាប័ន**

ការបញ្ជូនកុមារផ្ទៃក្នុងស្ថាប័ន គឺជាសកម្មភាពបញ្ជូនកុមារឱ្យទទួលបានសេវាផ្សេងៗនៅក្នុងស្ថាប័នតែមួយ។ ការបញ្ជូនកុមារតាមវិធីនេះអាចមានទម្រង់ច្រើនប្រភេទ ដូចជា ការបញ្ជូនកុមារពីបុគ្គលដែលទទួលកុមារដំបូង ទៅរកសេវាអន្តរាគមន៍ពីគណៈគ្រប់គ្រង ឬបន្តបញ្ជូនកុមារទៅរកសេវាគាំទ្រនានាចាំបាច់ដទៃទៀតនៅក្នុងស្ថាប័ននោះ។

**អ្នកផ្តល់សេវា**

អ្នកផ្តល់សេវា គឺរាល់បុគ្គលិកស្ថាប័នរដ្ឋ បុគ្គលិកស្ថាប័នឯកជនមានច្បាប់អនុញ្ញាតត្រឹមត្រូវ អ្នកស្ម័គ្រចិត្ត អ្នកអនុវត្តន៍ភារកិច្ចផ្តល់សេវា និងអ្នកជួយគាំទ្រដល់កុមារដែលរងគ្រោះពីអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់។

**អំពើហិង្សាលើកុមារ**

អំពើហិង្សាលើកុមារ គឺជាសកម្មភាពទាំងឡាយណាដែលរំលោភបំពានលើកុមារ ដែលមានទម្រង់រួមមាន អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្លូវភេទ និងការមិនអើពើ ឬការមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ។

**អំពើហិង្សាផ្លូវកាយ**

អំពើហិង្សាផ្លូវកាយ គឺជាការប្រើកម្លាំង ឬអំណាចដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់រាងកាយកុមារ ដោយចេតនា ឬអចេតនាពីអ្នកដទៃ និងសមាជិកគ្រួសារណាម្នាក់ អាចជា ការវាយដំដោយដៃ ឬវត្ថុអ្វីមួយ ការទះកំផ្លៀង ការអង្រួនឱ្យកុមារភិតភ័យ ការចាប់គ្រវែង ឬគ្រវាត់ ការខាំ ការក្ដិចមួល ការញ៉ឹងត្រចៀក ការប្របាច់ក ការខ្វាចនឹងក្រចក ការដុត ឬធ្វើឱ្យរលាក ការធ្វើឱ្យថប់ដង្ហើម ឬជ្រមុជទឹក ការទាត់ធាក់ ការធ្វើឱ្យដាច់រលាត់ ការបង្ខំលុតជង្គង់ ឬឈររយៈពេលយូរ ការបង្ខំឱ្យបរិភោគអាហារដែលប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរ ។ល។ នៅក្នុងករណីជាច្រើន អំពើហិង្សាលើរាងកាយកុមារ អាចត្រូវបានប្រើប្រាស់ក្នុងទម្រង់ជាការដាក់ទណ្ឌកម្ម។

**អំពើហិង្សាផ្លូវភេទ**

អំពើហិង្សាផ្លូវភេទ គឺជាសកម្មភាពបង្ខំ ឬល្បួងកុមារឱ្យប្រព្រឹត្តអំពើអាសអាភាស និងរួមភេទ ឬការប៉ុនប៉ងទទួលបានសកម្មភាពផ្លូវភេទ ទោះបីជាកុមារនោះមានការយល់ដឹង ឬមិនមានការយល់ដឹងពីអ្វីដែលកើតឡើង ឬកុមារនោះយល់ព្រមក៏ដោយ ដែលសកម្មភាពនេះប្រព្រឹត្តដោយបុគ្គលណាមួយ ឬបុគ្គលមួយក្រុម ដែលមិនមានទំនាក់ទំនង ឬមានទំនាក់ទំនងជាមួយកុមារទាំងនោះ។ សកម្មភាពអំពើហិង្សាលើផ្លូវភេទមានដូចជា ការបៀតបៀនកេរខ្មាស ការរំលោភបំពានផ្លូវភេទផ្ទាល់ ឬដោយពាក្យសម្ដី ការឱ្យកុមារមើលរូបភាព និងវីដេអូអាសអាភាស ឬចូលរួមប្រព្រឹត្តសកម្មភាពផ្ទាល់ និងទម្រង់នានាតាមអនឡាញជាដើម។

**អំពើហិង្សាផ្លូវចិត្ត**

អំពើហិង្សាផ្លូវចិត្ត គឺជាសកម្មភាពដែលធ្វើបាបផ្លូវអារម្មណ៍ និងទឹកចិត្តរបស់កុមារដែលនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ និងយូរអង្វែងទៅលើការអភិវឌ្ឍផ្នែកបញ្ញា ស្មារតីរបស់កុមារ។ ទង្វើនាំឱ្យកើតមានអំពើហិង្សាផ្លូវចិត្ត មានដូចជា ការស្ដីបន្ទោសកុមារ ការដាក់ងារ ការជេរប្រមាថ ការបង្អាប់ ប្រៀបធៀបពីចំនុចខ្សោយ បញ្ជាក់ពីអសមត្ថភាពរបស់កុមារ ការបដិសេធនូវតម្រូវការ ការរិះគន់បែបអវិជ្ជមាន ការមើលងាយ ប្រាប់ថាពួកគេគ្មានតម្លៃ និងគ្មានអ្នកស្រលាញ់ចូលចិត្ត ការបំភិតបំភ័យ ឬគម្រាមកំហែង ការឃារឃាំងឱ្យនៅកន្លែងបិទជិត ងងឹត ឬនៅតែម្នាក់ឯង ។ល។

**ការមិនអើពើ ឬការមិនយកចិត្តទុកដាក់**

ការមិនអើពើ ឬការមិនយកចិត្តទុកដាក់ គឺជាសកម្មភាពដែលមិនយកចិត្តទុកដាក់ ឬខកខានដោយផ្ទាល់ ឬប្រយោលចំពោះការឆ្លើយតប និងការផ្ដល់ជូនទៅនឹងតម្រូវការចាំបាច់ និងជាមូលដ្ឋានរបស់កុមារ ដែលអាចនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍរបស់កុមារគ្រប់វិស័យ ដូចជា សុខភាព អប់រំ ស្មារតី អាហារូបត្ថម្ភ ជម្រក កិច្ចគាំពារសង្គម ។ល។ សកម្មភាពមិនអើពើ ឬការមិនយកចិត្តទុកដាក់ មានដូចជា ការទុកកុមារចោលនៅផ្ទះតែម្នាក់ឯង ការមិនផ្ដល់អាហារគ្រប់គ្រាន់ដល់កុមារ ការមិនឱ្យកុមារទៅរៀន កុមារមានជំងឺមិនទទួលបានការព្យាបាល ការមិនផ្ដល់កិច្ចគាំទ្រផ្លូវចិត្ត ការមិនផ្ដល់ក្ដីស្រលាញ់ដល់កុមារ

ការមិនឱ្យកុមារនិយាយ និងការមិនស្តាប់នូវកង្វល់ ឬបញ្ហាដែលកុមារលើកឡើង និងការមិនឱ្យកុមារចូលរួមនៅក្នុងសកម្មភាពនានានៅក្នុងសហគមន៍។ល។

**ការកេងប្រវ័ញ្ចលើកុមារ**

ការកេងប្រវ័ញ្ចលើកុមារ គឺជាសកម្មភាពទាំងឡាយណាដែលប្រើប្រាស់កុមារ ដើម្បីទទួលបាននូវផលប្រយោជន៍សម្រាប់អ្នកដទៃ ដែលសកម្មភាពនោះផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរទៅលើរាងកាយ ផ្លូវចិត្ត ផ្លូវភេទ សុខភាព និងការអភិវឌ្ឍរបស់កុមារ។ សកម្មភាពកេងប្រវ័ញ្ចលើកុមារ មានដូចជា ការឱ្យកុមារធ្វើការដើម្បីរកប្រាក់ចំណូល ការបង្ខំឱ្យកុមារធ្វើការនៅកន្លែងគ្រោះថ្នាក់ កុមារមិនបានទៅរៀនសូត្រ ការបង្ខំឱ្យកុមារប្រើប្រាស់ និងជួញដូរគ្រឿងញៀន និងគ្រឿងស្រវឹង ការជួញដូរកុមារ ការលក់សរីរាង្គមួយចំនួនរបស់កុមារ ។ល។ ទម្រង់នៃការកេងប្រវ័ញ្ចលើកុមារ រួមមាន ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទ។

**ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច**

ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច សំដៅលើការប្រើប្រាស់កុមារ ដើម្បីផលប្រយោជន៍របស់អ្នកដទៃ ឬការរកប្រាក់ចំណេញពីកុមារ ដែលជាញឹកញាប់ធ្វើឱ្យមានភាពអយុត្តិធម៌ និងឃោរឃៅហើយប៉ះពាល់ទៅដល់កុមារ។ សកម្មភាពទាំងនេះ បាននាំឱ្យមានប៉ះពាល់ដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត ការអប់រំ ការអភិវឌ្ឍផ្នែកសីលធម៌ ឬផ្លូវអារម្មណ៍របស់កុមារ។

**ការកេងប្រវ័ញ្ចកម្លាំងពលកម្ម**

ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ សំដៅលើការបង្ខំ ឬការប្រើប្រាស់កុមារឱ្យធ្វើការងារតាមរូបភាពផ្សេងៗ ដើម្បីបំពេញគោលបំណង ឬផលប្រយោជន៍របស់អ្នកដទៃ ដែលការងារទាំងនោះបានបង្កគ្រោះថ្នាក់ដល់កុមារ និងធ្វើឱ្យកុមារបាត់បង់សក្តានុពលនៃការអភិវឌ្ឍផ្នែកបញ្ញា ស្មារតី រូបរាងកាយ ផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូរបស់កុមារ។ ឧទាហរណ៍៖ ការប្រើប្រាស់កុមារឱ្យចូលរួមក្នុងជម្លោះប្រដាប់អាវុធ ឬការប្រើប្រាស់កុមារធ្វើការងារឱ្យអ្នកដទៃ ដើម្បីដោះបំណុល ។ល។

**ការកេងប្រវ័ញ្ចផ្លូវភេទ**

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ សំដៅលើការឱ្យប្រាក់ អាហារ អំណោយ ឬការអនុគ្រោះណាមួយដើម្បីបានទទួបានការរួមភេទ ឬការសម្តែងសកម្មភាពផ្លូវភេទក្នុងទម្រង់ណាមួយជាមួយនឹងកុមារ ឬការធ្វើឱ្យកុមារមិនសប្បាយចិត្ត ដោយនិយាយទៅកាន់កុមារក្នុងន័យផ្លូវភេទ ឬសរសេរអំពីបញ្ហាផ្លូវភេទរបស់កុមារ ឬបង្ខំឱ្យកុមារមើលរូប ឬវីដេអូអាសអាភាសដែលផ្ទុយពីឆន្ទៈរបស់កុមារ ឬបង្ខំឱ្យកុមារចូលរួមក្នុងការថតរូប ឬវីដេអូអាសអាភាស ។ល។

**ការសម្លុតធ្វើបាប**

ការសម្លុតធ្វើបាប គឺជាសកម្មភាពមានចេតនាបង្កឱ្យមានការឈឺចាប់ដល់អ្នកដទៃតាមរយៈការធ្វើបាបរាងកាយ ពាក្យសម្តី ឬអាកប្បកិរិយា។ សកម្មភាពធ្វើឡើងដដែលៗម្តងហើយម្តងទៀតពីសំណាក់កុមារម្នាក់ ឬជាក្រុមដែលមានរាងកាយធំជាង មានអំណាចជាង មានទ្រព្យសម្បត្តិច្រើនជាង មានគ្រួសារល្អប្រសើរជាង មានកម្លាំងខ្លាំងជាង មានប្រជាប្រិយភាពខ្លាំងជាង ចំពោះកុមារដែលខ្សោយជាងខ្លួន។

**ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (អ៊ីនធឺណេត)**

ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ គឺជាទម្រង់មួយនៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារដែលកើតឡើងនៅក្នុងបច្ចេកវិទ្យាអនឡាញ (អ៊ីនធឺណេត) ដូចជា គេហទំព័រ ប្រព័ន្ធទំនាក់ទំនងសង្គមនៅលើអនឡាញ (អ៊ីនធឺណេត) ទូរស័ព្ទ ឬកម្មវិធីចល័តដទៃទៀត ដែលរួមមាន ការផលិត និងការចែកចាយសម្ភាររំលោភបំពានផ្លូវភេទ រូបភាពអាសអាភាសអនឡាញ (អ៊ីនធឺណេត) ការល្បួងកុមារក្នុងគោលបំណងកេងប្រវ័ញ្ច និងរំលោភបំពានដោយប្រើប្រាស់បច្ចេកវិទ្យាអនឡាញ (អ៊ីនធឺណេត) ឬទូរស័ព្ទ ការផ្សាយបន្តផ្ទាល់ក្នុងប្រព័ន្ធទាំងនេះ បានបង្កជាអំពើកេងប្រវ័ញ្ច និងរំលោភបំពានគ្រប់ទម្រង់លើកុមារ។

**ឧបសម្ព័ន្ធទី ១២ ÷ ឯកសារគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងសាលារៀន**

| | |
|---|---|
| សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស | **មាត្រា៥** សិទ្ធិទទួលបានកិច្ចការពារពីការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬការប្រព្រឹត្តកាចសាហាវឥតមនុស្សធម៌ ឬថោកទាបបានឡើយ<br>**មាត្រា២៦** សិទ្ធិទទួលបានការអប់រំជាមូលដ្ឋាន និងប្រកបដោយគុណភាព អភិវឌ្ឍបុគ្គលិកលក្ខណៈ គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន |
| អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ | **មាត្រា១៩** សិទ្ធិកុមារទទួលបានកិច្ចការពារពីអំពើហិង្សា និងការរំលោភបំពាន<br>**មាត្រា ២៩** សិទ្ធិកុមារទទួលការសិក្សាអប់រំប្រកបដោយគុណភាព<br>**មាត្រា ៣២** សិទ្ធិកុមារទទួលបានកិច្ចការពារអំពីអំពើពលកម្មធ្ងន់ធ្ងរ<br>**មាត្រា ៣៣** សិទ្ធិកុមារទទួលបានកិច្ចការពារអំពីការប្រើប្រាស់កុមារនៅក្នុងការផលិត ការប្រើប្រាស់ និងជួញដូរសារធាតុញៀនខុសច្បាប់ |
| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា | **មាត្រា៣៨** ធានាមិនឱ្យមានការរំលោភលើរាងកាយលើបុគ្គលណាមួយឡើយ<br>**មាត្រា៤៨** ធានារក្សាការពារសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការពារប្រឆាំងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ |
| ច្បាប់ស្តីពីអប់រំ | **មាត្រា១៧** ធានាឱ្យអ្នកសិក្សារីកចម្រើនចំណេះដឹង សីលធម៌ និងបុគ្គលិកលក្ខណៈល្អ<br>**មាត្រា៣៥** អ្នកសិក្សាមានសិទ្ធិបញ្ចេញទស្សនៈសិក្សា សេរីភាពសិក្សា ទទួលបានការសិក្សាប្រកបដោយគុណភាព ចូលរួមក្រុម និងសកម្មភាពអប់រំ ទទួលបាននូវសេចក្តីថ្លៃថ្នូរ និងរួចផុតពីអំពើទារុណកម្ម ឬការដាក់ទណ្ឌកម្មនានាលើរាងកាយ និងស្មារតី |
| អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | **មាត្រា៥** ប្រកាន់ខ្ជាប់នូវសីលធម៌ក្នុងការប្រកបវិជ្ជាជីវៈ<br>**មាត្រា៧** ការមិនរើសអើងចំពោះអ្នកសិក្សា និងអ្នកអាណាព្យាបាលរបស់ពួកគេ<br>**មាត្រា១២** មិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ និងផ្លូវចិត្តដែលនាំឱ្យប៉ះពាល់ដល់អ្នកសិក្សា |
| គោលនយោបាយស្តីពីសាលារៀនកុមារមេត្រី | សមាសភាគទី៣ សុខភាព សុវត្ថិភាព និងការការពារកុមារ |
| គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារផ្ទាំ | គោលដៅទី២ រៀបចំ និងអនុវត្តប្រព័ន្ធការពារកុមារជាពហុវិស័យ |

| | |
|---|---|
| ២០១៩-២០២៩ | គោលដៅទី៤ លើកកម្ពស់ការយល់ដឹង និងឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង |
| **គោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន** | យុទ្ធសាស្ត្រទី១ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ |
| **គោលនយោបាយជាតិស្តីពីសុខភាពសិក្សា** | យុទ្ធសាស្ត្រ៥.២ លើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា និងបុគ្គលិកអប់រំ<br>យុទ្ធសាស្ត្រ៥.៧ លើកកម្ពស់ការអប់រំសុខភាព |
| **ផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៩ - ២០២៣** | គោលនយោបាយទី១ ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន |
| **ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀនឆ្នាំ២០១៩-២០២៣** | យុទ្ធសាស្ត្រទី១៖ សកម្មភាព ១.១ ង.បង្កើតនូវសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន |
| **ផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១** | យុទ្ធសាស្ត្រទី២៖ ការទប់ស្កាត់បឋម<br>ផ្នែករងទី២៖ កម្មវិធីតាមសាលារៀន<br>យុទ្ធសាស្ត្រទី៣៖ សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ<br>ផ្នែករងទី៥៖ សេវាផ្នែកអប់រំ |

**ឯកសារយោង**

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- សេចក្តីសម្រេចស្តីពីការចូលរួមរបស់កុមារលេខ០១៦ កជក ឆ្នាំ២០១៤
- គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩
- របាយការណ៍ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ២០១៩

## ក្រសួងអប់រំ យុវជន និង កីឡា

- គោលនយោបាយសាលាកុមារមេត្រី
- គោលនយោបាយស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ឆ្នាំ២០១៦ និងផែនការសកម្មភាពអនុវត្តគោលនយោបាយ ២០១៩-២០២៣
- គោលការណ៍ណែនាំស្តីពីសាលារៀនសុវត្ថិភាព ឆ្នាំ២០១៣
- សេចក្តីប្រកាសស្តីពីនីតិវិធីនៃការស្នើ ឬការតវ៉ា ការប្តឹង និងដំណោះស្រាយសម្រាប់អ្នកសិក្សា មាតាបិតា ឬអ្នកអាណាព្យាបាល និងបុគ្គលិកអប់រំ លេខ២២៨០អយកប្រក ឆ្នាំ២០១២
- សេចក្តីណែនាំស្តីពីផែនការបើកសាលារៀនឡើងវិញនៅក្នុងស្ថានភាពផ្ទុះជំងឺឆ្លងកូវីដ១៩ ឆ្នាំ ២០២០
- សៀវភៅណែនាំសម្រាប់គ្រូបង្រៀននៅបឋមសិក្សាអំពីការវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀន ឆ្នាំ២០១៩
- គោលការណ៍ណែនាំស្តីពីការការពារកុមារនៅក្នុងសាលារៀនរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ឆ្នាំ២០១៤
- សេចក្តីព្រាងស្តីពីដំណើរការគ្រឹះស្ថានសិក្សាប្រកបដោយសុវត្ថិភាពក្នុងបរិបទជំងឺកូវីដ១៩ នាយកដ្ឋានសុខភាពសិក្សា

## ក្រសួងកិច្ចការនារី

- ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ២០១៨-២០២១
- គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឆ្នាំ២០១៦

## ក្រសួងមហាផ្ទៃ

- សៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់ឆ្នាំ២០១៩

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងករណីក្នុងអំឡុងពេលផ្ទុះជំងឺឆ្លងកូវីដ១៩ ឆ្នាំ២០២០
- សៀវភៅណែនាំស្តពីវិធីបំពេញទម្រង់គ្រប់គ្រងករណីឆ្នាំ២០១៨ នាយកដ្ឋានសុខុមាលភាពកុមារ

## ស្ថាប័នដៃគូ

- កូវីដ-១៩ ការបញ្ចូលនូវកិច្ចការពារកុមារទៅក្នុងការត្រឡប់ចូលរៀនៈ គន្លឹះសំខាន់ៗសម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន សារគន្លឹះសម្រាប់កុមារ និងយុវវ័យនៅពេលត្រឡប់ចូលរៀនវិញ សេចក្តីណែនាំអំពីវិធីបញ្ជូនករណីកិច្ចការពារកុមាររវាងសាលា ជាមួយអាជ្ញាធរកិច្ចការពារកុមារ និងអាជ្ញាធរដទៃទៀត អង្គការយូនីសេហ្វតំបន់អាស៊ីខាងកើតនិងប៉ាស៊ីហ្វិចឆ្នាំ២០២០
- សៀវភៅបង្រៀនសម្រាប់អ្នកសម្របសម្រួលស្តីពីការចូលរួមរបស់កុមារក្នុងកិច្ចការពារខ្លួនឯង (Sticks and Stones) អង្គការភ្លែនអន្តរជាតិឆ្នាំ២០១៣
- បទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារកុមារនៅក្នុងសកម្មភាពមនុស្សធម៌របស់សម្ព័ន្ធសម្រាប់កិច្ចការពារកុមារនៅក្នុងសកម្មភាពមនុស្សធម៌ ឆ្នាំ២០១៩
- គោលនយោបាយកិច្ចការពារកុមាររបស់អង្គការពាក់ព័ន្ធមួយចំនួនទៀត។

រៀបចំដោយ៖

ក្រសួងអប់រំ យុវជន និងកីឡា

សហការរៀបចំដោយ៖

unicef
Save the Children
PLAN INTERNATIONAL
World Vision
ChildFund Alliance
អង្គការមូលនិធិសិទ្ធិកុមារ Child Rights Foundation Organization

ក្រោមជំនួយឧបត្ថម្ភ

End Violence Against Children
Safe to Learn
Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra